ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# សិក្សាសង្គម

១០

# ភូមិវិទ្យា









ក្រសួងអប់រំ យុវជន និងកីឡា

# សិក្សាសង្គម

## ថ្នាក់ទី ១០

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៥៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | លោក អេង វ៉ាត់ | លោក មួង សុផាត |
| | លោកស្រី មាស សុគ្គន | លោកស្រី បែន នាង |
| | លោក តែន គីមគុន | លោកស្រី ច័ន្ទ សំរស្មី |
| | លោក ស៊ុន ណាត្រី | |
| **អ្នកវាយអត្ថបទ** | លោក ជុំ សត្យា | |
| **វិចិត្រករ** | លោក តន់ ជាតិ | លោក ឡុង សុវណ្ណា |
| **អ្នករៀបរៀង** | លោក លិម ហ៊ិន | លោក ប៊ី សុផល |
| | លោក ខាត់ ធី | លោក ឃ្លោក វីរ៉ា |
| **អ្នករចនាទំព័រ** | លោក ហាក់ វណ្ណថា | |
| **គណៈកម្មការពិនិត្យ** | លោក មាស ជុតិមា | លោកស្រី ព្រាប សុភ្លង |
| | លោក គីម សារី | លោកស្រី ស្វាយ ធឿម |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី **ក្រសួងអប់រំ យុវជន និងកីឡា** តាមប្រកាសលេខ ១៣៨៧ អយក.ប្រក. ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១០ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ ២០១៨

ISBN 9-789-995-000-981

# អារម្ភកថា

សៀវភៅសិក្សាសង្គមថ្នាក់ទី 10 នេះ គណៈកម្មការនិពន្ធបានរៀបចំចងក្រងឡើងដោយផ្អែកលើកម្មវិធីសិក្សាថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា ។ នៅក្នុងកម្មវិធីសិក្សាថ្មី មុខវិជ្ជាសិក្សាសង្គមមានមុខវិជ្ជារងចំនួនបួនគឺ ភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌-ពលរដ្ឋវិជ្ជា និងគេហវិទ្យា ។

ខ្លឹមសារមេរៀនដែលមាននៅក្នុងសៀវភៅនេះនឹងជួយប្អូនៗ ឱ្យមានចំណេះដឹងអំពី យេនឌ័រ និងបង្ហាញពីការរៀបចំឧស្សាហកម្មនៅលើពិភពលោក កសិករនិងកសិកម្មពិភពលោក ប្រទេសឧស្សាហកម្មថ្មីនៅអាស៊ីប៉ាស៊ីហ្វិក កំណើនប្រជាជន នគរូបនីយកម្ម ឬពីប្រវត្តិសាស្ត្រពិភពលោក តំបន់មជ្ឈិមបូព៌ា ប្រវត្តិសាស្ត្រកម្ពុជា ពីតម្លៃមនុស្ស វប្បធម៌សន្តិភាព និងការចូលរួមអភិវឌ្ឍសហគមន៍ ។

គ្រប់មេរៀនដែលមាននៅក្នុងសៀវភៅនេះ មានទម្រង់ដូចគ្នាទាំងអស់ដូចជា ការកំណត់វត្ថុបំណងនៃមេរៀនសម្រាប់ឱ្យប្អូនៗដឹងពីអ្វីដែលនឹងត្រូវសិក្សានៅក្នុងមេរៀននីមួយៗ រូបភាពច្បាស់ល្អងាយយល់ទាក់ទងនឹងខ្លឹមសារមេរៀន អត្ថបទមេរៀន សំណួរបញ្ចប់មេរៀន និងសំណួរបញ្ចប់ជំពូកសម្រាប់វាយតម្លៃលើចំណេះដឹងនៅពេលរៀនចប់ជំពូកនីមួយៗ ។

តាមរយៈខ្លឹមសារនៃមេរៀនដែលមាននៅក្នុងសៀវភៅនេះ ប្អូនៗនឹងទទួលបានចំណេះដឹងបំណិន ឥរិយាបថ តាមរយៈការសង្កេត ការបញ្ចេញមតិយោបល់ ការពិភាក្សាជាដៃគូ ឬជាក្រុម ការពិចារណា ការស្រាវជ្រាវ ប្រសើរជាងការទន្ទេញមេរៀនចាំមាត់តែមិនយល់ច្បាស់ ។ម្យ៉ាងទៀត ក្នុងការរៀបចំសៀវភៅសិក្សានេះ ក៏មានការចូលរួមផ្តល់យោបល់កែលម្អពីសំណាក់លោកគ្រូ អ្នកគ្រូនៅតាមបណ្តាខេត្តក្រុងមួយចំនួនផងដែរ ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅសិក្សាសង្គមថ្នាក់ទី 10 នេះ នឹងក្លាយជាមិត្តដ៏ល្អរបស់ប្អូនៗសិស្សានុសិស្សជាក់ជាមិនខាន ។ ទន្ទឹមគ្នានេះដែរ គណៈកម្មការនិពន្ធរីករាយនឹងទទួលយកមតិកែលម្អពីសំណាក់អ្នកគ្រូ លោកគ្រូ និងប្រិយមិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន ។

គណៈកម្មការនិពន្ធ

# បញ្ជីអត្ថបទ

## ភូមិវិទ្យា

ជំពូក1 : ទីតាំងឧស្សាហកម្ម និងលំហភូមិសាស្ត្រ.......................................1
ជំពូក2 : កសិករ និងកសិកម្មពិភពលោក.......................................23
ជំពូក3 : ប្រទេសឧស្សាហកម្មថ្មីនៅអាស៊ីប៉ាស៊ីហ្វិក.......................................41
ជំពូក4 : កំណើនប្រជាជន និងផលវិបាក.......................................67
ជំពូក5 : នគរូបនីយកម្ម និងបញ្ហា.......................................83

# ជំពូកទី 1 ទីតាំងឧស្សាហកម្មនិងលំហភូមិសាស្ត្រ



*បណ្តុំឧស្សាហកម្មស្រួចស្រាល់ (បច្ចេកវិទ្យាខ្ពស់)នៃមេកាឡូប៉ូលនាប្រទេសជប៉ុន*

ឧស្សាហកម្ម ជាផ្នែកគន្លឹះមួយនៃសេដ្ឋកិច្ច និងជាសូចនាករ(អាំងឌីកាទ័រ)ដ៏សំខាន់ដែល បង្ហាញឱ្យឃើញពីកម្រិតអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមនៃប្រជាជន និងតំបន់នានា ព្រោះវាជាសកម្មភាពដែលប្លែងរូបធាតុដើមឱ្យទៅជាផលិតផលពាក់កណ្តាលសម្រេច ឬផលិតផលសម្រេច ។

តាមការពិត លំហឧស្សាហកម្មទទួលបានការផ្លាស់ប្តូរយ៉ាងខ្លាំង តាំងពីសតវត្សទី ១៨ មកម្ល៉េះ ដោយសារបដិវត្តន៍ផ្នែកបច្ចេកវិទ្យានិងថាមពល ។ ពួកអ្នកស្រាវជ្រាវដោយផ្អែកលើកត្តានិងទ្រឹស្តីនៃតំណាំងទី អាចយល់និងពន្យល់បានអំពីបញ្ហានេះ គឺភាពខុសគ្នាជាសារវន្តរវាងលំហឧស្សាហកម្មចាស់និងថ្មី ។

# 1 ឧស្សាហកម្មជាគន្លឹះនៃសេដ្ឋកិច្ច

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីចំណែកថ្នាក់ឧស្សាហកម្ម និងសារៈសំខាន់ឧស្សាហកម្ម
- ❑ ស្រឡាញ់ចូលចិត្តបច្ចេកទេសឧស្សាហកម្ម ដើម្បីរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិ ។

ជាទូទៅ ឧស្សាហកម្មទាំងអស់ត្រូវចាត់ទុកថាជាផ្នែកទី 2 នៃសេដ្ឋកិច្ច ព្រោះជាគន្លឹះដ៏សំខាន់នៃអភិវឌ្ឍន៍សង្គមជាតិនីមួយៗ ។ តាមពិតឧស្សាហកម្មមានច្រើនប្រភេទទទួលបានកំណែប្រែទៅតាមការវិវត្តនៃបច្ចេកទេសវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទំនើប ។

## 1. ឧស្សាហកម្ម

ឧស្សាហកម្ម ជាសំណុំសកម្មភាពសេដ្ឋកិច្ចដែលប្រើប្រាស់ ឬប្លែងរូបធាតុដើម ដើម្បីផលិតគ្រឿងសម្ភារៈ ។ សំណុំសកម្មភាពទាំងនេះសំដៅបង្កើតផលិតផលក្នុងបរិមាណដ៏ច្រើនសម្បើម និងសម្បូរបែប ដើម្បីបំពេញតម្រូវការរបស់មនុស្ស ដោយផ្តើមចេញពីរូបធាតុដើម ឬផលិតផលពាក់កណ្តាលសម្រេចតាមមធ្យោបាយបច្ចេកទេសក្នុងរចនាសម្ព័ន្ធពិសេសមួយគឺរោងចក្រ ។ ជារួមមានឧស្សាហកម្មជីកគាស់ អគារនិងសាធារណការ ផលិតកម្មទឹក ឧស្ម័ននិងអគ្គិសនី ព្រមទាំងឧស្សាហកម្មប្លែងភាពផងដែរ ។

## 2. ប្រភេទឧស្សាហកម្ម

ជាទូទៅ គេអាចធ្វើចំណែកថ្នាក់ឧស្សាហកម្មជាសាខា ឬអនុសាខាទៅតាមផលិតផលបង្កើតបាន និងទៅតាមបច្ចេកទេសអនុវត្តន៍ ។ ប៉ុន្តែគេអាចធ្វើចំណែកថ្នាក់ផ្សេងទៀតដែរទៅតាម ៖

- លក្ខណៈធ្ងន់នៃរូបធាតុដើម ឬផលិតផលសម្រេច : ឧស្សាហកម្មធុនធ្ងន់ ឧស្សាហកម្មធុនស្រាល ។
- កម្រិតកម្ពស់នៃបម្រើបម្រាស់ផលិតផលបង្កើតបាន : គ្រឿងឧបភោគបរិភោគ គ្រឿងបរិក្ខារផលិតផលពាក់កណ្តាលសម្រេច ។

- កម្រិតកម្ពស់បច្ចេកវិទ្យា : ឧស្សាហកម្មប្រពៃណី ឧស្សាហកម្មស្រួចស្រាល់ ឬបច្ចេកវិទ្យាខ្ពស់ ។
- តម្រូវការទុន : ឧស្សាហកម្មមូលធន(វិនិយោគទុនដ៏ច្រើនសម្បើម)ឬឧស្សាហកម្មហត្ថពលករ ។

ចំណែកថ្នាក់ឧស្សាហកម្ម




## 3. ទម្ងន់ឧស្សាហកម្មនៅក្នុងសេដ្ឋកិច្ច

អស់រយៈពេលជាច្រើនសតវត្សមកឧស្សាហកម្មមានលក្ខណៈជាគ្រួសារ ។ មនុស្សម្នាក់អាចជាកសិករផង ជាងឈើ ជាងកំបោរ និងអ្នកតម្បាញផង ។ បន្ទាប់មកក៏បានក្លាយទៅជាសិប្បកម្មដែលមនុស្សធ្វើការដោយប្រើ ឧបករណ៍សាមញ្ញមានជំនួយពីកម្មករអាចផលិតវត្ថុមួយឬច្រើនប្រភេទបាន ។

នៅសតវត្សទី 19និងដើមសតវត្សទី 20លក្ខខណ្ឌមួយចំនួនបានរួមចំណែកធ្វើឱ្យមានការរីកលូតលាស់ផ្នែកឧស្សាហកម្មដូចជា កំណើនតម្រូវការរបស់របរប្រើប្រាស់ក្នុងពិភពលោកដែលជំរុញឱ្យមានវិនិយោគទុនកាន់តែច្រើនឡើងៗ ។



*សកម្មភាពឧស្សាហកម្មនៅកម្ពុជា*

នៅសតវត្សទី 20 ប្រទេសទាំងឡាយបានរិះរកគ្រប់មធ្យោបាយជំរុញផ្នែកឧស្សាហកម្មដែលជាគន្លឹះសម្រាប់អភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចជាតិ ។ ប្រទេសលោកខាងលិចដែលមានភាពចំណាស់ខាងឧស្សាហកម្ម បានខិតខំរក្សាភាពឈានមុខផ្នែកបច្ចេកវិទ្យារបស់ខ្លួន និងខំរៀបចំឧស្សាហកម្មនៅលើលំហដែនដីរបស់ខ្លួនឱ្យបានកាន់តែប្រសើរឡើង ។

ចំណែកប្រទេសសេដ្ឋកិច្ចផែនការនៅអឺរ៉ុបខាងកើតនិងប្រទេសកំពុងអភិវឌ្ឍ បានកំណត់យកឧស្សាហកម្មធុនធ្ងន់ជាអាទិភាពក្នុងយុទ្ធសាស្ត្រសេដ្ឋកិច្ចរបស់ខ្លួន ។

ទោះបីទម្ងន់ឧស្សាហកម្មលើផ្នែកការងារនិងតម្លៃបន្ថែមឧស្សាហកម្មនៅក្នុងប្រទេស ឬតំបន់ជាច្រើនមានការថយចុះក៏ដោយ ក៏ឧស្សាហកម្មនៅតែជាសកម្មភាពសំខាន់នៃជីវិតសេដ្ឋកិច្ចដដែល ព្រោះវាជាមជ្ឈមណ្ឌលប្រមូលផ្តុំរបៀបបញ្ចូលបច្ចេកវិទ្យាថ្មីៗ ហើយជះឥទ្ធិពលទៅលើផ្នែកផ្សេងៗទៀត ជាអាទិ៍តី កសិកម្មនិងសេវាកម្ម ។ គេអាចចាត់ទុកតម្លៃបន្ថែមឧស្សាហកម្មក្នុងមនុស្សម្នាក់ជាអាំងឌីកាទ័រមួយដ៏ល្អដែលអាចបង្ហាញពីកម្រិតអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិនីមួយៗ ។

តំហាយចុះនៃទម្ងន់ឧស្សាហកម្ម ជាលទ្ធផលបានមកពីការវិវត្តបច្ចេកវិទ្យាក្នុងពេលថ្មីៗនេះដែលបានកាត់បន្ថយចំនួនកម្មករអស់មួយភាគធំ ហើយបានបង្កើតការងារជំនាញកាន់តែច្រើនជំនួសវិញ ។




*ផែនទីពិភពលោក : តម្លៃបន្ថែមឧស្សាហកម្មសម្រាប់មនុស្សម្នាក់ (គិតជាលានដុល្លារ) 1990*

## ? សំណួរ

1. ចូរធ្វើការបកស្រាយតារាងចំណែកថ្នាក់ឧស្សាហកម្ម ។
2. ចូរពិនិត្យរូបភាពរោងចក្រ ។ តើលក្ខណៈត្រង់ណាដែលបង្ហាញថាវាជារោងចក្រ ?
3. តើឧស្សាហកម្មជីកគាស់ជាឧស្សាហកម្មធុនធ្ងន់ ឬធុនស្រាល ? ចូរពន្យល់ ។
4. តើសំណង់រថយន្តអាចចាត់ទុកជាឧស្សាហកម្មប្រភេទណាខ្លះ ?
5. តើតំហាយចុះនៃទម្ងន់ឧស្សាហកម្មអាចនាំឱ្យបាត់បង់សក្តានុភាពសេដ្ឋកិច្ចដែរ ឬទេ ? ចូរពន្យល់ ។
6. តើអ្វីខ្លះដែលជាលក្ខខណ្ឌអភិវឌ្ឍន៍ឧស្សាហកម្ម ?

មេរៀនទី

# 2 បណ្តុំឧស្សាហកម្ម

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីសកម្មភាពឧស្សាហកម្ម បណ្តុំឧស្សាហកម្ម និងលំហឧស្សាហកម្មបច្ចុប្បន្ន
- ❑ ស្រឡាញ់ការងារផលិតកម្មពិសេសវិស័យឧស្សាហកម្ម ។

ដើមឡើយឧស្សាហកម្មស្ថិតនៅបែកខ្ញែកពីគ្នា ។ ក្រោយបដិវត្តន៍ឧស្សាហកម្ម សកម្មភាពផ្នែកនេះមានលក្ខណៈប្រមូលផ្តុំយ៉ាងខ្លាំង ។ ចាប់ពីឆ្នាំ 1960មក បណ្តុំឧស្សាហកម្មបានកើនឡើងទ្វេដង បង្កើតបានជាភូមិវិទ្យាឧស្សាហកម្មថ្មីមួយ ។

## 1. សកម្មភាពឧស្សាហកម្មមុនសតវត្សទី 18




*ទីតាំងទីឧស្សាហកម្មនៅប្រទេសបារាំងមុនបដិវត្តន៍ឧស្សាហកម្ម (ឆ្នាំ 1780)*

តាំងពីសម័យបុរេប្រវត្តិមកដល់សតវត្សទី 18 ផលិតកម្មគ្រឿងសម្ភារៈក្រៅពីឧបករណ៍កសិកម្ម តែងជួបការលំបាក ភាពអន់ថយផ្នែកគមនាគមន៍ ភាពក្រខ្សត់និងតម្លៃខ្ពស់នៃរូបធាតុដើម ជំរុញឱ្យកសិករផលិតឧបករណ៍ប្រើប្រាស់ដោយខ្លួនឯង ។ បន្តិចក្រោយមក ការងារសិប្បកម្មក៏លេចរូបរាងឡើង ពិសេសនៅទីក្រុងដែលប្រព្រឹត្តទៅក្នុងរោងជាងគ្រួសារ ហើយបានប្រមូលផ្តុំនិងចងក្រងជាសមាគមមុខរបរ ។

នៅសតវត្សទី 17 កម្មន្តសាលត្រូវបានបង្កើតឡើងដោយមានសិប្បករជាច្រើនរយនាក់ចូលរួម និងទទួលបានការបែងចែកការងារផង ។ កំពង់ផែនានាដែលអនុគ្រោះដល់ពាណិជ្ជកម្មអាណានិគម បានក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្មដ៏សំខាន់ ។

ជារឿយៗទីផ្សារដែលមានកំណត់ផងនោះ តម្រូវឱ្យមានការបំបែកការងារទៅក្នុងលំហ ។ កម្លាំងចលករនៃទឹកហូរនិងខ្យល់បក់ ការប្រើប្រាស់ថាមពលអុស អាចឱ្យគេតាំងទីរោងចក្រឧស្សាហកម្មបានច្រើនកន្លែងនៅតាមព្រៃឈើ ឬក្បែរផ្លូវទឹក ។ ផលិតកម្មក្នុងបរិមាណតិចតួចត្រូវការតែធនធានមានកម្រិតដូចជា អណ្តូងរ៉ែកណ្តាលវាល ។

## 2. បណ្តុំលំហឧស្សាហកម្មនៅសតវត្សទី 19




*តំណាំងទីឧស្សាហកម្មនៅប្រទេសបារាំង ឆ្នាំ 1880*




*តំណាំងទីឧស្សាហកម្មនៅប្រទេសបារាំងរវាងឆ្នាំ 1930*

បដិវត្តន៍ឧស្សាហកម្មបានកើតឡើងនៅប្រទេសអង់គ្លេសនៅដំណាច់សតវត្សទី 18 រួចបានរីកសាយខ្ទាំងអឺរ៉ុបភាគពាយ័ព្យនៅដើមសតវត្សទី 19 ។ វាជាបដិវត្តន៍បច្ចេកទេស (គ្រឿងយន្តជំនួសឱ្យឧបករណ៍)និងបដិវត្តន៍ថាមពល (បម្រើបម្រាស់ម៉ាស៊ីនដើរដោយចំហាយទឹក)រួមគ្នាតែម្ដង ។ បម្រើបម្រាស់ថាមពលធ្យូងថ្ម ធ្វើឱ្យតំបន់អាងធ្យូងមានការរីកចម្រើនដោយបានប្រមូលផ្ដុំក្រុមកម្មករនិងឧស្សាហកម្មនានា (ឧស្សាហកម្មដែក ឧស្សាហកម្មវាយនភ័ណ្ឌ) ។

សិប្បកម្មជនបទបានចុះថយសកម្មភាពនៅចំពោះមុខឧស្សាហកម្ម ។ រីឯទីក្រុងមួយចំនួនតូចបានប្រមូលផ្ដុំសកម្មភាពប្រពៃណីប្រចាំតំបន់របស់ខ្លួនឡើងវិញ ។ ទាំងនេះបង្កើតឱ្យមានភូមិវិទ្យាឧស្សាហកម្មបច្ចុប្បន្នមួយ ។ ផែនទីទាំងពីរខាងលើ បានបញ្ជាក់ច្បាស់ពីបញ្ហានេះ ។

នៅដំណាច់សតវត្សទី 19 កើតមានបដិវត្តន៍ថាមពលមួយទៀត ។ បម្រើបម្រាស់អគ្គិសនីបានរីកសាយភាយ ហើយម៉ាស៊ីនផ្ទុះដែលដើរដោយថាមពលប្រេងកាតក៏បានបង្កើតឡើង ។ ឧស្សាហកម្មគីមីអគ្គិសនី -លោហកម្មនិងទព្វសម្ភារៈថ្មីៗក៏បានចេញមកបង្ហាញមុខ ។ នៅយុគសម័យមួយដែលដំណឹកជញ្ជូនអគ្គិសនីផ្លូវឆ្ងាយមិនទាន់ប្រព្រឹត្តទៅបាន រោងចក្រវារីអគ្គិសនីបានទាក់ទាញឧស្សាហកម្មឱ្យមកតាំងទីនៅតាមជ្រលងភ្នំ ។ ឧស្សាហកម្មប្លែងភាពដែលមិនសូវត្រូវការរូបធាតុដើមច្រើនតាំងនៅតំបន់សម្បូរហត្ថពលករ (ទីក្រុង) ជាហេតុជំរុញឱ្យមាននគរូបនីយកម្មយ៉ាងខ្លាំងក្លា ។ អាងអណ្ដូងរ៉ែនៅតែជាកន្លែងទាក់ទាញមនុស្សឱ្យចូលទៅរស់នៅ ។ សំណុំឧស្សាហកម្មចាស់ៗនៅមាននៅឡើយហើយបានផ្សុំខ្លួនទៅនឹងលក្ខខណ្ឌថ្មីៗ ។ សង្គ្រាមលោកលើកទី I អនុគ្រោះដល់ការចាប់ផ្ដើមឧស្សាហូបនីយកម្មនៅប្រទេសនានាក្រៅទ្វីបអឺរ៉ុប ។

## 3. លំហឧស្សាហកម្មបច្ចុប្បន្ន

តាំងពីជាង 40ឆ្នាំមកហើយ ឧស្សាហកម្មទទួលបានផលចំណេញច្រើនពីបំណែងចែកលំហថាមពល និងទទួលបានបំលាស់ប្តូរបច្ចេកទេសយ៉ាងជ្រាលជ្រៅ (ស្វ័យប្រវត្តូបនីយកម្ម មនុស្សយន្តូបនីយកម្ម ផលិតផលថ្មីៗ) ។ ឧស្សាហកម្មហាក់ដូចជាលែងទាក់ទិនទៅនឹងសង្កាត់កម្មករទៀតហើយ ។ មណ្ឌលឧស្សាហកម្មផ្សេងៗគ្នា ត្រូវបានរៀបចំនៅតាមបរិមណ្ឌលក្រុងដោយមិនបានធ្វើឱ្យបាត់បង់ទេសភាពឥតសណ្ដាប់ធ្នាប់នៃបណ្ដុំក្រុងពីមុនមកនោះទេ ។ តំណាំងទីថ្មីៗនៃឧស្សាហកម្មស្រួចស្រាល់ឬក្រៅពីនេះក្ដីត្រូវតែគិតគូរពីភាពស្អាត ពោលគឺសាកល្បងបង្ហាញនូវស្នាដៃថ្មីមួយព្រមទាំងក្របខណ្ឌជីវភាពមួយឱ្យកាន់តែល្អប្រសើរឡើង ។

ការដាក់តំបន់ឆ្នេរឱ្យទៅជាតំបន់ឧស្សាហកម្មធុនធ្ងន់ ទាមទារភាពចំពេងនៃសំណង់ដូចជា ឡស្លដែកធុនយក្ស ដើម្បីសម្រេចឱ្យបាននូវបទដ្ឋានសេដ្ឋកិច្ច ។

និយាយរួមការរីកសាយភាយមួយដែលមានលក្ខណៈមិនស្មើភាពកំពុងប្រព្រឹត្តទៅដោយយឺតៗនៅក្នុងលោកយើងនេះ ។



*ទេសភាពឧស្សាហកម្មនៅទីប្រជ្រលងទន្លេ ប្រទេសអាល្លឺម៉ង់*

## សំណួរ

1. ចូរសាកល្បងបកស្រាយតំណាំងទីឧស្សាហកម្មនៅប្រទេសបារាំងនៅរវាងឆ្នាំ 1780 ។
2. ចូរសាកល្បងបកស្រាយតំណាំងទីឧស្សាហកម្មនៅប្រទេសបារាំងនៅរវាងឆ្នាំ 1880 ។
3. ចូរសាកល្បងបកស្រាយតំណាំងទីឧស្សាហកម្មនៅប្រទេសបារាំងនៅរវាងឆ្នាំ 1930 ។
4. ចូរពិនិត្យរូបភាពទេសភាពឧស្សាហកម្មនៅឱ្យសបួ (អាល្លឺម៉ង់) ៖

   ក. តើអ្វីខ្លះជាធាតុសំខាន់ៗនៃទេសភាពតំបន់ស្លដែកនេះ ?

   ខ. ហេតុអ្វីបានជាគេចាត់ទុកទេសភាពនេះជាគំរូនៃអាងឧស្សាហកម្មបុរាណមួយ ?
5. តើសកម្មភាពឧស្សាហកម្មមុនសតវត្សទី 18 មានការវិវត្តដូចម្តេច ?
6. តើបណ្តុំឧស្សាហកម្មនៅសតវត្សទី 19 កើតឡើងដោយសារកត្តាអ្វីខ្លះ ?
7. តើលំហាឧស្សាហកម្មបច្ចុប្បន្នមានទម្រង់ដូចម្តេចខ្លះ ?

មេរៀនទី

# 3 ការរៀបចំឧស្សាហកម្មនៅលើពិភពលោក

**ចប់មេរៀននេះ សិស្សអាច**

- យល់បានពីរបៀបរៀបចំលំហឧស្សាហកម្មនៅលើពិភពលោកនិងផលប៉ះពាល់ដល់បរិស្ថាន
- ស្រឡាញ់និងរួមចំណែករក្សាការពារបរិស្ថានកម្ពុជា ។

ឧស្សាហូបនីយកម្មនៅលើពិភពលោកមានរបាយមិនស្មើគ្នាទេ ។ អាស្រ័យហេតុនេះហើយទើបគេសង្កេតឃើញមានប្រទេសមហាអំណាចឧស្សាហកម្ម ប្រទេសឧស្សាហកម្មថ្មី ប្រទេសឧស្សាហកម្មលូតលាស់មធ្យម និងប្រទេសឧស្សាហកម្មអន់ថយ ។ ឧស្សាហូបនីយកម្ម បានក្លាយទៅជាបាតុភូតសកលទៅហើយនាពេលបច្ចុប្បន្ននេះ ។ រីឯលំហឧស្សាហកម្មក៏បានផ្តល់ទេសភាពប្លែកៗច្រើនយ៉ាងដែរ ។

## 1. វិសមភាពឧស្សាហូបនីយកម្មលើពិភពលោក

### 1.1. ប្រទេសមហាអំណាចឧស្សាហកម្ម

ប្រទេសមហាអំណាចឧស្សាហកម្មមានសហរដ្ឋអាមេរិក រុស្ស៊ី ជប៉ុន ប្រទេសអឺរ៉ុបខាងលិចប្រមូលផ្តុំផលិតផលឧស្សាហកម្មបានមួយចំនួនធំ ព្រមទាំងមានសក្តានុភាពផ្នែកហិរញ្ញវត្ថុនិងបច្ចេកវិទ្យាទៀតផង ។ នៅក្នុងប្រទេសមហាអំណាចទាំងនេះ ឧស្សាហកម្មមានគ្រប់ប្រភេទ តែគេក៏ឃើញមានភាពផ្ទុយគ្នារវាងតំបន់ឧស្សាហកម្មលូតលាស់និងតំបន់ឧស្សាហកម្មកំពុងជួបវិបត្តិ ។

តើវិបត្តិឧស្សាហកម្មនោះជាអ្វី ? គឺជាតំហយចុះនៃបរិមាណផលិតផលឧស្សាហកម្ម ដោយសារតម្រូវការរបស់ទីផ្សាររួមតូចនិងតម្លៃខ្ពស់ខ្លាំងនៃផលិតផលដូចជា សំណង់នាវា ផលិតកម្មដែក គីមីមូលដ្ឋានជាដើម ។ ពេលខ្លះ ផ្នែកវាយនភ័ណ្ឌមិនអាចទប់ទល់និងការប្រជែងពីសំណាក់ប្រទេសកំពុងអភិវឌ្ឍដែលមានតម្លៃពលកម្មទាបជាង ។ សម្ភារៈបរិក្ខារ ពិសេសរថយន្តជាផលិតផលដែលមានការប្រជែងគ្នាយ៉ាងខ្លាំងនៅក្នុងបណ្តាប្រទេសឧស្សាហកម្មលូតលាស់ ។

ដើម្បីសាកល្បងដោះស្រាយការលំបាកទាំងនេះ និងរក្សាជំហររឹងមាំតទៅទៀត គេបានប្រើយុទ្ធវិធីផ្សេងៗដូចជាធ្វើស្វ័យប្រវត្តូបនីយកម្មឧស្សាហកម្មដែលមានវិបត្តិ ការបិទឧស្សាហកម្មដែលគ្មានចំណេញ ធ្វើឯកទេសកម្មសំដៅលើកកម្ពស់គុណភាពផលិតផល (ដែកថែប សម្លៀកបំពាក់ប្រណីត) និងការជួយពង្រឹងដើមទុន ។ កិច្ចការទាំងនេះទាមទារការកាត់បន្ថយចំនួនពលករដែលជាហេតុនាំមកនូវបញ្ហាសង្គម ពិសេសនៅក្នុងតំបន់មានឯកទេសកម្មខ្ពស់ ។ម្យ៉ាងទៀត គេបានផ្តោតការយកចិត្តទុកដាក់ទៅលើឧស្សាហកម្មស្រួចស្រាល់(បច្ចេកវិទ្យាខ្ពស់)ដែលមានប្រសិទ្ធភាពពាណិជ្ជកម្មខ្លាំង ។ ការបោះទីតាំងរោងចក្រនៅបរទេស ជាលក្ខខណ្ឌប្រសើរបំផុតក្នុងការទាក់ទាញយកផលប្រយោជន៍ ។



*ប៉ូលឧស្សាហកម្មគីមីចម្បងមួយនៅយូកូហាម៉ាប្រទេសជប៉ុន*

ស្ថានភាពនៃការប្រកួតប្រជែងមិនដូចគ្នាទេ ។ សហរដ្ឋអាមេរិកនិងជប៉ុនហាក់ឈ្នះដាច់គេ នៅចុងសតវត្សទី 20 ដោយសារភាពជឿនលឿនខាងបច្ចេកវិទ្យានិងភាពទំនើបនៃម៉ាស៊ីនផលិតរបស់ខ្លួន ។ ប្រទេសអឺរ៉ុបខាងលិច ត្រូវប្រឈមមុខនឹងកំណែប្រែតំបន់ឯកទេសកម្មទាំងស្រុងដោយលំបាកលំបិន ដូចជាប្រទេសបារាំងជាដើម ។

## 1.2. ប្រទេសឧស្សាហកម្មថ្មី

ប្រទេសឧស្សាហកម្មថ្មីប្រមាណ 20 ជាគូប្រជែងរបស់ជប៉ុនមាន កូរ៉េខាងត្បូង តៃវ៉ាន់ សិង្ហបុរី ហុងកុង ឥណ្ឌា ម៉ាឡេស៊ី ហ្វីលីពីន ម៉ិកស៊ិក ប្រេស៊ីល ។ល ។ តាំងពីឆ្នាំ 1995 មក ប្រទេសទាំងនោះប្រើប្រាស់ពលករសរុបចំនួន 30 លាននាក់នៅក្នុងឧស្សាហកម្មហើយសម្រេចបាន 10% នៃឧស្សាហផលពិភពលោក ។ ដោយផ្តើមចេញពីសហគ្រាសតូចៗក្នុងស្រុក គេបានឈានដល់ពហុដ្ឋានឧស្សាហកម្ម ដែក គីមី រថយន្ត នាវា និងយន្តហោះ ។ បន្ទាប់ពីវគ្គហ៊ឹកហ៊ើន ប្រទេសទាំងនោះបានចាកផុតពីភាពរណបខាងបច្ចេកទេសរបស់បស្ចិមប្រទេសនិងជប៉ុន ហើយសម្រេចជោគជ័យលើសកម្មភាពដែលមានតម្លៃខ្ពស់ក្នុងផលិតកម្មមិនសូវទំនើបនិងអាចបំពេញតម្រូវការរបស់ប្រជាជនលោកខាងត្បូង ។ ប្រទេសឧស្សាហកម្មលូតលាស់ថ្មីទាំងនោះ មានសមត្ថភាពនាំចេញយន្តូបករណ៍រោងចក្រ ហើយមានបណ្តាញពាណិជ្ជកម្មអន្តរជាតិដូចប្រទេសជប៉ុនដែរ ។ តម្លៃពលកម្មទាប ផ្តល់លទ្ធភាពឱ្យប្រទេសដទៃទៀតអាចក្លាយទៅជាប្រទេសឧស្សាហកម្មលូតលាស់ថ្មីនាពេលអនាគតដ៏ខ្លីដូចជា ឥណ្ឌូណេស៊ី ថៃ ចិន ។ ប៉ុន្តែនៅក្រុមប្រទេសក្រោយនេះ បំណុលនិងភាពអាស្រ័យនឹងបរទេសអាចធ្វើឱ្យរអាក់រអួលដល់ការលូតលាស់ឧស្សាហកម្ម ។



*រថយន្តម៉ាក ហ៊ីយុនដៃ(កូរ៉េ)បម្រុងនាំចេញ*

## 1.3. ប្រទេសឧស្សាហកម្មអន់ថយ

ប្រទេសឧស្សាហកម្មអន់ថយនៅរក្សាកេរដំណែលប្រព័ន្ធអាណានិគម ពោលគឺជាប្រភពផ្តល់រូបធាតុដើមនិងជាទីផ្សារប្រើប្រាស់ផលិតផលឧស្សាហកម្ម ។ ប្រទេសភាគច្រើននៅទ្វីបអាហ្វ្រិក មានតែធនធានធម្មជាតិ តែខ្វះដើមទុន និងគ្មានហត្ថពលករជំនាញ ។ ម្ល៉ោះហើយការធ្វើឧស្សាហូបនីយកម្មតែងជួបការលំបាក ឬត្រូវរណបប្រទេសក្រៅដែលសម្បូរទុននិងបច្ចេកវិទ្យាខ្ពស់ ។ បច្ចុប្បន្នគេអាចផលិតសម្ភារៈសំណង់ សាច់សំពត់ ស្បៀង ក្នុងបំណងកាត់បន្ថយការនាំចូលតែប៉ុណ្ណោះ ។

ឧស្សាហកម្មនៅប្រទេសក្រីក្រ នាសតវត្សទី 20នេះ មានសភាពដូចនៅប្រទេសអឺរ៉ុបកាលពីសតវត្សទី 19ដែរ គឺឧស្សាហកម្មបានបង្កើតលក្ខខណ្ឌការងារនិងជីវភាពយ៉ាងតឹងតែងដល់ពលករនិងជាអ្នកបង្កើតភាពតោកយ៉ាកដល់មនុស្សទាំងប្រុសទាំងស្រី រួមទាំងកុមារផង ។

ភាពថមថយនៃសេដ្ឋកិច្ចក្រោយឆ្នាំ 1973 និងការផ្លាស់ប្តូរបច្ចេកទេសធ្វើឱ្យការប្រជែងគ្នាលើទីផ្សារពិភពលោកមានសភាពកាន់តែខ្លាំងក្លា ហើយបង្ខំឱ្យម្នាក់ៗប្រើប្រាស់អស់លទ្ធភាពដែលគេមាន ។

នៅគ្រប់ទីកន្លែងក្នុងប្រទេសឧស្សាហកម្មមិនថាចាស់ឬថ្មីទេ គេបានខិតខំធ្វើការស្រាវជ្រាវអភិវឌ្ឍន៍សំដៅដណ្តើមទីផ្សារ ។ លំហឧស្សាហកម្មមានទំហំធំធេងណាស់ បើគេរួមបញ្ចូលគ្នារវាងទីផ្សាររូបធាតុដើម មជ្ឈមណ្ឌលផលិតកម្ម និងទីផ្សារលក់ផលិតផលសម្រេច ។

## 2. ទេសភាពឧស្សាហកម្ម

លំហឧស្សាហកម្មផ្តល់ទេសភាពប្លែកៗគ្នាច្រើនយ៉ាង ។ ជួនកាលសហគ្រាសឧស្សាហកម្មមិនអាចមើលឃើញភ្លាមៗទេ ទាល់តែយកចិត្តទុកដាក់សង្កេត ព្រោះវាស្ថិតនៅលាយឡំរាយប៉ាយក្នុងទីក្រុង ក្នុងភូមិ តាមដងទន្លេ ឬក្នុងព្រៃ ។

*ឧទាហរណ៍* : ផលិតកម្មដែលស្រដៀងគ្នានិងសិប្បកម្ម ដូចជា ការងារច្នៃឈើ ផលិតកម្មកែវគ្រឿងយន្តតូចតាច... ។ ផ្ទុយទៅវិញ ជារឿយៗអ្នកភូមិវិទ្យាអាចរកឃើញដោយងាយនូវឧស្សាហកម្មនានា ដែលជ្រៀតចូលតាមសង្កាត់ក្នុងទីក្រុង ។

រោងចក្រទាក់ទាញរោងចក្រ : រោងចក្រប្រមូលផ្តុំ ជួនកាលតាមសង្កាត់ឧស្សាហកម្មក្នុងទីក្រុងធំៗ ឬតាមលំនៅស្ថាន ជួនកាលប្រមូលផ្តុំតាមតំបន់ឧស្សាហកម្មដែលបំពាក់ដោយបរិក្ខារសមូហភាព ឬជាអគាររៀបចំទុកជាមុនដែលបង្កើតឡើងដោយរដ្ឋ ឬដោយសមូហភាពមូលដ្ឋាន ។ ស៊ីលីខុនវ៉ាលេ (Silicon Valley) នៅកាលីផរនី សហរដ្ឋអាមេរិក ជាបណ្តុំសំខាន់ជាងគេបំផុតក្នុងពិភពលោកខាងឧស្សាហកម្មកុំព្យូទ័រ ។ ទីក្រុងខ្លះមានឯកទេសកម្មខ្លាំងខាងវាយនភ័ណ្ឌ ឧស្សាហកម្មដែកថែប ឬសំណង់រថយន្ត ដូចជាទីក្រុងរូបេ (បារាំង) ទីក្រុងពីតស្បឺក (Pittsburgh) ឌីត្រយ (Detroit) នៅសហរដ្ឋអាមេរិក ។ ទីក្រុងខ្លះទៀតរីកធំឡើងៗរហូតដល់ក្លាយជាទីក្រុងដ៏ធំសម្បើមដូចជាទីក្រុងឡុង (London) នៅអង់គ្លេស ប៉ារីស (Paris) នៅបារាំង មីឡង់ (Milan) នៅអ៊ីតាលី និងក្លាយជាមេកាឡូប៉ូល (Mégalo pole) នៅភាគឦសានសហរដ្ឋអាមេរិក ឬតូកាយដូ (Tokaido) មេកាឡូប៉ូល នៅតាមបណ្តោយឆ្នេរភាគខាងត្បូងកោះហុងដូ ជប៉ុន ។ លំហឧស្សាហកម្មនិងលំហទីក្រុងមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ។



*បណ្តុំឧស្សាហកម្មនៅអូសាកាប្រទេសជប៉ុន*

បណ្តុំរោងចក្រ និងបុរីឧស្សាហកម្មអាចមានពាសពេញនៅក្នុងតំបន់ ។ បណ្តុំជាខ្សែរៀបរយនៅតាមជ្រលងដូចជា ជ្រលងស្ទឹងអូស (Oise) និងតំបន់ទន្លេសែនក្រោមក្នុងប្រទេសបារាំង ឆ្នេរភាគអាគ្នេយ៍ប្រទេសជប៉ុនដែលមានប៉ុលឧស្សាហកម្ម បណ្តោយមាត់បឹងធំនិងឆ្នេរអាត្លង់ទិចនៃសហរដ្ឋអាមេរិក និងនៅអឺរ៉ុបពីទន្លេសែនទៅដល់ទន្លេអែល ដែលបានរៀបចំជាតំបន់កំពង់ផែឧស្សាហកម្មធំៗ ។ តំបន់កំពង់ផែឧស្សាហកម្មសំខាន់ៗមាន ហាំបួ (Hambourg) រ៉ូទែដាំ (Rotterdam) ដង់គែក (Dunkerque) និងហាវ (Havre) ។ នៅទីនោះគេឃើញមានឧស្សាហកម្មចម្រាញ់ប្រេងកាត គីមីប្រេងកាត ដែកថែប សំណង់នាវា អាលុយមីញ៉ូម និងឧស្សាហកម្មថាមពលធំៗ ។ នៅមានឧស្សាហកម្មសម្ភារៈបរិក្ខារ និងគ្រឿងឧបភោគបរិភោគថែមទៀត ។ អាងឧស្សាហកម្ម គឺជាបណ្តុំឧស្សាហកម្មធំៗអស្ចារ្យដូចជា អាងដុនបាសនៅអ៊ុយក្រែន តំបន់រ៉ាំងរួនៅអាល្លឺម៉ង់ ។ តំបន់រួមានបណ្តុំឧស្សាហកម្មដ៏ធំមួយគួរឱ្យស្ញប់ស្ញែងដែលមានទំនាក់ទំនងបច្ចេកទេសរវាងរោងចក្រធ្យូងកូក ឡស្ពដែក រោងចក្រដែកថែប រោងចក្រអគ្គិសនី រោងចក្រគីមី នៅក្បែរលំនៅស្ថានកម្មករនិងចម្ការ ។ តំបន់នេះក៏មានបណ្តុំហិរញ្ញវត្ថុនិងសហគ្រាសធំៗផងដែរ ដូចជា ធីសិន អិន គ្រុប (THYSSEN AND KRUPP) ដែលធំជាងគេនៅអឺរ៉ុប ។ មនុស្សចំនួន 11 លាននាក់រស់នៅក្នុងតំបន់ត្រីកោណដែលមានជ្រុងប្រវែង 100km ស្ថិតនៅចន្លោះក្រុងបោន (Bourn) ដកមុន (Dortmund) និងឌ្វីសបួ (Duisbourg) ។ តំបន់ខាងត្បូងទន្លេរ៉ាំងមានរោងចក្រវាយនភ័ណ្ឌជាហូរហែ ហើយឧស្សាហកម្មឯកទេសលេចធ្លោជាងគេស្ថិតនៅជាប់ៗគ្នាតាមទីក្រុងកូឡូញនិងឌូសិលដហ្វ (Dusseldorf) ។



*រោងចក្រឧស្សាហកម្មគីមី (នៅអឺរ៉ុប)*

## សំណួរ

1. ដូចម្ដេចហៅថា ឧស្សាហូបនីយកម្ម ?
2. តើវិបត្តិឧស្សាហកម្មនៅប្រទេសមហាអំណាចបណ្ដាលមកពីមូលហេតុអ្វីខ្លះ ? តើគេដោះស្រាយដោយមធ្យោបាយណាខ្លះ ?
3. តើអ្វីខ្លះដែលជាកត្តាអនុគ្រោះដល់ឧស្សាហូបនីយកម្មនៅប្រទេសមួយចំនួនដូចជា ឥណ្ឌូណេស៊ី ថៃ ចិន ជាដើម ។
4. ប្រទេសជាច្រើននៅទ្វីបអាហ្វ្រិកសម្បូរធនធានធម្មជាតិណាស់ ហេតុអ្វីបានជាឧស្សាហូបនីយកម្មនៅប្រទេសទាំងនោះមិនអាចសម្រេចឡើងបាន ?
5. តើទេសភាពឧស្សាហកម្មមានលក្ខណៈសម្គាល់សំខាន់ៗអ្វីខ្លះ ? ចូររៀបរាប់ ។

មេរៀនទី

# 4 កត្តាតំណាំងទីនិងផលបះពាល់បរិស្ថាន

**ចប់មេរៀននេះ សិស្សអាច**

- យល់បានកត្តាតំណាំងទីនិងផលប៉ះពាល់បរិស្ថាន
- បកស្រាយបានពីបញ្ហាទាំងនោះ ។

គ្រប់ការជ្រើសរើសទីតាំង តែងបានមកពីសេចក្ដីសម្រេចរបស់សហគ្រិនណាម្នាក់ ទៅតាមលក្ខណៈវិនិច្ឆ័យផ្សេងៗហៅថា កត្តាតំណាំងទី ។ ម៉្យាងទៀត ដើម្បីបានជាក្បួនខ្នាតសម្រាប់ទ្រទ្រង់លំនាំនៃការជ្រើសរើស អ្នកស្រាវជ្រាវបានបង្កើតទ្រឹស្ដីតំណាំងទី សំដៅបញ្ចៀសអ្វីដែលមិនចាំបាច់ នាំឱ្យខាតបង់ផលប្រយោជន៍និងប៉ះពាល់ដល់បរិស្ថាននាពេលបច្ចុប្បន្ននិងទៅអនាគត ។

## 1. កត្តាតំណាំងទីឧស្សាហកម្ម

### 1.1. ទីតាំងឧស្សាហកម្មចាស់



*រោងចក្រមីសឺឡាំង នៅក្លែរម៉ង់-ហ្វែរ៉ង់ (បារាំង)*

ទីតាំងឧស្សាហកម្មជាច្រើន ជាមរតកនៃប្រវត្តិសាស្ត្រ ។ នៅសតវត្សទី 19 និងដើមសតវត្សទី 20 នៅពេលដែលឧស្សាហកម្មកំពុងរីកចម្រើននៅអឺរ៉ុបនិងអាមេរិកខាងជើង ឧស្សាហកម្មច្រើនមានទីតាំងនៅក្បែរប្រភពថាមពលនិងរូបធាតុដើម ។ ចំណែកឧស្សាហកម្មកម្មន្តសាលមានទីតាំងនៅជិតទីផ្សារប្រើប្រាស់ និងកន្លែងសម្បូរហត្ថពលករ ។

នៅតំបន់ខាងជើងប្រទេសបារាំង តំបន់កណ្ដាល និងនិរតីប្រទេសអង់គ្លេស តំបន់ភ្នំអាប៉ាឡាសនៅសហរដ្ឋអាមេរិក តំបន់ដូណិតនៅរុស្ស៊ី និងតំបន់រួនៅប្រទេសអាល្លឺម៉ង់ដោយឧស្សាហកម្មបានប្រើប្រាស់ថាមពលធ្យូងថ្មដែលបញ្ចេញផ្សែងខ្មួលខ្មាញ់ទៅលើអាកាស គេហៅតំបន់ទាំងនោះថា ស្រុកផ្សែងធ្យូង (Pays Noirs) ។ តំបន់កំណប់រ៉ែដែក ក៏ជាទីតាំងឧស្សាហកម្មល្អប្រសើរដែរ កាលណាគេអាចដឹកជញ្ជូនធ្យូងថ្មចូលទៅបានដោយតម្លៃថោក ។ ស្រុកផ្សែងធ្យូង ក៏បានទាក់ទាញប្រជាជននិងឧស្សាហកម្មផ្សេងទៀតដែរ ដូចជាឧស្សាហកម្មវាយនភ័ណ្ឌដែលប្រើប្រាស់ភាគច្រើនជាកម្មការិនី ។ ឧស្សាហកម្មប្លែងភាពតាំងនៅតំបន់សម្បូរថាមពល ដូចជាឧស្សាហកម្មអាលុយមីញ៉ូមនៅតាមជ្រលងក្បែររោងចក្រវារីអគ្គិសនី ។ ឧស្សាហកម្មធុនស្រាល តាំងនៅតំបន់ទីក្រុងដែលអាចផ្ដល់កម្មករជំនាញ មូលធន និងទីផ្សារប្រើប្រាស់ផលិតផលសម្រេច តែក៏អាចស្ថិតនៅក្នុងតំបន់កំពង់ផែដែលជាកន្លែងទទួលផលិតផលនាំចូល ជាពិសេសគ្រឿងបរិភោគផងដែរ ។

ឧស្សាហកម្មខ្លះទៀត កើតពីគំនិតផ្ដួចផ្ដើមផ្ទាល់របស់គ្រួសារមួយដូចជា ក្រុមហ៊ុន ហ្វត (Ford) នៅឌីត្រយ (Detroit) នៅសហរដ្ឋអាមេរិក មីសឺឡាំង (Michelin) នៅក្លែរម៉ង់-ផេរ៉ង់ (Clermont-Ferand) រីណូ (Renault) នៅប៉ារីស ប៉ឺស្ហូ (Peugeot) នៅសូស្ហូ (ប្រទេសបារាំង) ។

## 1.2. ទីតាំងឧស្សាហកម្មថ្មី

នៅពាក់កណ្ដាលសតវត្សទី 20 កត្តាតំណាំងទីឧស្សាហកម្មក្បែរប្រភពថាមពលនិងរូបធាតុដើម មិនមែនជាកត្តាសំខាន់ប៉ុន្មានទេ តែបញ្ហាកម្លាំងពលកម្មទេ ដែលមានសារៈសំខាន់ជាង (កម្មករជំនាញ និងកម្រិតប្រាក់បៀវត្ស) ។ សហគ្រាសឧស្សាហកម្មធំៗ ត្រូវការចំនួនកម្មករកាន់តែច្រើន តែគេឱ្យតម្លៃកាន់តែខ្ពស់ទៅលើលក្ខណៈទីតាំងណាដែលងាយផ្គត់ផ្គង់ទឹក ងាយចេញចូល និងងាយបញ្ចេញកាកសំណល់ ។

នៅឆ្នាំ 1970 ប្រទេសឧស្សាហកម្មជាច្រើន បានប្រកាន់យកនយោបាយរៀបចំលំហឧស្សាហកម្មជាថ្មីឡើងវិញ ។ តំបន់ដែលជួបការលំបាកបានទទួលជំនួយសម្រាប់ការរៀបចំ តែការផ្លាស់ប្ដូរផលិតកម្មក៏មិនមែនជាការងាយស្រួលដែរ ។ តំបន់ដែលសកម្មបំផុតនោះ គឺតំបន់កំពង់ផែនិងជ្រលងទន្លេដែលអាចឱ្យគេតាំងទីឧស្សាហកម្មធុនធ្ងន់ៗបាន (ឧស្សាហកម្មផែកតាមផ្លូវទឹក) ។ ភាពដែលអាច

ប្រកួតប្រជែងបាន ស្ថិតនៅលើកំណែលម្អតាមរយៈការកាត់បន្ថយសោហ៊ុយដឹកជញ្ជូនផលិតផល ។ តំបន់ឧស្សាហកម្មថ្មីៗត្រូវបានបង្កើតឡើងគ្រប់ផ្នែកផលិតកម្ម នៅជិតទីក្រុងធំៗ និងសកលវិទ្យាល័យ (ស៊ីលីខុនវ៉ាលេ នៅសហរដ្ឋអាមេរិក) ឬក្បែរអណ្តូងរ៉ែថ្មីៗ (ស៊ីបេរី) ។ បច្ចេកវិទ្យាទំនើបអាចចូលទៅក្នុងបណ្តាប្រទេសដែលមិនបានរៀបចំធ្វើឧស្សាហូបនីយកម្មដូចជា រោងចក្រដែលគេទិញមកដំណើរការភ្លាមនិងធានារ៉ាប់រងដោយប្រទេសអ្នកលក់ ។ ប្រទេសកំពុងអភិវឌ្ឍ (កូរ៉េខាងត្បូង តៃវ៉ាន់...) ដែលធ្វើឧស្សាហូបនីយកម្មដោយប្រើបច្ចេកទេសលោកខាងលិច បានក្លាយទៅជាប្រទេសឧស្សាហកម្មថ្មី ។



*ឧស្សាហកម្មនៅប្រទេសសិង្ហបុរី*

កំពង់ផែតាមឆ្នេរសមុទ្រជាទីតាំងឧស្សាហកម្មដ៏ប្រសើរ ព្រោះវាងាយទាក់ទងមកកាន់ទីប្រជុំជនក្នុងប្រទេសតាមបណ្តាញផ្លូវថ្នល់ ផ្លូវទឹក និងផ្លូវដែក ដែលជាកត្តាទាក់ទាញឧស្សាហកម្មផងនិងរួមចំណែកពង្រីកអានុភាពតំបន់ឆ្នេរសមុទ្រផង ។

ហេតុនេះ តំណាំងទីរោងចក្រកាន់តែមានភាពងាយស្រួលឡើងរហូតដល់មិនចាំបាច់គិតទុកជាមុន ហើយការរៀបចំភូមិសាស្ត្រឧស្សាហកម្មថ្មីមួយកំពុងកើតឡើងក្នុងកម្រិតជាតិ និងអន្តរជាតិ ។ ប្រទេសលូតលាស់ បានបោះទីតាំងឧស្សាហកម្មក្នុងប្រទេសកំពុងអភិវឌ្ឍដែលមានផ្ទៃដីធំទូលាយងាយស្រួលបញ្ចេញចោលកាកសំណល់ ។ ប្រទេសទាំងនោះខិតខំស្រូបយកចំណេញពីអំណោយផល

ទីតាំង តម្លៃពលកម្មទាបនៅតំបន់អាស៊ីអាគ្នេយ៍ និងនៅប្រទេសចិន (តំបន់សេដ្ឋកិច្ចពិសេស) ដោយសារការយកពន្ធដារតិច ។ ដោយសារលក្ខខណ្ឌទាំងពីរចុងក្រោយនេះ វិនិយោគទុនបរទេសនៅកម្ពុជាមានទឹកប្រាក់ជាង 2 200 លានដុល្លារ ចាប់ពីពាក់កណ្ដាលឆ្នាំ 1994 ដល់ពាក់កណ្ដាលឆ្នាំ 1996 ។ ជាង 60% នៃវិនិយោគទុនឯកជនស្ថិតនៅក្នុងផ្នែកឧស្សាហកម្មធុនស្រាល និងសេវាកម្ម ។ វិបត្តិសេដ្ឋកិច្ចពិភពលោកបច្ចុប្បន្នក៏បានជះឥទ្ធិពលអវិជ្ជមានមកលើវិស័យឧស្សាហកម្មកម្ពុជាដែរ ។

ឧស្សាហូបនីយកម្មមិនចាំបាច់ផ្ដើមចេញពីឧស្សាហកម្មធុនធ្ងន់និងឧស្សាហកម្មគន្លឹះណាមួយនោះទេ ។ សព្វថ្ងៃឧស្សាហកម្មផ្ដើមចេញពីសហគ្រាសតូចនិងមធ្យម ។ ឧស្សាហូបនីយកម្ម អាស្រ័យលើសមត្ថភាពបញ្ចូលរបៀបផលិតថ្មីៗ លើការបណ្ដាក់ទុនរកស៊ីរបស់ម្ចាស់សហគ្រាសលើក្រុមហ៊ុនពហុជាតិនិងលើការសម្រេចពីអំណាចនយោបាយ ។

## 2. ផលប៉ះពាល់នៃឧស្សាហកម្មទៅលើបរិស្ថាន

ឧស្សាហកម្មរីកដុះដាលកាន់តែខ្លាំង ផលវិបាកក៏មានកាន់តែច្រើនដែរ ។ ឧស្សាហកម្មដែលដើរដោយចំហេះឥន្ធនៈផូស៊ីល បង្កឱ្យមានឧស្ម័នពុលផ្សេងៗជាច្រើនទៅក្នុងបរិយាកាស ពិសេសកាបូនឌីអុកស៊ីតដែលជាឧស្ម័នផ្ទះកញ្ចក់ដ៏សំខាន់មួយ រួមចំណែកក្នុងការធ្វើឱ្យផែនដីឡើងកម្ដៅ ។ ឧស្សាហកម្មដើរដោយចំហេះឥន្ធនៈនុយក្លេអ៊ែបន្សល់ទុកនូវកាកសំណល់ជាតិពុល ពិសេសធាតុវិទ្យុសកម្មដ៏គ្រោះថ្នាក់ពេលមានការបែកធ្លាយចេញពីរោងចក្រ ។ ឧស្សាហកម្មគីមី តែងបង្កមហន្តរាយដល់បរិស្ថានទាំងក្នុងប្រទេសអភិវឌ្ឍ និងក្នុងប្រទេសកំពុងអភិវឌ្ឍ ។

ប្រទេសជប៉ុន ជាឧទាហរណ៍យ៉ាងច្បាស់មួយដែលបញ្ជាក់ពីបញ្ហានេះ ។ តែក្នុងរយៈពេល 10 ឆ្នាំចុងក្រោយនេះ 40% នៃឆ្នេរសមុទ្រជប៉ុនត្រូវបានកែលម្អ ។ ជាងនេះទៅទៀតកង្វក់អាកាសបណ្ដាលមកពីឧស្សាហកម្មដូចជា នៅយូកែជី កាវ៉ាសាគី អាម៉ាតាស៊ី និងយូកូហាម៉ា នាំមកនូវជំងឺប្លែកៗដូចជាប្រជាជននៅទីក្រុងយូកែជីកើតមានជំងឺហឺតប្រមាណ 70 000 នាក់ ។ តាមជំរឿនបានបង្ហាញឱ្យឃើញមនុស្សស្លាប់ 562 នាក់ និងពិការ 10 000 នាក់ដោយសារការពុលជាតិបារតនៅប្រទេសជប៉ុន ។

ប្រទេសចិនបានប្រើប្រាស់ធ្យូងថ្មយ៉ាងច្រើននៅក្នុងឧស្សាហកម្ម ។ នៅប៉ឺជីន (ប៉េកាំង) ខ្យល់អាកាសពោរពេញដោយផ្សែងភ្លើង ។ ទីក្រុងនានានៃប្រទេសចិនត្រូវបានរាប់បញ្ចូលទៅក្នុងបញ្ជីក្រុងដែលមានកម្រិតកង្វក់អាកាសខ្ពស់បំផុតក្នុងពិភពលោក ។ នៅតំបន់អភិវឌ្ឍឧស្សាហកម្មធុនធ្ងន់ប្រជាជនច្រើនកើតជំងឺសួតរ៉ាំរ៉ៃ ។ តំបន់ឧស្សាហកម្មប៉ែកអាគ្នេយ៍ប្រទេសចិន មានបញ្ហាភ្លៀងអាស៊ីតយ៉ាងធ្ងន់ធ្ងរ ។ និយាយរួម ឧស្សាហូបនីយកម្មនៅប្រទេសចិននាំមកនូវបញ្ហាបរិស្ថានមានកង្វក់ទឹកនិងអាកាសកាន់តែច្រើនឡើងៗ ។



*រោងចក្របញ្ចេញផ្សែងយ៉ាងខ្លួលខ្មាញ់នៅប្រទេសចិន*

នៅឆ្នាំ 1976 នៅសីវ៉ីសូ (Seveso) ក្បែរទីក្រុងមីឡង់ (Milan) ប្រទេសអ៊ីតាលី រោងចក្រគីមីមួយបានធ្វើឱ្យបែកធ្លាយចំហាយឌីអុកស៊ីន (សារធាតុពុលខ្លាំង) ទៅក្នុងបរិយាកាស នាំឱ្យប៉ះពាល់ដល់សុខភាពប្រជាជនដែលរស់នៅទីជុំវិញនោះ ។

នៅប្រទេសបារាំងឆ្នេរសមុទ្រប្រវែង 160km ត្រូវរងគ្រោះដោយសារការបែកធ្លាយប្រេងកាតចំនួន 200 000 តោន ពីនាវាដឹកប្រេងមួយកាលឆ្នាំ 1978 បណ្តាលឱ្យបក្សីស្លាប់ចំនួន 10 000 ក្បាល ។ នៅឆ្នាំ 2001 ការផ្ទុះរោងចកក្រគីមី AZF (Azote Fertilisants ) នៅទូលូ ប្រទេសបារាំង បណ្តាលឱ្យមានមនុស្សស្លាប់អស់ 30 នាក់ របួសអស់ជាច្រើនពាន់នាក់ និងជាង 70 000 នាក់រងមហន្តរាយ ។

នៅឆ្នាំ 1984 នៅបូផល (Bhopal) ប្រទេសឥណ្ឌា ការបែកធ្លាយសារធាតុពុលបានធ្វើឱ្យមនុស្សស្លាប់អស់ប្រហែល 4 000 នាក់ ។ នៅឆ្នាំនេះដែរ ការផ្ទុះរោងចក្រគីមីមួយនៅទីក្រុងម៉ិកស៊ិកូ (Mexico) ប្រទេសម៉ិចស៊ិកបានសម្លាប់មនុស្សអស់ 600 នាក់ ។ នៅឆ្នាំ 2002 ការផ្ទុះរោងចក្រគីមី នៅឡាហ្គោស (Lagos) ប្រទេសនីហ្សេរីយ៉ា បានសម្លាប់មនុស្សអស់ 1 000 នាក់ ។

ទោះបីរោងចក្រនុយក្លេអ៊ែ បានទទួលការត្រួតពិនិត្យនិងថែរក្សាយ៉ាងជិតដល់យ៉ាងណាក៏ដោយ តែមហន្តរាយដែលបណ្តាលមកពីការបែកធ្លាយធាតុវិទ្យុសកម្មបានកើតមាននៅប្រទេសមហាអំណាចផុតលេខពីរនៅស្រ៊ីម៉ាយអ៊ីសឡិន (Three Miles Island) សហរដ្ឋអាមេរិកនៅឆ្នាំ 1979 និងនៅឈែណូ

ប៊ីល (Tchernobyl) ក្នុងរដ្ឋអ៊ុយក្រែន (សហភាពសូវៀត)ឆ្នាំ 1986 រួចមកហើយ ។ ការផ្ទុះរេអាក់ទ័រនុយក្លេអ៊ែពីរ ក្នុងចំណោមបួនកន្លែងនៅឈែណូប៊ីល បណ្ដាលឱ្យទ្វីបអឺរ៉ុបមួយភាគធំរងគ្រោះពីការធ្លាក់ធាតុវិទ្យុសកម្មដែលមិនធ្លាប់មានពីមុនមក ។ ក្នុងរយៈពេលពីរសប្ដាហ៍វិទ្យុសកម្មតិចតួចត្រូវបានគេរកឃើញនៅវ៉ាស៊ីនតោន តូក្យូ និងពាសពេញអឌ្ឍគោលខាងជើង ។ មហន្តរាយនេះបណ្ដាលឱ្យមានមនុស្សស្លាប់ចំនួន 31 នាក់រងរបួស 1 000 នាក់និងមនុស្សប្រមាណ 135 000 នាក់ ត្រូវបង្ខំចិត្តចាកចេញពីលំនៅស្ថានដែលនៅក្បែរតំបន់គ្រោះថ្នាក់ ។ តាមការប៉ាន់ស្មាននាពេលអនាគតនឹងមានមនុស្សស្លាប់លើសពី 100 000 នាក់ដោយសារជំងឺមហារីកដែលបណ្ដាលមកពីធាតុវិទ្យុសកម្ម ។ នៅអឺរ៉ុបខាងលិចការធ្លាក់ធាតុវិទ្យុសកម្មបានធ្វើឱ្យសត្វនិងដំណាំខូចខាតជាច្រើន ។

ទាំងអស់នេះបង្ហាញឱ្យឃើញថា គ្រប់សកម្មភាពទាំងអស់ដែលខ្វះភាពម្ចាស់ការ ពិសេសសកម្មភាពឧស្សាហកម្មនឹងអាចបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់បរិស្ថាន និងដល់ជីវិតមនុស្ស សត្វ រុក្ខជាតិទៀតផង ។

## ? សំណួរ

1. ដូចម្ដេចហៅថា កត្តាតំណាំងទី ? ស្រុកផ្សែងឲ្យង ?
2. តើពីដើមគេនិយមតាំងទីរោងចក្រឧស្សាហកម្មនៅទីណាខ្លះ ?
3. តើសព្វថ្ងៃតំណាំងទីឧស្សាហកម្មថ្មី ស្ថិតនៅកន្លែងណាខ្លះ ?
4. ហេតុអ្វីបានជាតំបន់ឆ្នេរសមុទ្រជាកន្លែងដ៏ល្អសម្រាប់តំណាំងទីឧស្សាហកម្ម ?
5. តើកំណើននៃឧស្សាហកម្ម នាំមកនូវផលប៉ះពាល់អ្វីខ្លះដល់បរិស្ថាន ?

## ? សំណួរបញ្ចប់ជំពូកទី១

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់មុខចម្លើយត្រូវតែមួយគត់

1. ឧស្សាហកម្មជីកគាស់ស្ថិតក្នុងប្រភេទឧស្សាហកម្ម

☐ ក. ឧស្សាហកម្មបញ្ញា ☐ ខ. ឧស្សាហកម្មធុនធ្ងន់

☐ គ. ឧស្សាហកម្មគ្មានផ្សែង ☐ ឃ. ឧស្សាហកម្មធុនស្រាល

2. ឧស្សាហកម្មប្លែងភាពច្រើនតាំងនៅ

☐ ក. ក្បែររូបធាតុដើម ☐ ខ. ក្បែរអណ្តូងធ្យូង

☐ គ. កន្លែងសម្បូរហត្ថពលករ ☐ ឃ. កន្លែងសម្បូរថាមពល

II. ចូរផ្គូផ្គងផ្នែក A និង B រួចភ្ជាប់ចម្លើយត្រូវក្នុងផ្នែក C

| A (ឈ្មោះប្រទេស) | B (ក្រុមប្រទេស) | C (ចម្លើយ) |
|---|---|---|
| 1. ប្រទេសចិននិងថៃ ។ | ក. ប្រទេសឧស្សាហកម្មថ្មី ។ | 1 → |
| 2. ប្រទេសបារាំងនិងរាជាណាចក្រ រួម ។ | ខ. ប្រទេសឧស្សាហកម្ម ។ | 2 → |
| 3. ប្រទេសកូរ៉េខាងត្បូងនិងប្រេស៊ីល ។ | គ. ប្រទេសដែលទើបចាប់ផ្តើម ឧស្សាហូបនីយកម្ម ។ | 3 → |
| | ឃ. ប្រទេសឧស្សាហកម្មទន់ខ្សោយ ។ | |

III. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. សំណង់ផ្លូវរូងក្រោមសមុទ្រជាប្រភេទឧស្សាហកម្ម .................................... ។

2. កាលពីឆ្នាំ 1986 រោងចក្រនុយក្លេអ៊ែមួយនៅ ........................ បានរងគ្រោះថ្នាក់ ។

IV. សំណួរ

1. តើកត្តានៃតំណាំងទីឧស្សាហកម្មចាស់មានអ្វីខ្លះ ? ចូររៀបរាប់ ។

2. តើកត្តានៃតំណាំងទីឧស្សាហកម្មថ្មី មានអ្វីខ្លះ ? ចូរពន្យល់ ។

3. ហេតុអ្វីបានជាប្រទេសមហាអំណាចជួបនឹងវិបត្តិឧស្សាហកម្ម ? តើគេប្រើយុទ្ធសាស្ត្រអ្វីខ្លះក្នុងការដោះស្រាយវិបត្តិនេះ ?

# ជំពូកទី 2 កសិករនិងកសិកម្មពិភពលោក



*ស្រែថ្នាក់នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី*

មុខងារទីមួយនៃកសិកម្ម គឺចិញ្ចឹមមនុស្សលោក ។ តំបន់ស្រែចម្ការត្រូវបានរចនាដោយសង្គមមនុស្សតាំងពីយូរលង់ណាស់មកហើយ ។ ប្រជាជនពិភពលោកជាង 50% រស់នៅដោយរបរកសិកម្ម ។ លំហកសិកម្មទាំងនោះ ទទួលបានកំណែប្រែនិងការវិវត្តយ៉ាងឆាប់រហ័ស ហើយកំពុងតែបាត់បង់អត្តសញ្ញាណរបស់ខ្លួន ។

នៅក្នុងប្រទេសលូតលាស់ គេយកចិត្តទុកដាក់ទៅលើកសិកម្មទំនើបដោយផ្អែកលើបម្រើបម្រាស់មធ្យោបាយបច្ចេកទេសជឿនលឿន លើតម្រូវការរបស់ទីផ្សារជាតិ និងអន្តរជាតិ ។ កសិកម្មប្រមូលផ្ដុំនៅលើទីដីដ៏ល្អប្រសើរ ហើយសំណង់ទីក្រុងកំពុងតែសម្រុកវាតទីទៅលើតំបន់ដីស្រែចម្ការជិតៗនោះ ។

នៅក្នុងប្រទេសកំពុងអភិវឌ្ឍ កំណើនប្រជាជនដាក់បន្ទុកយ៉ាងធ្ងន់ទៅលើតំបន់ជនបទនិងរំខានដល់ការរីកចម្រើន ។ បណ្ដាប្រទេសទាំងនោះនៅតែអនុវត្តកសិកម្មចិញ្ចឹមពោះដែលពុំទាន់អាចឆ្លើយតបនិងតម្រូវការភាគច្រើននៃប្រជាជនជនបទនៅឡើយ ។ ការវិវត្តផ្ទុយគ្នាបែបនេះ បង្កើតឱ្យមាននានាភាពដ៏ធំធេងនៃពិភពជនបទ ។

មេរៀនទី

# 1 លក្ខណៈសម្គាល់ទូទៅនៃកសិកម្ម

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីប្រភេទកសិកម្ម : កសិកម្មប្រពៃណីនិងកសិកម្មទំនើប
- ❑ បង្ហាញពីការងារចាំបាច់សម្រាប់កសិកម្ម ។

ទោះបីមានការរីកចម្រើនខ្ពស់ផ្នែកបច្ចេកទេសវិទ្យាសាស្ត្រ ពិសេសផ្នែកកសិកម្មយ៉ាងណាក៏ដោយ ក៏កសិកម្មពិភពលោកមិនអាចឈានដល់ភាពទំនើបគ្រប់ទីកន្លែងបានឡើយ ។ ប្រព័ន្ធកសិកម្មប្រពៃណីទ្វីបអាហ្វ្រិកនិងអាស៊ីនៅតែមានអាទិភាពខ្ពស់ដដែល ។ មានតែប្រព័ន្ធកសិកម្មរបស់ប្រទេសលូតលាស់ទេ ដែលទទួលបានកំណែប្រែនិងការវិវត្តឥតឈប់ឈរ ហើយក្លាយទៅជាកសិកម្មទំនើប ។

## 1. ប្រភេទកសិកម្ម

ជាទូទៅ គេអាចបែងចែកកសិកម្មពិភពលោកជាពីរប្រភេទគឺ កសិកម្មប្រពៃណី និងកសិកម្មទំនើបដែលមានភាពផ្ទុយគ្នាយ៉ាងខ្លាំង ។ ជាដំបូង គេឃើញភាពខុសគ្នាខាងប្រព័ន្ធផលិតកម្មឬសំណុំបច្ចេកទេសទាញយកផល មានបម្រើបម្រាស់ដីធ្លី ដី ឧបករណ៍កសិកម្ម កម្លាំងពលកម្មជាដើម ។ ភាពខុសគ្នាខ្លាំងមួយទៀតគឺ ទម្រង់ដីធ្លី និងកម្មសិទ្ធិដីធ្លី (សមូហភាព កម្មសិទ្ធិឯកជនតូចតាច និងកម្មសិទ្ធិឯកជនធំៗ) ។ ជារឿយៗ ដីធ្លីមួយភាគធំមិនមែនជាកម្មសិទ្ធិរបស់អ្នកដាំដុះទេ ។ អ្នកទាំងនោះជាកសិករខ្វះដីដាំដុះ ដូចនេះត្រូវជួលដីគេធ្វើអាជីវកម្ម ឬក៏ត្រូវប្រវាស់ដីគេធ្វើ ដោយត្រូវប្រគល់ផលមួយចំណែកទៅឱ្យម្ចាស់ដី ហើយម្ចាស់ដីក៏បានផ្តល់ប្រាក់មុនមួយចំនួនតាមការព្រមព្រៀងគ្នា ។

លក្ខណៈសម្គាល់ផ្សេងទៀតគឺ ទិន្នផលដែលកសិករទទួលបានក្រោយប្រមូលផល ។

កសិកម្មយថាផលសម្គាល់លើទិន្នផលទាបក្នុងមួយហិចតា ព្រោះមធ្យោបាយប្រើប្រាស់សាមញ្ញតម្រូវការទីដីដាំដុះធំទូលាយ និងការពឹងផ្អែកលើធម្មជាតិ ។

កសិកម្មអតិផល សម្គាល់លើទិន្នផលខ្ពស់តាមធម្មតាលើទីដីដាំដុះមានកំណត់បំផុត ជាមួយការអនុវត្តបច្ចេកទេសជឿនលឿន សម្ភារៈកាន់តែវិសេសឡើងៗនិងទុនវិនិយោគយ៉ាងសំខាន់ ។

អ្វីដែលចាំបាច់សម្រាប់ជីវភាពរស់នៅរបស់មនុស្ស គឺផលិតភាពនៃការងារកសិកម្ម ។ ក្នុងការងារមួយឆ្នាំ កសិករអាហ្វ្រិក ឬអាស៊ីម្នាក់អាចផលិតស្បៀងចិញ្ចឹមមនុស្សត្រឹមតែពីរនាក់ប៉ុណ្ណោះ ហើយស្ត្រីនិងកុមារក៏ធ្វើពលកម្មដែរ ។ ផ្ទុយទៅវិញ កសិករអឺរ៉ុបម្នាក់អាចផលិតស្បៀងជាមធ្យមសម្រាប់ចិញ្ចឹមមនុស្សបានពី 10 នាក់ទៅ 15 នាក់ ហើយកសិករអាមេរិកផលិតក្នុងរយៈពេលតែប៉ុន្មានម៉ោងនៃការងារប្រចាំថ្ងៃ អាចចិញ្ចឹមមនុស្សបានពី 25 ទៅ 30 នាក់ ។

## 1.1. កសិកម្មប្រពៃណី

កសិកម្មប្រពៃណី រួមមានដំណាំពនេចរ ចិញ្ចឹមសត្វពនេចរ ដំណាំត្រូពិចស្ងួត ដំណាំក្នុងអាស៊ីសដំណាំស្រូវនៅអាស៊ីមូសុង និងមានកម្រិតអតិផលកម្មមិនស្មើគ្នា ៖

- ការចិញ្ចឹមសត្វពនេចរ ឬពាក់កណ្ដាលពនេចរ ផ្ដល់ផលតិចតួច អាចចិញ្ចឹមប្រជាជនបានតិចតែអាចប្រព្រឹត្តទៅក្នុងមជ្ឈដ្ឋានពិបាករស់នៅនៃវាលលំហ ឬពាក់កណ្ដាលវាលលំហ ។
- កសិកម្មនិសិទ្ធស្ងួត គឺកសិកម្មមិនផ្លាស់ប្ដូរទីកន្លែង (នៅនឹងមួយកន្លែង) នៅតំបន់ស្ងួតប្រព្រឹត្តទៅតាមចង្វាក់ធម្មតានៃរបបទឹកភ្លៀង ។ គេឃើញមានដំណាំព្រៃដុតនៃតំបន់ព្រៃឈើដែលមានដង់ស៊ីតេប្រជាជនតិចជាង 10 នាក់ /$km^2$ ដំណាំចិញ្ចឹមពោះ ការចិញ្ចឹមសត្វ និងដំណាំជំនួញបន្សល់ទុកដោយពួកអាណានិគម ប្រមូលផ្ដុំប្រជាជនច្រើនជាង 100 នាក់/$km^2$ ។
- ដំណាំបញ្ចូលទឹក មានលក្ខណៈអតិផលខ្លាំង នៅតាមទំនាបនៃតំបន់មេឌីទែរ៉ាណេ នៅអាស៊ីសនៃតំបន់ស្ងួតហែង ។ ជាពិសេសដំណាំស្រូវដែលផ្ដល់ផលច្រើននិងបង្កើតឱ្យមានបណ្ដុំប្រជាជនកុះករនៅតាមជ្រលង ដីសណ្ដ និងទំនាបល្បាប់ ។

## 1.2. កសិកម្មទំនើប

ក្នុងប្រព័ន្ធកសិកម្មទំនើប គេឃើញមានកសិកម្មជំនួញនៃតំបន់ត្រជាក់បង្គួរ ដំណាំចម្ការធំៗនៅតំបន់ត្រូពិច និងកសិកម្មនៅបណ្ដាប្រទេសអឺរ៉ុបខាងកើត និងរុស្ស៊ី ។

- ការវិវត្តសង្គមមនុស្ស បានកែប្រែកសិកម្មប្រពៃណីឱ្យទៅជាកសិកម្មទំនើប តែមិនបានទូទៅគ្រប់ទីកន្លែងនោះទេ ។



ការប្រើប្រាស់គ្រឿងយន្តនៅសហរដ្ឋអាមេរិក

- បដិវត្តន៍ដំណឹកជញ្ជូន ជាកត្តាមួយនៃទំនើបកម្មកសិកម្ម ៖ កសិករក្លាយជាផលិតករ កសិផលលើសតម្រូវការអាចនាំចេញទៅលក់ដូរបានគ្រប់ទិសទី ។
- កំណើនឆាប់រហ័សនៃប្រជាជនពិភពលោក ជាកត្តាសំខាន់មួយទៀតនៃទំនើបកម្ម ។ តែនៅប្រទេសកំពុងអភិវឌ្ឍខ្លះ បាតុភូតនេះ ជាផលនៃកំណែទម្រង់នយោបាយនិងសង្គមមនុស្ស ។

- កសិកម្មទំនើប ជាផលនៃការរីកលូតលាស់ផ្នែកក្សេត្រវិទ្យាដែលបានសិក្សាអំពីដី អាកាសធាតុ ជីគីមី ថ្នាំការពារផលដំណាំ វិធីបង្កាត់ពូជសត្វ និងរុក្ខជាតិ តម្រូវការតាមលក្ខណៈធម្មជាតិនៃតំបន់ ។ វិទ្យាស្ថានស្រាវជ្រាវឯកទេស សម្រេចបានស្នាដៃក្នុងការបង្កាត់ពូជសត្វ និងរុក្ខជាតិ ដូចជា ពូជស្រូវ IR36 ផ្តល់ទិន្នផលខ្ពស់ ពូជគោផ្តល់ទឹកដោះច្រើន ពូជជ្រូកឆាប់ធំ ពូជមាន់ពងច្រើន ... ។
- បន្ថែមពីលើតម្រូវការបង្កើនទិន្នផល គេបានគិតគូរដល់ផលិតភាពការងារ បង្កបង្កើនផលទៀតដោយពឹងផ្អែកទៅលើការរីកចម្រើនផ្នែកបច្ចេកទេស ។ គេបានបង្កើតគ្រឿងយន្តកសិកម្មច្រើនបែបច្រើនយ៉ាងដូចជា ម៉ាស៊ីនភ្ជួរ ម៉ាស៊ីនរាស់ ម៉ាស៊ីនច្រូត ម៉ាស៊ីនបោករហូតដល់ម៉ាស៊ីនចម្រុះច្រូតផង បោកបែនផង និងច្រកដាក់បាវផង ។
- កសិកម្មទំនើប ជាកិច្ចការសេដ្ឋកិច្ចមួយមានទំហំធំធេងណាស់អាចប្រៀបបានទៅនឹងសហគ្រាសឧស្សាហកម្មមួយពិតៗគឺ "កសិ-ឧស្សាហកម្ម" (Agro-industrie) ហើយក៏ជាកិច្ចការជំនួញមួយដែរហៅថា "កសិ-ពាណិជ្ជកម្ម" (Agro-business) ។

## 2. ការងារចាំបាច់នៃកសិកម្ម

ពីមុនមកក៏ដូចបច្ចុប្បន្ននេះដែរ ការងារចាំបាច់នៃកសិកម្មជាសំខាន់មានពីរគឺ ការរុករកដីថ្មីនិងការបង្កើនទិន្នផល ។

### 2.1. ការរុករកដីថ្មី

នៅបណ្តាប្រទេសមួយចំនួនធំដោយសារប្រជាជនមានការហូបចុកខ្វះខាត រដ្ឋាភិបាលប្រទេសទាំងនោះបានលើកគម្រោងផែនការអភិវឌ្ឍជនបទ មានការផ្តល់ដីថ្មីជាដុះដល់ "អ្នកគ្មានដីថ្មី" ដែលជាទូទៅច្រើនតែជាដីព្រៃ ។

នៅប្រទេសប្រេស៊ីល កម្មវិធី "ការអត់ឃ្លានសូន្យ" (Faim Zéro) ឆ្នាំ 2003 របស់រដ្ឋាភិបាលសំដៅកែលម្អលក្ខខណ្ឌជីវភាពប្រជាជនដោយធ្វើកំណែទម្រង់ដីធ្លី ជំរុញកសិកម្មគ្រួសារ ដំណើរការនូវមីក្រូឥណទាន ... ។ នេះជាតុល្យការលើកទីមួយឆ្នាំ 2004 ដែលយើងបានផ្តល់ឥណទានសម្រាប់កសិកម្ម

គ្រួសារអស់យ៉ាងច្រើនដែលមិនធ្លាប់មានពីមុនមក ។ យើងបានសន្យាផ្ដល់ដីជូន "អ្នកគ្មានដីធ្លី" ចំនួន 480 000 គ្រួសាររហូតដល់ដំណាច់អាណត្តិ ធ្វើយ៉ាងណាឱ្យប្រជាជនប្រេស៊ីល ទទួលបានការហូបចុកបីពេលក្នុងមួយថ្ងៃ ។

ចំណែកនៅកម្ពុជាវិញ រាជរដ្ឋាភិបាលតែងមានវិធានការលើកកម្ពស់ផលិតកម្ម កសិកម្មក៏ដូចជាលើកកម្ពស់ជីវភាពប្រជាជនដែរ ដោយការបង្កើនផ្ទៃដីដាំដុះ និងបង្កើនទិន្នផលសំដៅធ្វើឱ្យផលិតផលកសិកម្មកម្ពុជាយើងសម្បូរបែបតាមទិសស្លោក "ភូមិមួយផលិតផលមួយ" ។ ដីព្រៃឈើយើងមួយចំនួនធំ ត្រូវបានប្រែក្លាយទៅជាចម្ការដំណាំផ្សេងៗដូចជា ទឹកដីភាគឦសាន ទឹកដីប៉ៃលិនជាដើម ។

## 2.2. បដិវត្តន៍កសិកម្ម

ការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ ធ្វើឱ្យកសិកម្មមានការវិវត្តយ៉ាងខ្លាំង ។ ជាងកន្លះសតវត្សមកហើយ ដែលកសិកម្មកាន់តែមានលក្ខណៈវិទ្យាសាស្ត្រខ្លាំងឡើងៗ ដូចជា ម៉ាស៊ីនកសិកម្មកាន់តែវិសេសវិសាល ជម្រើសពូជ ឬការបង្កាត់ពូជសត្វ និងរុក្ខជាតិកាន់តែមានប្រសិទ្ធភាព ការអនុវត្តរបកគំហើញគីមីកាន់តែទូលំទូលាយ ហើយកម្រិតជំនាញរបស់កសិករកាន់តែត្រូវបានលើកកម្ពស់ ដែលនាំឱ្យទិន្នផលកសិកម្មកើនឡើងខ្ពស់យ៉ាងពិតប្រាកដ ។

ម្យ៉ាងវិញទៀត គេអាចផលិតដោយមិនចាំបាច់ត្រូវការទីដីធំដុំឡើយ ។ ការចិញ្ចឹមសត្វក្រៅ-ដី (Elevage hors-sol) ដោយដាក់សត្វក្នុងទ្រុង នៅក្នុងអគារ និងផ្ដល់ចំណីចេញពីរោងចក្រ (ជ្រូកនិងបក្សីស្រុកនៅក្រង់ប្រីតាញ) ឬដាក់សត្វក្នុងឧទ្យាន (គោក្មេង ឬជំទង់យកមកពីភូមិភាគខាងលិចសម្រាប់បំប៉នឱ្យធាត់ចំតាមបែបអតិផល ត្រួតពិនិត្យតាមបែបវិទ្យាសាស្ត្រនៅក្នុងរបងបិទជិត) ក្នុងរដ្ឋតិចសាស់នៃសហរដ្ឋអាមេរិក ។ ដំណាំគ្មាន-ដី (Culture Sans-sol) ដូចជាដំណាំផ្កាក្នុងស៊ែ (ផ្ទះកញ្ចក់) នៅលើប៉ុលឌែ ប្រទេសពេអ៊ីបា (ប្រទេសហូឡង់) លក់ចេញពេញពិភពលោក ឬដំណាំប៉េងប៉ោះដោយប្រើសូលុយស្យុងសារធាតុចិញ្ចឹមផ្ដល់ផលពេញមួយឆ្នាំ ។ល ។

## ? សំណួរ

1. តើមានកត្តាសំខាន់អ្វីខ្លះដែលនាំឱ្យកសិកម្មប្រពៃណីក្លាយទៅជាកសិកម្មទំនើប ?
2. តើកសិកម្មប្រពៃណីដែលមានលក្ខណៈអន់ថយជាងគេ គឺជាកសិកម្មប្រភេទណា ? ចូរពន្យល់ ។
3. តើកសិកម្មទំនើបដែលមានលក្ខណៈជឿនលឿនជាងគេ គឺជាកសិកម្មបែបណា ? ចូរពន្យល់ ។
4. តើកសិកម្មមានសារៈសំខាន់សម្រាប់សេដ្ឋកិច្ចដូចម្ដេចខ្លះ ?
5. ចូរពន្យល់ពាក្យ ៖ ដំណាំគ្មាន-ដីនិងចិញ្ចឹមសត្វក្រៅ-ដី ។

មេរៀនទី

# 2 កសិកម្មតំបន់ត្រូពិក

ចប់មេរៀននេះ សិស្សអាច

- ពណ៌នាពីសកម្មភាពកសិកម្មតំបន់ត្រូពិក
- បង្ហាញពីតំបន់ដែលទទួលបានការរីកចម្រើនផ្នែកកសិកម្ម ។

លក្ខខណ្ឌធម្មជាតិតំបន់ត្រូពិក មានអំណោយផលច្រើនចំពោះសកម្មភាពកសិកម្ម ។ តែសង្គមមនុស្សតំបន់នោះមិនទទួលបានការរីកចម្រើនដូចៗគ្នាទេ តំបន់ខ្លះរីកចម្រើនលូតលាស់ខ្លាំង ខ្លះទៀតនៅយឺតយ៉ាវនៅឡើយ ។ ចំណែកប្រព័ន្ធផលិតកម្មកសិកម្ម រួមមានកសិកម្មចិញ្ចឹមពោះ ដំណាំចម្ការធំៗបែបអាណានិគម ដំណាំអតិផលតាមជ្រលងនានាជាដើម ។

## 1. អាកាសធាតុអនុគ្រោះតែដីខាយខ្សោះជីជាតិ

អាកាសធាតុត្រូពិកមានរដូវពីរគឺ រដូវប្រាំងនិងរដូវវស្សាដែលសម្បូរកម្តៅនិងសំណើម ហើយអនុគ្រោះខ្លាំងដល់ដំណុះរុក្ខជាតិ (ព្រៃឈើនិងដំណាំនានា) ។ សណ្ឋានដីតំបន់ត្រូពិក សម្បូរទៅដោយទីដីល្អៗជាច្រើនដែរ ដូចជា ជ្រលងភ្នំ ទំនាបទន្លេ ដីសណ្ត ទំនាបឆ្នេរ ខ្ពង់រាបទាបៗ និងតំបន់កូនភ្នំជាដើម ដែលគ្របដណ្តប់ទៅដោយដីល្បាប់ ដីសិលាក្រែ ដីសិលាបាសាល់ ដីថ្មកំបោរ អាចប្រើប្រាស់បានសម្រាប់អភិវឌ្ឍដំណាំអតិផល ។

ទាំងនេះបង្ហាញថា លក្ខខណ្ឌធម្មជាតិតំបន់ត្រូពិកមានអំណោយផលច្រើនដល់ការងារដាំដុះ ។ ប៉ុន្តែទន្ទឹមនឹងនេះ គេឃើញមានភាពមិនអនុគ្រោះខ្លះដែរដូចជា ភ្លៀងធ្លាក់ខ្លាំងហូរនាំសារធាតុចិញ្ចឹមពីដីទៅអស់ឬធ្វើឱ្យមានសំណឹកដី (ការហូរច្រោះ) កម្តៅខ្លាំងនាំឱ្យមានរំហួតខ្លាំង ហើយពពួកអុកស៊ីតក៏ហើបមកផ្ទៃខាងលើ ធ្វើឱ្យដីដែលគ្មានគម្របរុក្ខជាតិ ក្លាំងរឹងក្លាយទៅជាដីថ្មបាយក្រៀមអស់ជីជាតិមិនអាចដាំដុះបានឡើយ ។

## 2. តំបន់ត្រូពិកខ្លះមានការរីកចម្រើនខ្លាំង

ទោះបីមានការលំបាកខ្លះៗដែលបណ្តាលមកពីធម្មជាតិក្តី គេឃើញប្រទេសមួយចំនួននៅតំបន់ត្រូពិកទទួលបានការរីកលូតលាស់ ប្រជាជនមានជីវភាពរស់នៅសមរម្យ ចាកផុតពីភាពក្រីក្រដែលកំពុងតែញាំញីប្រទេសមួយចំនួនធំក្នុងពិភពលោក ។ គេដាំដុះនៅលើទីដីដែលមានលក្ខណៈអំណោយផលបំផុត ជាមួយនិងការអនុវត្តបច្ចេកទេសកសិកម្មជឿនលឿនផងនោះ ធ្វើឱ្យគេទទួលបានភោគផលយ៉ាងច្រើនដូចជា នៅរដ្ឋផ្លរីត(តំបន់ក្បែរត្រូពិក) និងអូស្រ្តាលីជាដើម ។ នៅទីនោះដំណាំមានលក្ខណៈអតិផល ព្រោះជាតំបន់ដែលស្ថិតនៅក្នុងប្រទេសសេដ្ឋកិច្ចរីកចម្រើនដូចជា ចម្ការក្រូចនៅរដ្ឋផ្លរីត ចម្ការអំពៅនៅអូស្រ្តាលីជាដើម ។

## 3. ដំណាំចម្ការធំៗបែបពាណិជ្ជកម្ម



*ដំណាំចម្ការធំៗ (ដំណាំតែ) នៅអាហ្វ្រិកខាងត្បូង*

នៅបណ្តាប្រទេសត្រូពិកមួយចំនួន ដំណាំប្រភេទនេះ ជាមរតកបន្សល់ទុកដោយពួកនិគមជនអឺរ៉ុបសម្រាប់នាំចេញតាំងពីសតវត្សទី 17 មកម្ល៉េះ ។

លក្ខណៈពិសេសនៃដំណាំចម្ការធំៗដែលជាប្រព័ន្ធផលិតកម្មមាន ៖

- ឯកវប្បកម្មនៃផលិតផលតែមួយមុខសម្រាប់លក់ចេញ ។

- វិនិយោគទុនក្នុងទ្រង់ទ្រាយធំ ។
- ការប្រើប្រាស់ពលករស៊ីប្រាក់ឈ្នួល ។
- ទំនាក់ទំនងជាមួយទីផ្សារក្នុងស្រុកមិនមានឡើយ ។
- បណ្តុំបញ្ឈរខ្លាំងក្លាមានផលិតកម្ម ការទុកដាក់ ការវេចខ្ចប់ និងការធ្វើជំនួញ ដោយផ្អែកលើបណ្តាញដឹកជញ្ជូនញឹក នៅក្នុងតំបន់ព្រៃស្បាតត្រូពិចទាំងនោះ ។

ចំណែកផលិតកម្មមានច្រើនប្រភេទដូចជា គ្រឿងបរិភោគប្រណីត (កាហ្វេ តែ កាកាវ) រូបធាតុដើមសម្រាប់ឧស្សាហកម្ម (កៅស៊ូ ដូងប្រេង...) និងផលិតផលអាហារស្រស់ (ចេក ម្នាស់...) ។

រីឯវិនិយោគទុនបរទេសមានទំនោរទៅរកការកាត់បន្ថយ ហើយត្រូវជំនួសដោយមូលធនរបស់ជាតិនីមួយៗ ។ ប៉ុន្តែថាមភាពនៃដំណាំចម្ការតូចៗរបស់កសិករបានបញ្ជាក់ពីភាពទាក់ទាញនៃមុខដំណាំទាំងនោះ ហើយទទួលបានការលើកទឹកចិត្តពីរដ្ឋថែមទៀតផង ។ នៅអាមេរិកខាងត្បូង ឈូងគីនេនៃទ្វីបអាហ្វ្រិក ឬនៅអាស៊ីអាគ្នេយ៍ ដំណាំចម្ការទាំងនោះ ជាអាជីវកម្មខ្នាតធំមានលក្ខណៈបច្ចេកទេសខ្ពស់ កាន់កាប់ដោយសហគ្រាសពហុជាតិរបស់ប្រទេសលោកខាងជើង ។ ចំណែកផលិតផលវិញសំដៅឆ្ពោះទៅរកតែប្រទេសអ្នកមានប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត ភាពមិននឹងនរនៃតម្លៃលក់ផលិតផលទាំងនោះ គឺជាការចាញ់ប្រៀបមួយសម្រាប់ប្រទេសផលិតករ ។

ចំណែកនៅកម្ពុជាវិញ មរតកនៃដំណាំចម្ការដែលបន្សល់ទុកដោយពួកអាណានិគមបារាំង គឺដំណាំកៅស៊ូនៅខេត្តកំពង់ចាមដែលពូជទាំងនោះត្រូវបាននាំចូលមកពីប្រទេសប្រេស៊ីលកាលពីឆ្នាំ 1920 ។ បច្ចុប្បន្នដំណាំនេះ កំពុងត្រូវបានស្តារឡើងវិញ និងមានដាំដុះបន្ថែមទៀតដោយក្រុមហ៊ុនឯកជន ។ ទន្ទឹមនឹងនេះ ក៏គេឃើញមានដំណាំកៅស៊ូមួយចំនួន ជាអាជីវកម្មបែបគ្រួសាររបស់កសិករយើងផងដែរ ។

## 4. កសិកម្មចិញ្ចឹមពោះ

"គេត្រូវហូបដើម្បីរស់ មិនមែនរស់ដើម្បីហូបនោះទេ" នេះជាសំណេររបស់លោក ព្រីឡាសាវ៉ារីន អ្នកជំនាញខាងម្ហូបអាហារកាលពីឆ្នាំ 1825 ។ ពាក្យពេចន៍នៃសំណេរនេះ បានបង្ហាញច្បាស់ពីមនុស្សម្នាក់ដែលមានការហូបចុកត្រឹមត្រូវ ហើយខ្វល់ខ្វាយតែពីរឿងគុណភាពអាហារតែប៉ុណ្ណោះ ។ សព្វថ្ងៃនេះ មានមនុស្សជាច្រើនលើពិភពលោកកំពុងតែ "រស់ដើម្បីហូប" ពោល គឺបានចំណាយកម្លាំងរបស់ខ្លួន ដើម្បីស្វែងរកចំណីអាហារ ។

## 4.1. កសិកម្មចិញ្ចឹមពោះ

កសិកម្មចិញ្ចឹមពោះ សព្វថ្ងៃនេះអាចចិញ្ចឹមប្រជាជនបានមួយចំនួនធំ ដូចជានៅអាមេរិកឡាទីន អាហ្វ្រិក អាស៊ីខាងត្បូង និងអូសេអានី ។ កសិកម្មប្រភេទនេះតែងរួមបញ្ចូលពហុវប្បកម្មទៅនឹងការចិញ្ចឹមសត្វថែមទៀត ដូចជានៅប្រទេសឥណ្ឌាដែលនិយមហូបតែអាហាររុក្ខជាតិ មិនហូបសាច់ក៏ដោយ ក៏មានការចិញ្ចឹមសត្វសម្រាប់ជាកម្លាំងអូសទាញដែរ ។ ចំណែកបច្ចេកទេសកសិកម្ម នៅមានលក្ខណៈអន់ថយ ហើយពឹងផ្អែកខ្លាំងទៅលើលក្ខខណ្ឌអាកាសធាតុនិងដីដាំដុះ ។

បច្ចុប្បន្នដោយមានការផ្សព្វផ្សាយ និងយល់ដឹងពីបច្ចេកទេសកសិកម្ម ធ្វើឱ្យប្រទេសឥណ្ឌាមិនអាចជួបនឹងគ្រោះអត់ឃ្លានទៀតឡើយ ។



*កសិករនៅភាគខាងជើងប្រេស៊ីលអនុវត្តកសិកម្មចិញ្ចឹមពោះ*

## 4.2. កសិកម្មស្វ័យគ្រប់គ្រាន់

កសិកម្មស្វ័យគ្រប់គ្រាន់នៅអឺរ៉ុបនិងអាមេរិកខាងជើង មានទម្រង់ជាសួនគ្រួសារដែលដាំដុះតែអផ្សុកច្រើនជាងភាពត្រូវការចាំបាច់ ។ ផ្ទុយទៅវិញ នៅទ្វីបអាហ្វ្រិកកសិកម្មប្រភេទនេះបានគ្របដណ្តប់លើផ្ទៃដីមួយដ៏ធំ ។ គេដាំស្រូវមីល ស័រគូ គួបផ្សំជាមួយការដាំដើមឈើផ្សេងៗនិងចិញ្ចឹមសត្វ ។

នៅទ្វីបអាស៊ី ស្រូវជាដំណាំត្រូវពិចសំខាន់ជាងគេ ។ ចំណែកនៅអូសេអានី អាហារចាំបាច់របស់គេមានត្រាវ ដំឡូង និងដូង ។

### 4.3. កសិកម្មព្រៃដុត

កសិកម្មព្រៃដុត ជាកសិកម្មប្រពៃណី និងជាកសិកម្មចិញ្ចឹមពោះដែលមានលក្ខណៈយថាផល បំផុត ។ របៀបធ្វើដំណាំព្រៃដុត ជាដំបូងគឺកាប់ឆ្ការព្រៃ រួចដុត ដើម្បីបានដីសម្រាប់ដាំដុះ ។ ការងារ សំខាន់ៗដែលត្រូវធ្វើ មានការជ្រើសរើសទីព្រៃសម្រាប់កាប់ឆ្ការ ការកំណត់ក្បាលដីឱ្យគ្រួសារនីមួយៗ ហើយគេដុតព្រៃទាំងនោះនៅចុងរដូវប្រាំង និងដាំស្រូវ ឬដំណាំផ្សេងទៀតនៅពេលមានភ្លៀងធ្លាក់ ។ បន្ទាប់មកគេធ្វើរបងចម្ការជាសមូហភាព ។

ពីរ ឬបីឆ្នាំក្រោយមក ពេលដីខ្សោះជីជាតិ គេបានបោះបង់ដីទាំងនោះចោល រួចទៅកាប់ព្រៃកន្លែងថ្មីទៀត ។ ច្រើនឆ្នាំក្រោយមក គេមករានកន្លែងដើមជាថ្មី រួចបោះបង់ចោលម្តងទៀត ។



*ដំណាំព្រៃដុតនៅព្រៃអាម៉ាសូនី (ប្រេស៊ីល)*

ប្រព័ន្ធផលិតកម្មបែបនេះ ធានាបានលំនឹងខ្លះៗ លុះត្រាតែប្រជាជនមានចំនួនតិច ។ ពេលណាចំនួនប្រជាជនកើនឡើង គេត្រូវដាំដំណាំបន្ថែម ហើយផេះដែលជាប្រភពជីជាតិចាំបាច់តែមួយគត់មិនអាចមានគ្រប់គ្រាន់ ដីក្លាយជាហ៊ីរឡើងក្តាំងរឹងប្រើការលែងកើត គឺជាបាតុភូតមួយកំពុងកើតមាននៅតំបន់ត្រូពិក ចាប់ពីពេលដែលប្រជាជនមានកំណើនឆាប់រហ័ស ។ បញ្ហាកាន់តែធ្ងន់ធ្ងរ ពេលដែលគេបន្ថែមដំណាំសម្រាប់នាំចេញទៅលើដំណាំចិញ្ចឹមពោះ ដែលលេបផ្ទៃដីដាំដុះកាន់តែធំឡើងៗ ។ គេឃើញមានកសិកម្មប្រភេទនេះ នៅអាមេរិកឡាទីន អាហ្វ្រិក (លើកលែងតែចម្ការធំៗ) និងតំបន់មួយចំនួនទៀតនៅអាស៊ីដែលមានប្រជាជនរស់នៅតិច ។ ចំណែកនៅកម្ពុជាយើងមានជនជាតិភាគតិចអនុវត្តដំណាំព្រៃដុតនេះដែរ គឺនៅបណ្តាខេត្តភូមិភាគឦសាននិងប៉ែកខាងជើងនៃប្រទេស ។

## 5. កសិកម្មអតិផលនៅតាមជ្រលងក្នុងទ្វីបអាស៊ី

នៅទ្វីបអាស៊ី គេឃើញមានជ្រលងភ្នំ និងជ្រលងទន្លេជាច្រើនដែលជាទីដីទំនាបតូច ធំនានាដ៏សម្បូរជីជាតិដែលអាចឱ្យមនុស្សតាំងលំនៅនិងប្រកបរបរចិញ្ចឹមជីវិតបាន ។ ទំនាបសំខាន់ៗមានទំនាបទន្លេមេគង្គ ទំនាបទន្លេចៅប្រេះយ៉ា ទំនាបទន្លេសាល្វេង ទំនាបទន្លេអ៊ីយ៉ាវ៉ាឌី ទំនាបទន្លេឥណ្ឌុសគង្គា ជាដើម ។ ជ្រលងភ្នំទាំងឡាយនៅប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន និងស្រីលង្កាក៏មានសារៈ

សំខាន់ណាស់ដែរ ។ នៅតំបន់ទាំងនោះ លក្ខខណ្ឌជីវភាពមានភាពងាយស្រួល ប្រជាជនបានមកប្រមូលផ្ដុំគ្នារស់នៅច្រើនកុះករ ។ ប្រជាជនកើនឡើងមិនឈប់ឈរពីមួយឆ្នាំទៅមួយឆ្នាំ ដែលជាហេតុនាំឱ្យខ្វះខាតដីដាំដុះ ។ ក្នុងលក្ខខណ្ឌនេះ តម្រូវការបង្កើនទិន្នផលជាការចាំបាច់ ។

តើគេត្រូវធ្វើដូចម្ដេច ទើបទទួលបានទិន្នផលខ្ពស់ ? គេដាំដុះតាមជ្រលងទន្លេនិងវាលទំនាបល្បាប់ធំៗដែលអាចឱ្យគេទទួលបានទិន្នផលខ្ពស់និងអាចអូសបន្លាយភាពហិរនៃដី ព្រោះទឹកទន្លេបានហូរនាំដីល្បាប់ថ្មីមកបន្ថែមជារៀងរាល់ឆ្នាំដល់ដីលិចទឹកទាំងនោះ ។

ភ្លៀងមូសុងជាអំណោយផលមួយទៀតដល់ការបង្កបង្កើនផលរបស់កសិករអាស៊ី ។ ប៉ុន្តែផលិតកម្មកសិកម្មទាមទារការងារកែលម្អច្រើនទៀត មានការរៀបចំលំហកសិកម្ម ពិសេសការធ្វើទំនប់ការពារទឹកជំនន់ ។

ទឹកជំនន់ជាបញ្ហាមួយដ៏ធ្ងន់ធ្ងរនៅក្នុងតំបន់អាស៊ីដូចជា ប្រទេសបង់ក្លាដែស រាល់ឆ្នាំផ្ទៃដី 20% ទៅ 60% នៃប្រទេសនេះត្រូវរងគ្រោះដោយទឹកជំនន់ បណ្ដាលឱ្យមានមនុស្សស្លាប់និងខូចខាតផលដំណាំយ៉ាងច្រើន ។ ជាទូទៅរៀងរាល់ឆ្នាំនៅកម្ពុជាយើង កសិករតែងជួបនឹងគ្រោះធម្មជាតិពីរ គឺភាពរាំងស្ងួតនិងទឹកជំនន់ ។ ប៉ុន្តែគេអាចកាត់បន្ថយនិងអាចដោះស្រាយបានដោយអនុវត្តនយោបាយទឹក ។

ដោយសារប្រជាជនមានកំណើនយ៉ាងរហ័ស វិធីដាំដុះទាំងនោះគ្មានលទ្ធភាពបង្កើនផលិតផលឱ្យបានគ្រប់គ្រាន់តាមតម្រូវការទេ ។

## ? សំណួរ

1. តើដីតំបន់ត្រូពិកអាចរងការខូចខាតដោយរបៀបណា ?
2. ហេតុអ្វីបានជាតំបន់ត្រូពិចខ្លះទទួលការរីកចម្រើនខ្លាំងខាងកសិកម្ម ?
3. តើដំណាំចម្ការធំៗបែបពាណិជ្ជកម្មមានប្រភពកំណើតដូចម្ដេច ? មានលក្ខណៈសម្គាល់អ្វីខ្លះ ?
4. នៅប្រទេសកម្ពុជាយើងសព្វថ្ងៃមានដំណាំចម្ការបែបជំនួញដែរឬទេ ? មានដំណាំអ្វីខ្លះ ? ស្ថិតនៅខេត្តណា ?
5. ដូចម្ដេចហៅថា "កសិកម្មចិញ្ចឹមពោះ" ? តើកសិកម្មចិញ្ចឹមពោះដែលមានលក្ខណៈយថាផលបំផុតនោះគឺជាកសិកម្មអ្វី ? ចូរបង្ហាញ ។
6. ហេតុអ្វីបានជាកសិកម្មនៅតាមជ្រលងក្នុងទ្វីបអាស៊ីមានលក្ខណៈអតិផល ?

មេរៀនទី

# 3 កសិកម្មប្រទេសឧស្សាហកម្មលូតលាស់

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីកសិកម្មប្រទេសឧស្សាហកម្មលូតលាស់ នៅអឺរ៉ុបនិងសហរដ្ឋអាមេរិក
- ❑ កំណត់បានពីភាពដូចគ្នានិងខុសគ្នា នៃកសិកម្មអឺរ៉ុបនិងសហរដ្ឋអាមេរិក ។

ទេសភាពកសិកម្មនៅប្រទេសឧស្សាហកម្មលូតលាស់មិនដូចគ្នាទេ ហើយកម្រិតជីវភាពកសិករក៏មិនស្មើគ្នាដែរ ។ មជ្ឈដ្ឋានធម្មជាតិ និងទម្រង់សេដ្ឋកិច្ចផ្សេងគ្នា ជាប្រភពនៃភាពខុសគ្នាខាងលក្ខខណ្ឌជីវភាព និងការងារ ។ ប៉ុន្តែទំនើបកម្ម ជាលក្ខណៈរួមនៃកសិកម្មរបស់ប្រទេសអភិវឌ្ឍទាំងនោះដូចជានៅអឺរ៉ុបនិងសហរដ្ឋអាមេរិកជាដើម ។

## 1. កសិកម្មថ្មីនៅអឺរ៉ុប

កសិកម្មអឺរ៉ុប ជាកសិកម្មសម្បូរបែប ។ នានាភាពនៃទេសភាពជនបទបង្ហាញច្បាស់ពីភាពខុសប្លែកគ្នានៃមជ្ឈដ្ឋានធម្មជាតិ និងភាពចំណាស់ក្នុងការកាន់កាប់ដីធ្លី ។

បច្ចុប្បន្ននៅទ្វីបអឺរ៉ុប ទេសភាពដីដាំដុះមួយភាគនៅរក្សាទម្រង់ប្រពៃណីនៅឡើយ ។ តំបន់មេឌីទែរ៉ាណេ ចាប់ពីប្រទេសព័រទុយហ្គាល់រហូតដល់ប្រទេសក្រិច កសិករប្រើប្រាស់ដើមទុនតិចតួចដែលខ្លួនមាន ផលិតបានភោគផលកសិកម្មសម្រាប់តែផ្គត់ផ្គង់គ្រួសារ និងចិញ្ចឹមសត្វ(កសិកម្មចិញ្ចឹមពោះ) ។ ប៉ុន្តែកសិកម្មប្រភេទនេះបានថយចុះ ហើយងាកទៅរកកសិកម្មបែបជំនួញវិញដូចជា ដំណាំទេពប្រទាន ( Huerta ) នៅអេស្ប៉ាញ ដំណាំស្រូវនៅកាម៉ាក (Camargue) និងចម្ការទំពាំងបាយជូរនៅឡង់គីដុក ( Languedoc ) ប្រទេសបារាំងជាដើម ។

នៅក្នុងប្រទេសអឺរ៉ុបមួយចំនួនធំ ការធ្វើសមាហរណកម្មដីធ្លីអនុគ្រោះដល់ការពង្រីកនិងការធ្វើទំនើបកម្មអាជីវកម្ម ។ ចំនួនកសិដ្ឋានកាន់តែថយចុះ ប៉ុន្តែទំហំដីកសិដ្ឋាននីមួយៗកាន់តែរីកធំឡើង ។ ចំនួនកសិករកាន់តែតិចទៅៗ ផលិតភាពការងារកើនឡើងយ៉ាងសម្បើមដោយសារការប្រើប្រាស់ជីនិងថ្នាំការពារដំណាំ ការធ្វើជម្រើសពូជសត្វ និងរុក្ខជាតិ ។

*ឧទាហរណ៍ :* កសិដ្ឋាននៅប្រទេសបារាំង មានទំហំដីមធ្យមលើសពី 25 ហ.ត ។ ចំណែកកសិដ្ឋានអង់គ្លេសមានទំហំដីលើសពី 65 ហ.ត ។ នៅប្រទេសបារាំង កសិដ្ឋានបានធ្លាក់ចុះពី 2.3 លានក្នុងឆ្នាំ 1945 មក នៅត្រឹម 1 លានប៉ុណ្ណោះនៅបច្ចុប្បន្ននេះ ។ កសិករបារាំងមានត្រឹមតែ 1.4 លាននាក់ ត្រូវជា 6% នៃប្រជាជនសកម្មដែលកាលពី 30 ឆ្នាំមុន ដែលមានពីរដងនៃចំនួននេះ ។ ទន្ទឹមនឹងនេះ គេឃើញទេសភាពដីធ្លីមានទម្រង់ដូចៗគ្នាកាន់តែច្រើនឡើងៗ ។ នេះគឺជាការវិវត្តពីស្រែចំណារទៅជាស្រែវាល ហើយកសិកម្មអឺរ៉ុបទទួលបានកំណែប្រែដោយអនុលោមទៅតាមសេដ្ឋកិច្ចទីផ្សារ ។

កសិកម្មអឺរ៉ុបមានលក្ខណៈវិទ្យាសាស្ត្រកាន់តែខ្លាំងឡើងៗដូចជា បម្រើបម្រាស់គ្រឿងយន្ត ជីពូជដែលនាំមកនូវការរីកចម្រើនមួយយ៉ាងសំខាន់ ។ ក្នុងអាជីវកម្មកសិកម្ម គេត្រូវគិតពីភាពអំណោយផលនៃដីនិងតម្រូវការទីផ្សារផងដែរ ។ កត្តាទាំងនេះនាំឱ្យកសិកម្មប្រពៃណីវិវត្តទៅជាដំណាំបែបប្រពលវប្បកម្មនៅជុំវិញទីក្រុង (ដំណាំក្នុងស៊ែ) និងនៅតំបន់មេឌីទែរ៉ាណេដែលផ្តល់ជាពិសេសនូវបន្លែនិងផ្លែឈើនានា ។ ទិន្នផលកើនឡើងគ្រប់ទីកន្លែង ដូចជាមេគោមួយក្បាលផ្តល់ទឹកដោះបាន 3500 លីត្រក្នុងមួយឆ្នាំ ស្រូវសាលីផ្តល់ទិន្នផលបាន 5 តោន/ហ.ត ។ ចំណែកនៅប្រទេសបារាំងវិញ កសិកម្មតាងបានតែ 3% នៃផលិតផលក្នុងស្រុកសរុប ធានារ៉ាប់រងបានដល់ទៅ 12% នៃលំនាំចេញរបស់ប្រទេស អាចឱ្យបារាំងប្រកួតប្រជែងជាមួយសហរដ្ឋអាមេរិកបាន ហើយកសិករបារាំងម្នាក់អាចចិញ្ចឹមមនុស្សបានចំនួន 40 នាក់ ។




*ប្រភេទដំណាំផ្សេងៗនិងប្រព័ន្ធផលិតកម្មកសិកម្មនៅសហភាពអឺរ៉ុប*

បច្ចុប្បន្នដោយសារការបណ្តុះបណ្តាលវិជ្ជាជីវៈមានភាពកាន់តែប្រសើរឡើង កសិករម្នាក់ជាអ្នកក្សេត្រសាស្ត្រផង ពាណិជ្ជករផង និងគណនេយ្យករផង ។ ការប្រើប្រាស់សេវាព័ត៌មានវិទ្យាបានជ្រៀតចូលទៅក្នុងកសិដ្ឋាន ។ ការគាំទ្រខាងដើមទុនជាឱសថលើកកម្លាំងសម្រាប់ធ្វើឱ្យការងារកសិកម្មដំណើរការបានដោយឥតអាក់ ។

## 2. កសិករអឺរ៉ុបខាងលិច

កសិករនៅតាមអាងនៃទីក្រុងឡុង កសិករនៅភាគខាងជើង និងកណ្តាលអាងប៉ារីស កសិករនៅហូឡង់និងដាណឺម៉ាក បានអនុវត្តដំណាំអតិផលនិងចិញ្ចឹមសត្វតាមបែបវិទ្យាសាស្ត្រ ។ ក្នុងគោលបំណងឆ្ពោះទៅរកពាណិជ្ជកម្មមួយប្រសើរជាងមុន កសិកម្មបានឈានទៅដល់ការអនុវត្តបច្ចេកទេសជឿនលឿនដោយប្រើប្រាស់ជីគីមីនិងគ្រឿងយន្តកាន់តែច្រើន ដែលជាហេតុនាំឱ្យកសិករមានបំណុលគួរឱ្យព្រួយបារម្ភ ។ ទោះបី ប្រទេសហូឡង់មានទំហំដីតូចក្តី ក៏នៅឆ្នាំខ្លះប្រទេសនេះបានក្លាយទៅជាអ្នកនាំចេញទី 2 ខាងផលិតផលកសិកម្មនៅលើពិភពលោក ។

នៅគ្រប់តំបន់គ្មានលំហណាមួយដែលមនុស្សត្រូវបោះបង់ចោលនោះទេ ។ មនុស្សរៀបចំស្រែចំការទៅតាមលក្ខណៈអាកាសធាតុ និងសណ្ឋានដី ។ ដោយសារដំណាំធញ្ញជាតិ កសិករបានប្លែងទំនាប និងខ្ពង់រាបអាគីតាំង អាងប៉ារីស បដ ( Borde ) ... ឱ្យទៅជាជង្រុកស្រូវសាលីនៃទ្វីបអឺរ៉ុប ។ កសិករនៅបានចិញ្ចឹមសត្វតាមស្រែចម្ការនៃតំបន់ដែលទទួលឥទ្ធិពលមហាសមុទ្រ ចាប់ពីតំបន់កាលីស ( Galice ) នៅភាគខាងត្បូងទៅតំបន់អេកូស ( Ecosse ) នៅភាគខាងជើង ។ វាលស្មៅដែលច្រើនតែមានទម្រង់ជាស្រែចំណារមានច្រើនលើសលប់ ដូចជានៅអៀឡង់ជាដើម ។

កសិករជាឧស្សាហករនៃដីធ្លី ។ កសិដ្ឋានបានក្លាយជារោងចក្រផលិតគ្រឿងបរិភោគដែលគេហៅថា "កសិ-ឧស្សាហកម្ម" ។ ទិន្នផលកសិកម្មអាចកើនឡើងដល់ 10 តោន/ហ.ត ។ ឯកម្លាំងពលកម្មត្រូវបានកាត់បន្ថយ ។ ដូចគ្នានឹងការដាំដំណាំដែរ ការចិញ្ចឹមសត្វកាន់តែមានភាពប្រសើរឡើង ដោយប្រើជម្រើសពូជ ឬការបង្កាត់ពូជតាមបែបសិប្បនិម្មិត ការត្រួតពិនិត្យសុខភាពសត្វ ការបំប៉នចំណីអាហារ និងការប្រើក្រោលសេរីជាដើម ។ ទ្រុងបសុសត្វទំនើបៗផ្តល់សត្វរាប់ពាន់ក្បាល និងស៊ុតរាប់តោន ។ ទន្ទឹមនឹងនេះ បញ្ហាថ្មីកើតមានជាបន្តបន្ទាប់ ដូចជាកង្វក់ដែលកាន់តែធ្ងន់ធ្ងរ និងវិបត្តិគោឆ្កួតដែលចោទឡើងចំពោះកសិកម្មអតិផលនេះ ។

## 3. កសិករសហរដ្ឋអាមេរិក

កសិកម្មអាមេរិកប្រើប្រាស់អស់ 2.5% នៃប្រជាជនសកម្ម ផ្តល់បរិមាណផលិតផលច្រើនសម្បើម ដែលអាចបំពេញតម្រូវការក្នុងស្រុកនិងផ្គត់ផ្គង់ចរន្តនាំចេញមួយដ៏ខ្លាំងក្លាបាន ។

កសិករអាមេរិកជាអ្នកផលិតស្បៀងអាហារបានច្រើនបំផុតនៅលើពិភពលោក ។ ស្នាដៃវិសេសខ្លះ ជាលទ្ធផលនៃការធ្វើទំនើបកម្មក្នុងអាជីវកម្មធំៗ (កសិដ្ឋានមួយមានដីជាមធ្យម 180 ហ.ត នៅសហភាពអឺរ៉ុបមានត្រឹមតែ 17 ហ.ត) ប្រដាប់ដោយគ្រឿងយន្តនិងធ្វើសមាហរណកម្មជាមួយទីផ្សារក្នុងស្រុកបានយ៉ាងល្អ ។



*កសិដ្ឋានបំប៉នសត្វយកសាច់នៅរដ្ឋតិចសាស់ (សហរដ្ឋអាមេរិក)*

កសិករអាមេរិកមានចំនួនសរុបតិចជាង 2.5 លាននាក់ ទទួលបានការបណ្តុះបណ្តាលល្អលើផ្នែកបច្ចេកទេស ក្សេត្រសាស្ត្រ និងការគ្រប់គ្រង ។

កសិករអាមេរិកម្នាក់អាចចិញ្ចឹមមនុស្សបាន 80 នាក់ ។ ចំណែកនៅរុស្ស៊ីបានត្រឹមតែ 20 នាក់ ។ លទ្ធផលទាំងនេះ បានមកពីការដាំដុះលើផ្ទៃដីតែ 17% នៃផ្ទៃប្រទេសប៉ុណ្ណោះ ស្មើនិង 440 លានហិចតា បែងចែកបានជិតពីរលានកសិដ្ឋាន ។ ផលិតកម្មដំណាំ ( 45% នៃផលទុន)និងសត្វ( 55% )ពឹងផ្អែកលើការស្រាវជ្រាវក្សេត្រសាស្ត្រនិងសត្វសាស្ត្រ ។ ទីដីបញ្ចូលទឹកបានកើនឡើងដល់ 20 លានហិចតា (ឆ្នាំ 1945 មានតែ 6 លានប៉ុណ្ណោះ) ។ សហរដ្ឋអាមេរិកប្រើប្រាស់អស់ 18% នៃគ្រាក់ទ័រក្នុងពិភពលោក ។

បណ្តុំកសិកម្មអាមេរិកមានភាពជឿនលឿនណាស់ ។ កាលពីឆ្នាំ 1950 កសិដ្ឋានទាំងអស់មានចំនួនជាង 5 លាន ហើយកសិដ្ឋាននីមួយៗមានផ្ទៃជាមធ្យមតិចជាង 100 ហ.ត ។ បច្ចុប្បន្នមានជាង 2 លានកសិដ្ឋានដែលជាមធ្យមកសិដ្ឋាននីមួយៗមានផ្ទៃ 200 ហ.ត ។ 7/10 នៃអាជីវកម្មតូចតាចសម្រេចបានក្រោម 40 000 ដុល្លារក្នុងមួយឆ្នាំ ។ វាជាកសិកម្មមួយរបស់កសិករតូចតាចបែបអតិផលនឹងទទួលបានផលគ្រប់គ្រាន់នៅតាមបរិមណ្ឌលក្រុង ឬក៏ជាដំណាំឯកទេសនិងបញ្ចូលទឹកនៅភាគខាងត្បូង ។ ប៉ុន្តែនៅទីដទៃទៀត ដំណាំមានលក្ខណៈជាចន្លោះៗនិងមិនទៀងទាត់ ដូចជាកសិដ្ឋានចំនួនជាង 300 000 អាចឈរជើងបាន តែក្នុងករណីដែលអាជីវករមានផលទុនពីប្រភពផ្សេងទៀត ។

ប្រភេទកណ្តាលមានប្រហែល 250 000 កសិដ្ឋានធ្វើអាជីវកម្មតាមបែបគ្រួសារ ជាទូទៅផ្តល់ផលិតផលច្រើន តែក៏ជំពាក់បំណុលគេជារឿយៗ ។ ជាចុងក្រោយ អាជីវកម្មខ្នាតធំមានចំនួនប្រមាណ 300 000 ជាសហគ្រាសមូលធននិយមប្រកបដោយស្នាដៃខ្ពស់មានទឹកប្រាក់ជំនួញលើសពី 100 000 ដុល្លារក្នុងមួយឆ្នាំ ដែលសុទ្ធតែបានទទួលជំនួយមួយផ្នែកយ៉ាងសំខាន់ពីរដ្ឋសហព័ន្ធ ។

ការបែងចែកភូមិភាគខាងកើតនិងមីតវែស ជាវង់កសិកម្មបានបង្ហាញឱ្យឃើញនូវទិដ្ឋភាពប្លែកៗ ។ ភូមិភាគឦសាននិងតំបន់បឹងធំជាទឹកដីស្រែចំណារសម្រាប់ការចិញ្ចឹមសត្វយកទឹកដោះនិងដំណាំបន្លែ ឈើហូបផ្លែតាមបរិមណ្ឌលក្រុង ។ នៅប៉ែកខាងលិចភាគកណ្តាលមានវង់ស្រូវសាលីនិងវង់ពោតដែលសព្វថ្ងៃគេឃើញមានដំណាំផ្សេងៗទៀតដូចជា សណ្តែកសៀង ស្មៅសត្វ ចិញ្ចឹមសត្វក្រៅដី(គោនិងជ្រូក) ។ នៅភាគខាងត្បូង កប្បាសនិងថ្នាំជក់លែងជាដំណាំផ្តាច់មុខទៀតហើយ ។ ពហុវប្បកម្មរួមជាមួយនឹងការចិញ្ចឹមសត្វ (ពិសេសសត្វស្លាប) ត្រូវបានអនុវត្តនៅក្បែរនោះ ។ ភូមិភាគខាងលិចជាតំបន់ចិញ្ចឹមសត្វបែបយថាផល ការដាំដុះរួមតូចមកនៅត្រឹមវង្វង់ទីដីបញ្ចូលទឹកដូចជា ចម្ការក្រូចនៅជ្រលងអធិរាជ ( Imperial Valley ) និងចម្ការទំពាំងបាយជូរនៅជ្រលងណាប៉ា ( Napa Valley ) រដ្ឋកាលីផរនី ។



*យន្តកម្មកសិកម្មអាមេរិក*

កសិកម្មអាមេរិកបានធ្វើសមាហរណកម្មទៅក្នុងផ្ទៃនៃ "ពហុដ្ឋានកសិ-ឧស្សាហកម្ម" ដ៏សម្បើមមួយ ដោយបានប្រើប្រាស់កម្លាំងពលកម្មអស់ជិត 20% នៃប្រជាជនសកម្ម ។ នេះជាបណ្តុំបញ្ស្សរដ៏ធំ

ខូលាយមួយនៃឧស្សាហកម្មដី ( Industries du Sol ) ដែលនៅផ្នែកលើ ពលករសកម្មចំនួន 6លាននាក់ បំពេញការងារផលិតគ្រឿងយន្ត ជី ចំណីសត្វ ថ្នាំការពារដំណាំ បម្រើការងារខាងបណ្ដល់ហិរញ្ញវត្ថុ និងធានារ៉ាប់រង ។ នៅផ្នែកខាងក្រោម មានពលករជិត ១លាននាក់ បម្រើការខាងការកែច្នៃកសិផល ដំណឹកជញ្ជូន និងការធ្វើពាណិជ្ជកម្មផលិតផលសម្រេច ក្រោមការត្រួតពិនិត្យរបស់សហគ្រាសកសិ-អាហារធំៗ ។

មួយភាគបួននៃផលិតកម្មត្រូវបាននាំចេញ ។ កសិកម្មអាមេរិកពឹងផ្អែកលើទីផ្សារអន្តរជាតិនិងជាពិសេសកសិកម្មនេះងាយប្រែប្រួលផ្លាស់ប្ដូរដែលមួយផ្នែកទាក់ទងទៅនឹងភាពមិនទៀងទាត់នៃអាកាសធាតុនិងមួយផ្នែកទៀតគឺសេចក្ដីសម្រេចចិត្តរបស់នយោបាយរដ្ឋ ។ *ឧទាហរណ៍* ដូចជាសេចក្ដីសម្រេចចិត្តរបស់លោកប្រធានាធិបតី ហាមឃាត់មិនឱ្យនាំចេញជាតិទៅលក់ឱ្យសហភាពសូវៀត ដើម្បីប្រឆាំងទៅនឹងការចូលលុកលុយរបស់សូវៀតលើប្រទេសអាហ្វហ្គានីស្ថាន (1979) ។ ប៉ុន្តែអ្នករងគ្រោះគឺកសិករអាមេរិក ព្រោះថាសហភាពសូវៀតអាចទទួលបានការផ្គត់ផ្គង់ពីទីផ្សារដទៃទៀត ។

## ? សំណួរ

1. តើកសិកម្មអឺរ៉ុបសព្វថ្ងៃទទួលបានកំណែប្រែអ្វីខ្លះ ? ចូរពន្យល់ ។
2. តើកសិករអឺរ៉ុបបានទទួលការបណ្ដុះបណ្ដាលយ៉ាងដូចម្ដេច ?
3. ចូរកំណត់ន័យនៃពាក្យ : ស្រែចំណារ ស្រែវាល កសិ-អាហារ កសិ-ឧស្សាហកម្ម កសិ-ពាណិជ្ជកម្ម ។
4. តើស្នាដៃវិសេសៗក្នុងវិស័យកសិកម្មអាមេរិកបានមកពីអ្វី ?
5. ដូចម្ដេចហៅថា "វង់កសិកម្ម" ? នៅសហរដ្ឋអាមេរិកមានវង់កសិកម្មអ្វីខ្លះ ? បច្ចុប្បន្ននេះតើវង់កសិកម្មទាំងនោះ បានទទួលកំណែប្រែអ្វីខ្លះ ?
6. តើកសិកម្មអឺរ៉ុបនិងកសិកម្មអាមេរិកមានលក្ខណៈដូចគ្នានិងខុសប្លែកគ្នាដូចម្ដេចខ្លះ ?

## ? សំណួរបញ្ចប់ជំពូកទី២

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់មុខចម្លើយត្រូវតែមួយគត់

1. នៅអាស៊ីមូសុង ដំណាំអាហារសំខាន់ជាងគេគឺ

☐ ក. ស្រូវមីល ☐ ខ. ស្រូវសាលី

☐ គ. ស្រូវ ☐ ឃ. ស័រកូ

2. នៅកម្ពុជាយើង ដំណាំចំការធំៗដែលបន្សល់ទុកដោយពួកអាណានិគមបារាំងគឺ

☐ ក. តែ ☐ ខ. កាហ្វេ

☐ គ. កាកាវ ☐ ឃ. កៅស៊ូ

II. ចូរផ្គូផ្គងផ្នែក A និង B រួចភ្ជាប់ចម្លើយត្រូវក្នុងផ្នែក C

| A | B | C (ចម្លើយ) |
|---|---|---|
| 1. កសិកម្មចិញ្ចឹមពោះ<br>2. កសិកម្មជំនួញ<br>3. កសិកម្មពនេចរ | ក. ដំណាំដែលផ្លាស់ប្ដូរទីកន្លែង ។<br>ខ. ដំណាំចម្ការធំៗ (កៅស៊ូ កាហ្វេ តែ អំពៅ ម្នាស់ ...) ។<br>គ. ដំណាំស្រូវនៅអាស៊ីមូសុងឬដំណាំស្រូវមីលនៅអាហ្វ្រិក ។<br>ឃ. ដំណាំស្រូវសាលីនៅអឺរ៉ុបខាងលិច ។ | 1 →<br>2 →<br>3 → |

III. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. កសិកម្មអឺរ៉ុបទទួលបានកំណែប្រែដោយអនុលោមទៅតាម ........................................ ។

2. សំណុំសកម្មភាពរួមមានផលិតកម្ម ការប្លែងភាព និងការជួញដូរគ្រឿងបរិភោគហៅថា .......... ។

IV. សំណួរ

1. ចូរបង្ហាញពីផលិតភាពការងារកសិកម្មរបស់កសិករអឺរ៉ុប អាស៊ី ឬអាហ្វ្រិក រុស្ស៊ីនិងអាមេរិក ។

2. នៅកម្ពុជាយើង តើមានដំណាំចំការធំៗបែបពាណិជ្ជកម្មដែរឬទេ ? ចូរពន្យល់និងបញ្ជាក់ដោយឧទាហរណ៍ ។

3. តើអត្ថិផលកម្មកសិកម្មនៅតាមជ្រលងនៃទ្វីបអាស៊ីផ្អែកលើលទ្ធភាពអ្វីខ្លះ ?

# ជំពូកទី 3 ប្រទេសឧស្សាហកម្មថ្មីនៅអាស៊ីប៉ាស៊ីហ្វិក




*ផែនទីប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក*

"ប្រទេសឧស្សាហកម្មថ្មី" ជាកន្សោមពាក្យមួយ ប្រើសម្រាប់សម្គាល់ប្រទេសលោកខាងត្បូងមួយចំនួនដែលសម្រេចបានខឿនឧស្សាហកម្មរីកចម្រើនប្រាកដប្រជាមួយ ។ ប្រទេសទាំងនោះរួមមាន *កូរ៉េខាងត្បូង តៃវ៉ាន់ ហុងកុង សិង្ហបុរី ប្រេស៊ីល ម៉ិកស៊ិក* និងរួមទាំងចិន *ឥណ្ឌា តួគី ម៉ាឡេស៊ី ឬ ឥណ្ឌូណេស៊ី* ផង ។

ចំណែក "នាគទាំងបួន" ជាកន្សោមពាក្យសម្រាប់សម្គាល់ប្រទេសឧស្សាហកម្មថ្មីនៃអាស៊ីដែលបានរួមចំណែកធ្វើឱ្យឆ្នេរប៉ាស៊ីហ្វិកក្លាយជាតំបន់ទទួលបានចំលែងគួរឱ្យស្ញប់ស្ញែងបំផុត ។ នាគទាំងបួននោះគឺ *កូរ៉េខាងត្បូង តៃវ៉ាន់ ហុងកុង និងសិង្ហបុរី* ។

មេរៀនទី

# 1 ប្រទេសកូរ៉េខាងត្បូង

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីលក្ខខណ្ឌធម្មជាតិ លក្ខខណ្ឌសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសកូរ៉េខាងត្បូង ។

ប្រទេសកូរ៉េមាននេឈ្មោះជាផ្លូវការថា "*សាធារណរដ្ឋកូរ៉េ*" ។ បន្ទាប់ពីការបញ្ចប់សង្គ្រាមលោកលើកទី 2 និងស្ថិតនៅក្រោមកាលៈទេសៈនៃសង្គ្រាមត្រជាក់ ឧបទ្វីបកូរ៉េត្រូវបានបែងចែកជាពីរ ។ នៅឆ្នាំ 1950 ប្រទេសកូរ៉េចាប់ផ្តើមសង្គ្រាមរវាងបងប្អូនឯង(កូរ៉េខាងជើងនិងកូរ៉េខាងត្បូង) ហើយសង្គ្រាមបានបញ្ចប់តាមរយៈកិច្ចព្រមព្រៀងយុទ្ធសន្តិភាពមួយនៅថ្ងៃទី 27 ខែកក្កដា ឆ្នាំ 1953 ។ ចាប់ពីពេលនោះមក ឧបទ្វីបកូរ៉េត្រូវបានបែងចែកជាពីរគឺ កូរ៉េខាងជើងនិងកូរ៉េខាងត្បូង ។

តើប្រទេសនេះមានលក្ខខណ្ឌធម្មជាតិបែបណា ? តើលក្ខខណ្ឌសង្គមមានការវិវត្តដូចម្តេច ? ហើយតើកត្តាសំខាន់នៃការអភិវឌ្ឍសេដ្ឋកិច្ចមានអ្វីខ្លះ ?

## 1. លក្ខខណ្ឌធម្មជាតិ

ប្រទេសនេះស្ថិតនៅភាគខាងត្បូងនៃឧបទ្វីបកូរ៉េ ខាងលិចជាប់សមុទ្រលឿង ខាងកើតជាប់សមុទ្រជប៉ុន(សមុទ្រខាងកើត)ខាងត្បូងជាប់ច្រកកូរ៉េ និងសមុទ្រចិនខាងកើត ។ ប្រទេសកូរ៉េខាងត្បូងមានផ្ទៃដីសរុប 99 678 km$^2$ រួមទាំងកោះប្រហែល 3 000ផង ចែកជាបួនតំបន់គឺ

- តំបន់ភាគខាងកើត សម្បូរជួរភ្នំខ្ពស់និងទំនាបឆ្នេរតូចចង្អៀត
- តំបន់ភាគខាងលិច មានទំនាបឆ្នេរធំទូលាយ អាងទន្លេនិងទីដីរពើតរពើង
- តំបន់ភាគនិរតីជាតំបន់កូនភ្នំ
- តំបន់ភាគអាគ្នេយ៍ ជាអាងទន្លេណាកដុងដ៏ធំទូលាយ ។

និយាយរួមតំបន់ទំនាបទាំងអស់តាងបាន 30%នៃផ្ទៃប្រទេស ។ កំពូលខ្ពស់នៃកូរ៉េខាងត្បូង គឺ *ភ្នំហាឡា* មានកម្ពស់ 1 950m ។

ប្រទេសកូរ៉េមានទន្លេសំខាន់ៗមួយចំនួនដូចជា ទន្លេអាំណុក ទន្លេហាន និងទន្លេណាកដុងដែលហូរចាក់ទៅសមុទ្រខាងលិច ឬ សមុទ្រខាងត្បូង ។ ទន្លេហានមានប្រវែង 514km និងទន្លេណាកដុងប្រវែង 500km ដែលជាទន្លេមានប្រវែងជាងគេមានប្រភពទឹកចេញពីភ្នំតែបែក ហើយហូរចាក់នៅក្នុង

សមុទ្រ ។ ទន្លេ*ហាន*នៅខាងពាយ័ព្យហូរកាត់រដ្ឋធានី*សេអ៊ូល* ចាក់ទៅក្នុងសមុទ្រលឿង ។ ទន្លេ*ណាកដុង* នៅខាងត្បូងហូរចូលច្រកសមុទ្រកូរ៉េត្រង់ *ពូសាន* ដែលកំពង់ផែសំខាន់មួយរបស់កូរ៉េខាងត្បូង ។ *គុម* ជាទន្លេដ៏ធំមួយទៀតហូរកាត់ក្រុង*តេចុន* ប៉ែកខាងលិចនៃភូមិភាគកណ្ដាលចាក់ទៅក្នុងសមុទ្រលឿងដែរ ។ នៅតាមអាងទន្លេទាំងបីនេះមានមនុស្សរស់នៅកុះករនិងជាតំបន់កសិកម្មដ៏ធំធេងទៀតផង ។

កូរ៉េខាងត្បូង មានឆ្នេរទាំងអស់ប្រវែង 2 400km មានលក្ខណៈរនេករឆូច ដាច់ជាកង់ៗ នៅខាងលិចនិងខាងត្បូងបង្កើតបានជាឆកនិងជ្រោយ និងជាទីជម្រកកំពង់ផែធម្មជាតិជាច្រើន ។ ចំណែកកោះទាំង 3 000 ភាគច្រើនកោះតូចៗនិងគ្មានមនុស្សរស់នៅ ភ្ជាប់ពីឆ្នេរភាគខាងលិចមកឆ្នេរភាគខាងកើត ។




*សណ្ឋានដី កូរ៉េខាងត្បូង*

អាកាសធាតុកូរ៉េខាងត្បូងបង្កើតឱ្យមានរដូវបួនច្បាស់លាស់ ។ និទាឃរដូវ និងសរទរដូវមានរយៈពេលខ្លី ។ សិសិររដូវត្រជាក់ មានខ្យល់បក់បោកនិងធ្លាក់ទឹកកក ។ វស្សានរដូវ ក្ដៅ សើម និងមានភ្លៀងធ្លាក់ ។ ធាតុអាកាស តែងទទួលឥទ្ធិពលទ្វីបនិងសមុទ្រនៅជុំវិញ ។ ខ្យល់មូសុងអាស៊ីខាងកើត នាំមកនូវខ្យល់ត្រជាក់ ពីតំបន់អាកទិចនៅសិសិររដូវ និងមូសុងបក់មកពីសមុទ្រចិនខាងត្បូងនៅវស្សានរដូវជាខ្យល់ក្ដៅផ្ទុកដោយចំហាយទឹកច្រើន ។

ជាទូទៅក្នុងខែមករា នៅទីក្រុងសេអ៊ូលសីតុណ្ហភាពស្ថិតនៅចន្លោះពី –7 ទៅ 1°C ហើយក្នុងខែកក្កដា សីតុណ្ហភាពនៅចន្លោះពី 27 ទៅ 29°C ។ ជាធម្មតា កម្រិតទឹកភ្លៀងប្រចាំឆ្នាំនៅសេអ៊ូលមានកម្ពស់ 1 370 mm និងនៅប៊ូសានមានកម្ពស់ 1 470 mm ។ ជាទូទៅ រដូវចាន់ម៉ា ឬ រដូវភ្លៀងមានរយៈកាលប្រហែលមួយខែ គឺចាប់ពីចុងខែមិថុនាដល់ខែកក្កដា ។ ក្នុងគិម្ហន្តរដូវ មានភ្លៀងធ្លាក់រហូតដល់ទៅជាង 50 % នៃកម្រិតទឹកភ្លៀងប្រចាំឆ្នាំដែលមាននៅក្នុងតំបន់ភាគច្រើន ។ ឆ្នេរភាគខាងត្បូងតែងរងគ្រោះដោយខ្យល់ទីផុងវស្សានរដូវ ។

ព្រៃចម្រុះគ្របដណ្តប់អស់ 3/4 នៃផ្ទៃប្រទេស ហើយត្រូវបានកាប់យកមកប្រើប្រាស់ជាអុសដុតនិងសម្ភារៈសំណង់អស់ជាច្រើនសតវត្សមកហើយ ។ ប៉ុន្តែត្រូវបានគេយកចិត្តទុកដាក់ដាំដុះឡើងវិញចាប់តាំងពីឆ្នាំ 1970 ហើយព្រៃឈើដែលនៅសេសសល់ ត្រូវបានដាក់ជាតំបន់ការពារធម្មជាតិ ។ តំបន់ការពារតាងបាន4% នៃផ្ទៃដីថែមទាំងឧទ្យានជាតិចំនួនជាង 12 កន្លែងទៀត ។ ចំណែកសត្វព្រៃ បក្សាបក្សីរបស់ប្រទេសនេះមានច្រើនប្រភេទ ។

ផ្ទុយពីកូរ៉េខាងជើង ប្រទេសកូរ៉េខាងត្បូងជាតំបន់ខ្សត់ធនធានរ៉ែ ។ រ៉ែសំខាន់ៗមាន ធ្យូងថ្ម (ភាគច្រើនជា អង់ត្រាស៊ីត) ដែក និងក្រាភីត ។ រ៉ែផ្សេងៗទៀតមានស័ង្កសី តង់ស្តែន សំណ ទង់ដែង មាស ប្រាក់ និងម៉ូលីបដែន ។ ប៉ុន្តែប្រទេសនេះសម្បូរថ្មកំបោរណាស់ ។

## 2. លក្ខណសង្គម

សង្គមកូរ៉េខាងត្បូង ជាសង្គមថ្មីមួយដែលរដ្ឋប្រើអាជ្ញាក្នុងការដឹកនាំ ហើយសង្គមនោះទៀតសោតកំពុងតែវិវត្តយ៉ាងខ្លាំងក្លា ។

ប្រជាធិបតេយ្យនៅប្រទេសនេះ មានលក្ខណៈប្រហាក់ប្រហែលគ្នានិងប្រជាធិបតេយ្យនៅបណ្តាប្រទេសលោកខាងលិចនិងជប៉ុនដែរ ។ គោលបំណងនៃរបបគ្រប់គ្រងនេះ គឺការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការបង្កើនធនធាន និងអានុភាព ដើម្បីធ្វើឱ្យសុខុមាលភាពប្រជាពលរដ្ឋបានប្រសើរនិងពង្រឹង "ជំហរ" ប្រទេសជាតិលើវេទិកាអន្តរជាតិបានរឹងមាំ ។ ទោះបីជីវភាពនយោបាយមានការលោតផ្លោះដូចម្តេចក្តី ក៏ការគ្រប់គ្រងតែងប្រព្រឹត្តទៅតាមគន្លងទស្សនៈ *ខុងជឺ* ជានិច្ច ។

ចលនាសែម៉ើលអ៊ុនដុងមានន័យថាចលនា "សហគមន៍ថ្មី" ដែលចាប់ផ្តើមឡើងជាមួយនឹងចលនាអភិវឌ្ឍន៍ជនបទ ដោយឈរលើគុណតម្លៃជាមូលដ្ឋានសំខាន់ៗដូចជា ការព្យាយាមរៀសរវៃ ស្វ័យគ្រប់គ្រាន់ និងសហប្រតិបត្តិការ ។ ក្នុងការចាប់ផ្តើមដំបូងរបស់ចលនា "សែម៉ើល" រដ្ឋដើរតួយ៉ាងសំខាន់ក្នុងការបង្កើតមូលដ្ឋានគ្រឹះរបស់ចលនានេះ ។ ដើម្បីបន្តការជំរុញនិងអភិវឌ្ឍចលនាសែម៉ើល រដ្ឋាភិបាលបានបង្វែរចលនានេះឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពលរដ្ឋ នៅក្នុងខែធ្នូ ឆ្នាំ 1980 ហើយទីស្នាក់ការចលនាសែម៉ើលត្រូវបានបង្កើតឡើង ។

គោលការណ៍ជាប្រពៃណីដ៏ចំទូលាយទាំងនោះ ត្រូវបានយកមកអនុវត្តក្នុងសង្គមមួយដែលមានការវិវត្តយ៉ាងរហ័ស ។ ក្នុងឆ្នាំ 1965 មធ្យមភាពនៃអត្រាកំណើតកុមារកូរ៉េ មាន 5.63 ដែលជាអត្រាមួយមានកម្រិតខ្ពស់ជាងមធ្យមភាពនៃអត្រាកំណើតសកល ។ ប៉ុន្តែ ចាប់ពីឆ្នាំ 1990មក អត្រាកំណើតមានកម្រិតមិនដល់ 2.0 ផង ។ យោងតាមស្ថិតិក្នុងឆ្នាំ 2009 មធ្យមភាគនៃអត្រាកំណើតមានកម្រិតប្រហែល 1.15 គឺមិនបានពាក់កណ្តាលនៃកម្រិតមធ្យមភាពនៃអត្រាកំណើតសកលលោកដែលមានកម្រិត 2.65 ហើយអត្រាកំណើតនេះមានកម្រិតទាបបំផុតក្នុងចំណោមប្រជាជាតិនានានៃអង្គការសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) ។

ជាមួយនឹងការលូតលាស់នៃឧស្សាហូបនីយកម្មនិងនគរូបនីយកម្ម ប្រជាកសិករក្នុងពេលបច្ចុប្បន្នមានតិចជាង 10% នៃចំនួនប្រជាជនសរុប ហើយប្រជាជនដែលរស់នៅទីក្រុងមានប្រមាណ 70% នៃចំនួនប្រជាជនសរុប ។

នគរូបនីយកម្មខ្វះការត្រួតពិនិត្យបានចោទជាបញ្ហាយ៉ាងខ្លាំង ហើយក៏មានការរីកលូតលាស់យ៉ាងនាប់រហ័សដែរ ។ ប្រជាជនកូរ៉េខាងត្បូងជិត 7/10ជាអ្នកទីក្រុង ។ រដ្ឋធានី *សេអ៊ូល* ជាប់ចំណាត់ថ្នាក់លេខ 3 ឬ 4ក្នុងពិភពលោក ដែលមានកំណើនមនុស្សចំនួនប្រហែល 300 000 នាក់ក្នុងមួយឆ្នាំៗ ។ នៅភាគខាងត្បូង ពូសាន ជាកំពង់ផែលេខមួយ និងជាទីក្រុងទី 2 នៃប្រទេសមានកំណើនប្រជាជន 200 000 នាក់ជារៀងរាល់ឆ្នាំ ។ រីឯទីក្រុងដទៃទៀត ក៏ទទួលបានការរីកចម្រើនដែរ ដូចជាក្រុង *អ៊ុលសាន* ជាឧទាហរណ៍ ។ នគរូបនីយកម្មបែបនេះ តម្រូវឱ្យមាននយោបាយសាងសង់លំនៅស្ថានលក់ជូនប្រជាជនក្រុងថ្មី ដែលកើនឥតឈប់ឈរដោយតម្លៃថោក តែមិនអាចបានគ្រប់គ្រាន់ឡើយ ។

ក្រោមឥទ្ធិពលនៃកំណើនសេដ្ឋកិច្ច និងសម្ពាធនៃការទាមទារប្រាក់បៀវត្សមានការកើនឡើងគួរឱ្យកត់សម្គាល់ កូរ៉េខាងត្បូងពុំមែនជាប្រទេសដែលពលករស៊ីថ្លៃថោកនោះទេ ។ ជាវិបាក កម្រិតជីវភាពប្រជាជនត្រូវបានលើកតម្កើងដូចគ្នានឹងនៅប្រទេសជប៉ុនដែរ ។ ក្រោយភាពក្រីក្រអស់រាប់សតវត្សមក សង្គមកូរ៉េបានឈានចូលទៅក្នុងសម័យកាលបម្រើបម្រាស់ដោយក្តីប្រាថ្នាខ្ពស់ ។

# 3. សេដ្ឋកិច្ចថ្មីមួយ

## 3.1. មាគ៌ាអភិវឌ្ឍន៍តាមបែបកូរ៉េខាងត្បូង

ប្រទេសនេះ បានកសាងកិច្ចអភិវឌ្ឍន៍ដោយផ្អែកលើកត្តាសំខាន់ៗបួន :

ភាពសម្បូរក្រុមហត្ថពលករនៅវ័យក្មេង : ប្រកបដោយជំនាញ បំពេញការងារបានល្អ និងព្រមទទួលយកប្រាក់ខែទាប ម៉ោងការងារច្រើន ។

រដ្ឋអំណាចមួយដែលមាននៅគ្រប់កន្លែង : នៅបណ្តាប្រទេសមូលធននិយម ជាការពិត ផែនការកម្មមានលក្ខណៈប្រិតប្រៀនបំផុត ហើយការបង្កើតសហគ្រាសសាធារណៈបានដាក់ឱ្យដំណើរការរោងចក្រធំៗ ។ រដ្ឋាភិបាល តែងកំណត់ផ្នែកដែលមានអាទិភាពនិងគោលដៅម៉ាក្រូសេដ្ឋកិច្ច ហើយបង្កើតឱ្យមានអាជ្ញាធរមួយចំនួនបង្កើតឡើងដោយរដ្ឋនៅពីលើធនាគារ ។

ការផ្ដល់ហិរញ្ញវត្ថុមួយដ៏ចម្លែក ៖ មែនហើយ 30% នៃវិនិយោគសរុបកាលពីមុនឆ្នាំ 1965 ត្រូវបានផ្ដល់ហិរញ្ញវត្ថុដោយសហរដ្ឋអាមេរិក ជាបន្តបន្ទាប់មកទៀតដោយកិច្ចព្រមព្រៀងជាមួយជប៉ុន ឬប្រទេសផ្សេងៗទៀត ដែលប្រាក់កម្ចីត្រូវបានទទួល ។ សហគ្រាសរួម (មូលធនជាតិនិងបរទេសរួមគ្នា) របស់សហរដ្ឋ ឬជប៉ុនមានដល់ទៅ 4/5 តាងបាន 15% នៃវិនិយោគសរុបក្នុងឧស្សាហកម្មគីមីនិងអេឡិចត្រូនិច ។

ទម្ងន់នៃកុងគ្លូមេរ៉ា ៖ កិច្ចសហប្រតិបត្តិការនានា សម្រាប់លំនាំចេញចាប់ពីឆ្នាំ 1962 មក បានជំរុញឱ្យរដ្ឋជួយសម្រួលដល់បណ្ដុំឧស្សាហកម្មធុនធ្ងន់ ។ ពហុដ្ឋាន **ប៉ូហាង** ត្រូវបានដាក់ឱ្យដំណើរការនៅឆ្នាំ 1970 បន្ទាប់មក មានពហុដ្ឋាន **ក្វាងយ៉ាង អ៊ុលសាន យេវចុង** ... ។

ក្រុមហ៊ុនពលករជាង 50% ធ្វើការនៅក្នុងសហគ្រាសតូចៗនិងមធ្យម (95% នៃសហគ្រាស) ប៉ុន្តែក្រុមសហគ្រាសធំៗចំនួន 50 ដែលមាន 9 ជាសហគ្រាសយក្សធំសម្បើម ផលិតបាន 73% នៃផលិតផល និងត្រួតពិនិត្យបាន 60% នៃលំនាំចេញ ។

ភាពជោគជ័យនៃនយោបាយនេះ ធ្វើឱ្យមានកំណើនឡើងយ៉ាងឆាប់រហ័សនៃផលិតផលជាតិសរុបដែលកាលពីឆ្នាំ 1970 មាន 8 ពាន់លានដុល្លារ ឆ្នាំ 1980 មាន 56 ពាន់លានដុល្លារ ឆ្នាំ 1988 ឡើងដល់ 150 ពាន់លានដុល្លារ និងសព្វថ្ងៃ 970 ពាន់លានដុល្លារ គឺត្រូវជា 20 045 ដុល្លារម្នាក់ក្នុងមួយឆ្នាំ (2007) ។

## 3.2. សេដ្ឋកិច្ចមួយស្រួចស្រាល់




*ហេដ្ឋារចនាសម្ព័ន្ធនិងនានាភាពឧស្សាហកម្ម*




*ផែនទីកសិកម្ម កូរ៉េខាងត្បូង*

ទោះបីជាលក្ខខណ្ឌធម្មជាតិមិនសូវអនុគ្រោះក៏ដោយ ក៏កសិកម្មនេះអាចបំពេញតម្រូវការបានគ្រប់គ្រាន់ខាងស្រូវនិងធញ្ញជាតិបន្ទាប់បន្សំផ្សេងៗទៀត ។ ការនេសាទប្រព្រឹត្តទៅក្នុងដែនសមុទ្រអន្តរជាតិ ហើយវារីវប្បកម្មរីកចម្រើនយ៉ាងឆាប់រហ័ស ។

ឧស្សាហកម្មមួយមានបីដំណាក់កាល : រហូតមកដល់ឆ្នាំ 1970 គេផលិតជាពិសេស តែគ្រឿងសម្ភារៈប្រើប្រាស់ វាយនភ័ណ្ឌ ស៊ីម៉ងត៍ ជី អាហារកំប៉ុង... ។ ចាប់ពីគម្រោងផែនការទីបី (ឆ្នាំ 1972) គេបានអភិវឌ្ឍគីមី ប្រេងកាត ដែកថែប គ្រឿងយន្ត និងនាវា ដែលជារបស់ក្រុមហ៊ុនធំៗបួនគឺ ហ៊ីយុនដៃ ដេវូ សាំសុង និង ហានជីន ។ ឧស្សាហកម្មដែក មានច្រើនលើសលប់នៅ ប៉ូស្កូ គីមីប្រេងកាតនៅ អ៊ុលសាន និងយេវចុង ដែលផ្តល់ផលិតផលនាំចេញបាន 55% ។

ទោះបីថាមពលសំខាន់ៗបានមកពីធ្យូងថ្មក្នុងស្រុកនិងប្រេងកាតនាំចូលក៏ដោយ ក៏សាធារណរដ្ឋកូរ៉េមានរោងចក្រដើរដោយថាមពលនុយក្លេអ៊ែចំនួន 20 ដែលផ្តល់អគ្គិសនីបាន 50% នៅឆ្នាំ 2006 ។

នៅចុងក្រោយឆ្នាំ 1980 ផលិតផលបច្ចេកវិទ្យាខ្ពស់ (អេឡិចត្រូនិច ជីវតិចណូឡូស៊ី ឧបករណ៍ភ្លេង)ក៏ដូចជារថយន្តដែរ ទទួលបានការរីកចម្រើនដោយកិច្ចព្រមព្រៀងនៃសហប្រតិបត្តិការជាមួយបរទេស និងក្នុងក្របខ័ណ្ឌនៃ កុងគ្លូមេរ៉ា ។ សាំសុង និងហ៊ីយុនដៃ មានសាខារបស់ខ្លួននៅស៊ីលីខុនវ៉ាលេ (កាលីផរនីសហរដ្ឋអាមេរិក) ។

ក្នុងឆ្នាំ 1960 ប្រទេសកូរ៉េមានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ក្រោមការដឹកនាំដោយនៃគោលនយោបាយកំណែទម្រង់និងអភិវឌ្ឍន៍សេដ្ឋកិច្ចជោគជ័យដ៏របស់រដ្ឋាភិបាល ។

ក្នុងឆ្នាំ 1970 កំណើនឧស្សាហកម្មគីមីចុនធុន់ បានធ្វើឱ្យប្រទេសកូរ៉េមានការអភិវឌ្ឍនិងក្លាយជាប្រជាជាតិឧស្សាហកម្មលេចធ្លោមួយ ។ ការអភិវឌ្ឍសេដ្ឋកិច្ចដ៏គួរឱ្យភ្ញាក់ផ្អើលនេះបានបន្តរហូតមកដល់ក្រោយឆ្នាំ 1980 ។ ការអភិវឌ្ឍនេះ បានលើកកម្ពស់ឋានៈប្រទេសកូរ៉េបន្តទៅទៀត រហូតដល់ក្លាយជាប្រជាជាតិមួយដែលមានសេដ្ឋកិច្ចរឹងមាំ ។ បច្ចុប្បន្ននេះ កូរ៉េជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានទីផ្សារប្រកួតប្រជែងរឹងមាំក្នុងទីផ្សារពិភពលោក ។ ហើយប្រទេសស្ថិតក្នុងស្ថានភាពប្រកួតប្រជែងពីប្រទេសឧស្សាហកម្មដទៃទៀត ដូចជាជប៉ុនដែរ ។

## ? សំណួរ

1. តើកូរ៉េខាងត្បូងមានលក្ខខណ្ឌធម្មជាតិអនុគ្រោះដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិដែរឬទេ? ចូរពន្យល់ ។
2. ចូរប្រៀបធៀបលក្ខខណ្ឌធម្មជាតិកូរ៉េខាងត្បូងនិងកម្ពុជា ។
3. តើរបបគ្រប់គ្រងនយោបាយរបស់កូរ៉េខាងត្បូងមានលក្ខណៈដូចម្តេចខ្លះ ?
4. ដូចម្តេចហៅថា "សេម៉ូល" ?
5. តើមាគ៌ាអភិវឌ្ឍន៍បែបកូរ៉េខាងត្បូង ផ្អែកលើកត្តាអ្វីខ្លះ ?
6. តើដំណើរការអភិវឌ្ឍឧស្សាហកម្មកូរ៉េខាងត្បូងប្រព្រឹត្តទៅដូចម្តេច ?

មេរៀនទី

# 2 កោះតៃវ៉ាន់

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាបានពីលក្ខខណ្ឌធម្មជាតិ លក្ខខណ្ឌសង្គម និងសេដ្ឋកិច្ចកោះតៃវ៉ាន់ ។

តៃវ៉ាន់ ជាកោះមួយនៅឯនាយឆ្នេរសមុទ្រចិន ជារដ្ឋមួយឈ្មោះថា ចិនជាតិនិយម មិនមែនជាសមាជិកអង្គការសហប្រជាជាតិទេ និងមិនត្រូវទទួលស្គាល់ជាផ្លូវការដោយប្រទេសជាច្រើនក្នុងពិភពលោក ។ ចំណែកចិនដីគោកបានប្រកាសថា តៃវ៉ាន់ជាខេត្តមួយរបស់ចិន ។ ទោះបី មិនមានការទទួលស្គាល់ដូច្នេះក៏ដោយ ក៏តៃវ៉ាន់ជាទឹកដីមួយដ៏សំខាន់ ដោយសារអានុភាពសេដ្ឋកិច្ច និងតួនាទីរបស់ខ្លួននៅអាស៊ីបូព៌ាដែរ ។

## 1. លក្ខខណ្ឌធម្មជាតិ

កោះតៃវ៉ាន់ មានផ្ទៃដីប្រមាណ 36 000km$^2$ មានរាងពងក្រពើ សណ្ឋិតតាមទិសជើង-ត្បូង លើបណ្ដោយ 400km និងទទឹងធំបំផុត 120km ជាទឹកដីប្រកបទៅដោយទេសភាពប្លែកៗ ទាំងសណ្ឋានដី ទាំងអាកាសធាតុ រុក្ខជាតិ និងសត្វ ។

ប៉ែកខាងកើត គ្របដណ្ដប់ដោយជួរភ្នំបួនស្របគ្នា សណ្ឋិតតាមទិសជើង-ត្បូង ។ ជួរភ្នំខ្ពស់ជាងគេ មានកម្ពស់ខ្ពស់ជាង 3 500m ស្ថិតនៅខាងកើត ។ កំពូលភ្នំខ្ពស់ គឺភ្នំយូសាន(3 997m) ។ ជួរភ្នំទាំងនោះ ដាច់ចេញពីគ្នាដោយអាងសម្រុត ។ នៅប៉ែកខាងជើង គេឃើញមានភ្នំភ្លើង តែគ្មានមួយណាមានសកម្មភាពថ្មីៗកើតឡើងនោះទេ ។ ប៉ុន្តែជាតំបន់អស្ថិរភាព ហើយរញ្ជួយដីតែងកើតមានជាញឹកញាប់ ។ ប៉ែកខាងលិចបន្ទាប់ពីភ្នំ មានកូនភ្នំ រួចមកមានទំនាបឆ្នេរទាបតូចចង្អៀត ។ ជារួម ទាំងតំបន់កូនភ្នំ (100-500m) ទាំងទំនាបដែលមានរយៈកម្ពស់ទាបជាង 100m តាងបានផ្ទៃដីជិតពាក់កណ្ដាលនៃផ្ទៃដីសរុប ។

កោះតៃវ៉ាន់ មានអាកាសធាតុមិនដូចគ្នាទេ ។ កោះនេះ ស្ថិតនៅក្រោមខ្សែត្រូពិចខាងជើងនិងក្រោមឥទ្ធិពលខ្យល់មូសុង ។ ជាទូទៅ មានអាកាសធាតុក្ដៅហើយសើម ។ ប៉ែកអាគ្នេយ៍ មានភ្លៀង

ធ្លាក់រវាងខែឧសភានិងខែកញ្ញា (មូសុងអាស៊ី) ចំណែកប៉ែកខាងជើងនិងឆ្នេរខាងកើត មានភ្លៀងធ្លាក់ពីខែតុលាទៅខែមករា ។ ព្យុះទីផុង ដែលបក់បោកមកពីមហាសមុទ្រប៉ាស៊ីហ្វិក ជាពិសេស នៅដំណាច់វស្សានរដូវ ប៉ះពាល់ដល់ឆ្នេរខាងកើតយ៉ាងញឹកញាប់ ទោះបីពេលខ្លះ អាចទៅដល់កន្លែងខ្លះទៀតក៏ដោយ ក៏វាបានបង្កនូវមហន្តរាយយ៉ាងធំធេងដែរ ។

សីតុណ្ហភាពខ្ពស់នៅតំបន់ទំនាប (ខ្ពស់ជាង 22°C ជាមធ្យមនៅប៉ែកខាងជើងនិងជិត 25°C នៅប៉ែកខាងត្បូង) តែបានធូរស្រាលនៅទីខ្ពស់ ដែលបណ្ដាលឱ្យមានថ្នាក់រុក្ខជាតិ ។ តំបន់ទាបដែលមានរយៈកម្ពស់ក្រោម 500m ត្រូវបានកាប់ឆ្ការនិងអាចធ្វើស្រែបានបីដងក្នុងមួយឆ្នាំ ។ គេនៅសង្កេតឃើញមានព្រៃត្រូពិចសើមពណ៌បៃតងជានិច្ចខ្លះៗនៅឡើយ ។ ព្រៃចម្រុះ ឈើសម្បុរស្លឹកនិងដើមស្រល់ដុះជាថ្នាក់ៗ ត្រង់រយៈកម្ពស់ 1 800 និង 2 500m ។

តៃវ៉ាន់ មានធនធានធម្មជាតិសំខាន់ៗដូចជា កំណាប់រ៉ែមាសនិងទង់ដែង នៅជួរភ្នំឈុនយ៉ាងនិងជួរភ្នំឆ្នេរខាងកើត ។ ធ្យូងថ្ម នៅប៉ែកខាងកើតក្បែរទន្លេតាខូ ។ ប្រេងកាតនិងឧស្ម័នធម្មជាតិ មាននៅប៉ែកពាយ័ព្យ ។ ក្រៅពីនេះ គេឃើញមានថ្មម៉ាប ថ្ម គ្រួស ខ្សាច់ សម្រាប់ឧស្សាហកម្មសំណង់ ។




*ផែនទី កោះតៃវ៉ាន់*

## 2. លក្ខខណ្ឌសង្គម

ប្រជាជនតៃវ៉ាន់មានប្រមាណ 22.6 លាននាក់ (2003) និងនៅឆ្នាំ 2007 មានចំនួន 23 174 294 នាក់ ដែលមានជាច្រើនស្រទាប់ ជាប់ទាក់ទិនទៅនឹងវគ្គបន្តបន្ទាប់នៃដំណុះប្រជាជន ។ គេឃើញមានអ្នកសន្តានក្រោយនៃជនជាតិដើមនៅលើកោះប្រហែល 300 000 នាក់នៅឡើយ ដែលតាមរយៈភាសា និងវប្បធម៌ មានពន្ធភាព (ភាពស្រដៀងគ្នា) ជាមួយប្រជាជនភាគនិរតីប៉ាស៊ីហ្វិក ។ ក្រុមជនទាំងនោះស្ថិតក្នុងអំបូរ "ម៉ាឡាយូ-មេឡានេស៊ី" ឬ "អូស្ត្រូនេស៊ី"ផងដែរ និងមានឈ្មោះថា "កាវសាន" មានន័យថា "អ្នកភ្នំខ្ពស់ៗ" ប្រកបរបរកសិកម្មយថាផល ទោះបីបច្ចុប្បន្ននេះ បានបង្ហាញឱ្យឃើញថា មានសញ្ញានៃការវិវត្តយ៉ាងច្បាស់ណាស់ក៏ដោយ ។



*ក្រុងតៃប៉ិ*

គេមានឈ្មោះថា ជនជាតិតៃវ៉ាន់ គឺពួកអ្នកសន្តានក្រោយនៃជនចំណូលស្រុក ភាគច្រើនមកពីបណ្តាខេត្តប៉ែកអាគ្នេយ៍ប្រទេសចិន ពិសេសមកពីខេត្ត ភូជាន ជិតខាង ។ ក្នុងបណ្តាក្រុមជនទាំងនោះពួក ហាក់កា ជាជនជាតិភាគតិចដែលមានដើមកំណើតមកពីចិនភាគខាងជើង ហើយតាំងទីរស់នៅតាំងពីច្រើនសតវត្សមកហើយនៅភាគខាងត្បូងកោះ ប៉ុន្តែបានរក្សាអត្តសញ្ញាណវប្បធម៌របស់ខ្លួននៅឡើយ ។ ពួកហាក់កា មានប្រហែល 10% នៃប្រជាជនសរុប ។



បោះពុម្ពផ្សាយ ឆ្នាំ ២០១៨ PDH

ស្រទាប់ទីបីគឺ ពួកចិនជាតិនិយម ប្រមាណ 3 លាននាក់ ដែលភៀសខ្លួនមកកោះតៃវ៉ាន់ កាលពីឆ្នាំ 1949 ។ ពួកមកដល់ថ្មីៗទាំងនោះ និយាយភាសាម៉ង់ដារាំងនិងកាន់កាប់តួនាទីយ៉ាងសំខាន់ផ្នែកនយោបាយនិងរដ្ឋបាល ។

វគ្គជាបន្តបន្ទាប់មកទៀតនៃចំណូលស្រុកមកកាន់ដីកោះ នាំមកនូវកំណើនប្រជាជនយ៉ាងសំខាន់មួយ ក្នុងអត្រាមួយខ្ពស់នៅឡើយ (0.9% ក្នុងមួយឆ្នាំ) ទោះបីជាលទ្ធភាពបង្កកំណើតបានថយចុះមកនៅត្រឹម 1.4 សម្រាប់ស្ត្រីម្នាក់ក៏ដោយ គឺអត្រាជាតិប្រមាណខ្ពស់ (1.2%) ដោយសារទម្រង់ក្មេងនៃប្រជាជននិងអត្រាមរណប្រមាណទាប (0.6%) ។ ដង់ស៊ីតេប្រជាជននៃកោះតៃវ៉ាន់ គិតជាមធ្យមមាន 833 នាក់/$km^2$ បង្ហាញពីសម្ពាធប្រជាសាស្ត្រមួយដែលកាន់តែមានលក្ខណៈខ្លាំងក្លាបើនិយាយពីប្រជាជនរស់នៅតំបន់ក្រៅពីប្រជុំភ្នំ លើផ្ទៃដីតិចជាងពាក់កណ្តាលនៃផ្ទៃកោះសរុប ។ តៃវ៉ាន់ មានប្រជាជនក្រុងច្រើន ។ ទីក្រុងប្រមាណសែសិបមានប្រជាជនលើសពី 100 000 នាក់និងទីក្រុងចំនួនប្រាំមានប្រជាជនលើស 500 000 នាក់ ។ តៃប៉ិ ជារដ្ឋធានី (ដែលបណ្តុំក្រុងមានប្រជាជន 8 លាននាក់) នៅប៉ែកខាងជើង និងកៅស៊ីយ៉ុងនៅប៉ែកខាងត្បូង ជាចំណុចខ្លាំងខាងរបាយក្រុងញឹកនិងស្មើល្អ ដែលបានរចនាលំហទំនាបខាងលិច ។ ក្រៅពីនេះ គេមិនឃើញមានអ្វីក្រៅពីកំពង់ផែ ហ៊្វលាន នៅលើឆ្នេរខាងកើតឡើយ ។

## 3. លក្ខខណ្ឌសេដ្ឋកិច្ច

ដោយសារសំទុះឧស្សាហកម្ម តៃវ៉ាន់បានក្លាយទៅជាប្រជាជាតិមួយដែលមានកម្រិតជីវភាពខ្ពស់ គឺស្មើប្រាំដងនៃជីវភាពជនជាតិចិនដីគោក ។

### 3.1. មាគ៌ាអភិវឌ្ឍន៍តាមបែបតៃវ៉ាន់

មាគ៌ាអភិវឌ្ឍន៍តាមបែបតៃវ៉ាន់មិនដូចគ្នានិងប្រទេសចិនប្រជាមានិតទេ ។ រដ្ឋាភិបាលក្មួមីងតាងរបស់លោក **ចាង ខាយចៀក** ដែលបរាជ័យក្នុងចម្បាំងនិងត្រូវនិរទេសដោយបង្ខំ បានសាងសេដ្ឋកិច្ចផ្អែកលើការចូលជ្រៅទៅក្នុងទីផ្សារពិភពលោក ក្រោមកិច្ចការពារពីកងនាវាទី 7 របស់សហរដ្ឋអាមេរិករហូតដល់ឆ្នាំ 1971 ។ ផ្តើមចេញពីបាតដៃទទេ សេដ្ឋកិច្ចតៃវ៉ាន់ បានប្រើប្រាស់នូវអ្វីដែលខ្លួនមាន គឺកម្លាំងពលកម្មដ៏ថ្លៃថ្លារបស់ប្រជាជន ។ ឧស្សាហកម្មហត្ថពលករ ជាពិសេសវាយនភ័ណ្ឌនិងអេឡិចត្រូនិក ជាមូលដ្ឋាននៃជោគជ័យរបស់តៃវ៉ាន់ ។ ពេលមួយ តៃវ៉ាន់ក៏បានក្លាយទៅជាអាណាចក្រនៃការដំឡើងគ្រឿងសម្ភារៈ ។ សម័យកាលនោះមានឈ្មោះថា **អព្ភូតហេតុសេដ្ឋកិច្ច**(1960-1970) ។ គំរូអភិវឌ្ឍន៍បែបនេះ ត្រូវបានអនុវត្តតាមប្រកបដោយជោគជ័យ ជាក់ស្តែង ដោយប្រទេសដទៃទៀតនៃអាស៊ីអាគ្នេយ៍ ។ អ្វីដែលជារឿងចម្លែកថ្មីគឺ គេឃើញសាធារណរដ្ឋប្រជាមានិតចិន បានដើរតាមមាគ៌ាអភិវឌ្ឍន៍បែបនេះដែរ កាលពីឆ្នាំ 1984 ។

## 3.2. ការវិវត្តនៃមាគ៌ាអភិវឌ្ឍន៍

ប៉ុន្តែបច្ចុប្បន្ននេះ ជាការត្រឹមត្រូវបំផុតនោះ គឺតៃវ៉ាន់បានបោះបង់ចោលគំរូអភិវឌ្ឍន៍ដែលខ្លួនធ្លាប់ប្រកាន់យកស្ទើរតែទាំងស្រុង ដោយសារជោគជ័យដែលទទួលបាន តម្រូវឱ្យមានវិវត្តដូចនេះ ។

ក្រោយពេលឈានចូលក្នុងក្រុមប្រទេសអ្នកមាន តៃវ៉ាន់អាចតាំងទីរោងចក្រនៅប្រទេសចិនប្រជាមានិត តាំងពីឆ្នាំ 1987 ដោយក្ដីសប្បាយរីករាយ ក្នុងនាមជាជនជាតិចិន ដែលធ្លាប់បាក់មុខបាក់មាត់ ។ វាគឺជាពេលវេលាមួយសម្រាប់ផលិតកម្មដ៏ច្រើនដោយតម្លៃទាប ។ ការរួមបញ្ចូលគ្នាដ៏ចម្លែកមួយរវាងការជំរុញរបស់រដ្ឋាភិបាលទៅនឹងថាមភាពឯកជន បានធ្វើឱ្យតៃវ៉ាន់ស្ថិតនៅក្នុងរបៀបបង្កើតថ្មី និងភាពម្ចាស់ការលើបច្ចេកវិទ្យាជឿនលឿនបាន ។

## 3.3. តៃវ៉ាន់ផលិតកុំព្យូទ័របានច្រើនជាងជប៉ុន



*រោងចក្រសម្ភារៈអេឡិចត្រូនិក*

នេះជាការកត់សម្គាល់យ៉ាងស្ងប់ស្ងៀមរបស់ លោក គួ យន់ (Kuo Yun) នាយកវិទ្យាស្ថានឧស្សាហកម្មព័ត៌មាន ។ ក្រុមហ៊ុនជប៉ុន ដូចជាសាន់យ៉ូ (Sanyo) សាប (Sharp) ភូជិតស៊ូ (Fujitsu) ដើម្បីសង្គ្រោះខ្លួន ត្រូវបង្ខំចិត្តចេញទៅបោះទុនរកស៊ីនៅតៃប៉ិ ។ ក្រុមហ៊ុនកាណុង (Canon) បានសុំឱ្យក្រុមហ៊ុន អាសឺ (Acer) ស្ថាបនិកទីមួយរបស់តៃវ៉ាន់ រៀបចំឡើងវិញនូវខ្សែចង្វាក់ផលិតកម្មរបស់ខ្លួននៅប្រទេសជប៉ុន ។ ចំណែកក្រុមហ៊ុនណិច (NEC) បានសម្រេចទិញសម្ភារៈអេឡិចត្រូនិកពីតៃវ៉ាន់ ។ សូម្បីតែពួកកូរ៉េ ក៏ទប់ទល់ចំពោះភាពសម្បូរហូរហៀរបានដោយលំបាក ។ ទីក្រុងសេអ៊ូល បានបង្កើនតារាងពន្ធគយលើព័ត៌មានវិទ្យាយ៉ាងគំហុក ។ ប៉ុន្តែសម្ភារៈអេឡិចត្រូនិកម៉ាក សាំសុង ឥឡូវនេះមានផលិតនៅតៃវ៉ាន់ ។

កោះតៃវ៉ាន់ដណ្ដើមបានជោគជ័យជាស្រេច 80% នៃគ្រឿងអេឡិចត្រូនិក ជាងពាក់កណ្ដាលនៃម៉ូដឹម (modem) និងម៉ូនីទ័រ (moniteur) ដែលលក់ក្នុងពិភពលោកជាផលិតផលរបស់តៃវ៉ាន់ ។ ផ្ដើមចេញពីចំណុចសូន្យ តែប្រាំឆ្នាំប៉ុណ្ណោះផលិតផលអេឡិចត្រូនិកឥឡូវនេះមានជាង 1.5 លានគ្រឿង ។

## ១.៤. ទស្សនៈនៃជោគជ័យអេឡិចត្រូនិកតៃវ៉ាន់

ពលករស៊ីថ្លៃថោកមិនមែនជាកត្តាតែមួយគត់នៃជោគជ័យផ្នែកសេដ្ឋកិច្ចនោះទេ ។ ជាបឋម ឯកទេសភាពមូលធននិយមចិន(តៃវ៉ាន់)ដែលថ្មីកនិងផ្នែកអេឡិចត្រូនិច បាននាំមកនូវធនធានមនុស្សរបស់ខ្លួនពីគ្រប់ទិសទីក្នុងពិភពលោក ។ ជាពាណិជ្ជករផងនិងឧស្សាហករផង សហគ្រិនតៃវ៉ាន់ ប្រៀបបានទៅនឹងត្រីក្នុងទឹក ក្នុងការបែងចែកការងារអន្តរជាតិ ។ សហរដ្ឋអាមេរិក ជប៉ុន និងសិង្ហបុរី ជាអ្នកផ្គត់ផ្គង់លើផ្នែកផ្សេងៗនៃអេឡិចត្រូនិកដល់តៃវ៉ាន់ ។ ដូចនេះ តៃវ៉ាន់គ្រាន់តែជាទីតាំងពិព័រណ៍មួយដ៏ធំសម្បើមនៃមុខទំនិញអេឡិចត្រូនិក ដែលផលិតក្នុងស្រុក ឬនាំចូលតែប៉ុណ្ណោះ ។ លក្ខខណ្ឌតែមួយគត់គឺ តម្លៃថោកនិងបច្ចេកវិទ្យាជឿនលឿនបំផុតទេដែលមានប្រៀប ។

ក្នុងការគ្រប់គ្រង ជនជាតិតៃវ៉ាន់បានបង្ហាញនូវចរិតទន់ភ្លន់ដូចៗគ្នា ។ ផ្ទុយពីជប៉ុន តៃវ៉ាន់គ្មានកុងត្រូមេរាំដែលមានចំណាស់រាប់រយឆ្នាំទេ មានតែផែនការវិនិយោគសម្រាប់រយៈពេលដប់ឆ្នាំនិងតាមឋានានុក្រមប្រៀបបានទៅនឹងកងវរសេនាធំនៃកងទ័ពជើងគោកដូច្នេះដែរ ។ តៃវ៉ាន់មានសហគ្រាសតូចនិងមធ្យម PME ( Petites et Moyennes Entreprises) ផ្នែកអេឡិចត្រូនិកដែលជួនកាលជារោងជាងតូចៗផង ។ ប៉ុន្តែកម្លាំងសំខាន់នៃអេឡិចត្រូនិករបស់តៃវ៉ាន់ គឺរូបធាតុប្រផេះ(បញ្ញាវ័ន្ត)ជានិស្សិតច្រើនជំនាន់ ដែលបានទទួលការសិក្សាអប់រំនៅសហរដ្ឋអាមេរិកនិងត្រឡប់មកវិញ ក្នុងបំណងធ្វើឱ្យប្រទេសសម្បូរសប្បាយ នេះគឺជាការកត់សម្គាល់របស់លោក ប៉ាទ្រិចឡឺ អ្នកទទួលខុសត្រូវផ្នែកទីផ្សាររបស់ក្រុមហ៊ុន ហ៊ីវឡិត ប៉ាកាដ (Hewlett Packard) នៅតៃវ៉ាន់ ។

## ? សំណួរ

1. ចូរនិយាយអំពីសណ្ឋានដីនៃកោះតៃវ៉ាន់ ។
2. តើសណ្ឋានដីបែបនេះ អនុគ្រោះដល់ការអភិវឌ្ឍសេដ្ឋកិច្ចតៃវ៉ាន់បានដូចម្តេចខ្លះ ?
3. ចូរនិយាយអំពីសារៈសំខាន់ អាកាសធាតុកោះតៃវ៉ាន់ ។
4. តើស្រទាប់ជនជាតិតៃវ៉ាន់ណាមួយដែលដើរតួនាទីសំខាន់ក្នុងផ្នែកនយោបាយនិងរដ្ឋបាល ? ចូរពន្យល់ ។
5. ក្នុងការកសាងសេដ្ឋកិច្ច តើកោះតៃវ៉ាន់ពឹងផ្អែកលើកត្តាសំខាន់ៗអ្វីខ្លះ ?
6. "អព្ភូតហេតុសេដ្ឋកិច្ចឆ្នាំ 1960-1970" កើតឡើងនៅតៃវ៉ាន់ ដោយសារមូលហេតុអ្វី ?
7. ចូរប្រៀបធៀបទំហំផ្ទៃដីនិងចំនួនប្រជាជនតៃវ៉ាន់និងកម្ពុជា ។
8. តើកម្ពុជាអាចមានលទ្ធភាពអភិវឌ្ឍន៍សេដ្ឋកិច្ចដូចកោះតៃវ៉ាន់បានដែរឬទេ ? ចូរពន្យល់ ។

# 3 ទឹកដីហុងកុង

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាបានពីលក្ខខណ្ឌធម្មជាតិ លក្ខខណ្ឌសង្គម និងសេដ្ឋកិច្ចនៃទឹកដីហុងកុង ។

ហុងកុងជាផ្នែកតូចនៃទឹកដីចិន ហើយបានធ្លាក់ក្រោមការគ្រប់គ្រងរបស់ប្រទេសអង់គ្លេស កាលពីឆ្នាំ 1898 តាមអនុសញ្ញាប៉េកាំង សម្រាប់រយៈពេល 99ឆ្នាំ ។ អង់គ្លេសហៅទឹកដីនេះថា "ទឹកដីត្រូតត្រាថ្មី" (New Territories) ហើយបានអភិវឌ្ឍឱ្យក្លាយទៅជាទីក្រុងថ្មីដ៏ល្បីល្បាញ ។ នៅឆ្នាំ 1984 អង់គ្លេសយល់ព្រមប្រគល់ទឹកដីហុងកុងឱ្យទៅប្រទេសចិនវិញ នៅពេលផុតកំណត់នៃកិច្ចសន្យានៅថ្ងៃទី 01 ខែកក្កដាឆ្នាំ 1997 ។ តើទឹកដីនេះមានលក្ខខណ្ឌអំណោយផលដល់ការអភិវឌ្ឍដូចម្ដេចខ្លះ ?

## 1. លក្ខខណ្ឌធម្មជាតិ

ហុងកុង មានផ្ទៃដី 1 092 km$^2$ និងព័ទ្ធជុំវិញដោយដែនទឹក 1 830km$^2$ ។ ទោះបីមានទំហំតូចក្ដី ក៏សណ្ឋានដីហុងកុងមានលក្ខណៈប្លែកៗនិងរពើតរពើងដោយសារវត្តមាននៃភ្នំ ។ ភ្នំដែលមានកំពូលខ្ពស់ជាង 500m មានចំនួនច្រើនជាងម្ភៃ ។ តៃម៉សាន ជាភ្នំខ្ពស់ជាងគេ មានកម្ពស់ 957m ។ ចំណែកទីដីប្រើប្រាស់សម្រាប់កិច្ចអភិវឌ្ឍន៍មានតិចតួច (តិចជាង 15% នៃផ្ទៃដីសរុប) ។ នៅចន្លោះកោះហុងកុង និងកៅលន់ ឆ្នេរសមុទ្រជាជម្រកកំពង់ផែដ៏ល្អប្រសើរ ។

សាំឈុន ជាទន្លេសំខាន់តែមួយគត់ បង្កើតបានជាព្រំប្រទល់ខាងជើងជាមួយខេត្ត ក្វាងទុង ។ ផ្លូវទឹកផ្សេងទៀត ជាអូរតូចៗ ។ កង្វះទឹកស្អាតសម្រាប់ហូប ចោទជាបញ្ហាយ៉ាងធ្ងន់ធ្ងរចំពោះកោះហុងកុង ។ ទឹកស្អាតចំនួនជាង 80% នាំមកពីខេត្តក្វាងទុង ។

អាកាសធាតុហុងកុង មានលក្ខណៈជាអាកាសធាតុត្រូពិកមូសុង ។ សីតុណ្ហភាពមធ្យមប្រចាំថ្ងៃមានពី 26°C ទៅ 31°C នៅខែកក្កដានិង 13°C ទៅ 17°C នៅខែកុម្ភៈ ។ កម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំមាន 2 159mm ។ វស្សានរដូវ គឺពីខែឧសភាដល់ខែកញ្ញាមានរយៈពេលវែង ក្ដៅហើយសើម ។ ព្យុះទីផុង បក់បោកកាត់ទីក្រុងហុងកុងយ៉ាងទៀងទាត់នៅវស្សានរដូវនិងសរទរដូវ ។ ព្យុះដ៏សាហាវ

នេះនាំមកជាមួយនូវភ្លៀងខ្លាំងបំផុត ដែលជួនកាលបង្កឱ្យមានទឹកជំនន់និងការបាក់ដីទៀតផង ។ សិសិររដូវ គិតពីខែធ្នូ ទៅខែមីនា ត្រជាក់ហើយស្ងួត ។

ភ្លៀងធ្លាក់ខ្លាំងពេក ហូរនាំសារធាតុចិញ្ចឹមទៅអស់ពីដី ដែលជាហេតុបណ្តាលឱ្យដីខ្សោះជីជាតិ និងមិនអាចអនុវត្តកសិកម្មអតិផលបាន ។ ម្យ៉ាងវិញទៀត ដីកសិដ្ឋានក៏មានទំហំតូចៗ ។ ចំណែកព្រៃឈើជាច្រើនត្រូវបានកាប់និងដុតតាំងពីយូរយារមកហើយនិងត្រូវជំនួសដោយវាលស្មៅ ឬការដាំប្រភេទឈើ ដូចជាស្រល់និងដើមប្រេងខ្យល់ ។ សព្វថ្ងៃនេះ ភ្នំដែលមានដើមឈើមានប្រហែល 1/5 នៃផ្ទៃដីសរុប ។ ចំណែកឯដីវាលស្មៅ ដីឥតជីជាតិ និងវាលភក់ មានច្រើនជាងពាក់កណ្តាលនៃផ្ទៃដី ។

ហុងកុង ស្ថិតនៅក្នុងសមាគមនៃមូលនិធិសត្វព្រៃធម្មជាតិ បានអភិរក្សបក្សី តំបន់ដីសើមមួយចំនួនធំនៅម៉ៃប៉ំ (Maipo) តាមបណ្តោយឆ្នេរនៃឆកហាវហយ (Hau Hoi) និងនៅតាមទន្លេបណ្តោយព្រំប្រទល់ខេត្តក្វាងទុង ។ នៅម៉ៃប៉ំ មានបក្សីប្រហែល 260 ប្រភេទ ក្នុងចំណោមនោះ មានសត្វទាយ៉ាងច្រើន បក្សីដើរទេស សត្វចចាត សត្វចាប និងសត្វស្ទាំង ។ ទីបម្រុង គឺជាចំណុចស្នាក់នៅដ៏សំខាន់សម្រាប់បក្សីដើរទេស ដែលផ្លាស់ទីរវាងស៊ីបេរី តំបន់ត្រូពិកនៃអាស៊ីអាគ្នេយ៍ និងអូស្ត្រាលី ។ បន្ថែមពីលើនេះ ហុងកុងមានថនិកសត្វនិងល្មូនតូចៗជាច្រើនទៀត ។




*ទឹកដីហុងកុង*

## 2. លក្ខខណ្ឌសង្គម

នៅឆ្នាំ 1991 ហុងកុងមានប្រជាជនចំនួន 5 674 114 នាក់ ។ នៅឆ្នាំ 2007 មាន 6 980 412 នាក់ គិតជាដង់ស៊ីតេមាន 6 699 នាក់/$km^2$ ។

### 2.1. របាយប្រជាជន

ប្រជាជនមានរបាយមិនស្មើគ្នាទេ បណ្តុំប្រជាជនធំៗបំផុតមាននៅកៅលូន់និងនៅតាមកំពង់ផែនៃកោះហុងកុង ។ នៅសង្កាត់ខ្លះ ដូចជាម៉ងកុក នៃក្រុងកៅលូន់ ដង់ស៊ីតេប្រជាជន មានដល់ទៅ 40 000 នាក់/$km^2$ ក្នុងបណ្តាដង់ស៊ីតេប្រជាជនខ្ពស់បំផុតនៃពិភពលោក ។ ទោះបីអត្រាជាតិប្រមាណនិងមរណប្រមាណ មានកម្រិតទាបនៅហុងកុង ក៏ចលនាបម្លាស់ទីលំនៅមកពីកន្លែងដទៃទៀតនៃប្រទេសចិន បានបណ្តាលឱ្យមានអត្រាកំណើនប្រជាជនខ្ពស់ ហើយជនផ្លាស់លំនៅសព្វថ្ងៃនេះ មានដល់ទៅ 40% នៃប្រជាជនសរុប ។



*លំនៅស្ថាននៅហុងកុង*

### 2.2. ជាតិសាសន៍នានា

ប្រហែល 98% នៃប្រជាជនជាជនជាតិហាន ។ ក្នុងបណ្តាអ្នកទាំងនោះ 90% និយាយគ្រាមភាសាចិនកន្តាំងនិងមានដើមកំណើតមកពីភាគខាងត្បូងប្រទេសចិន ឬក៏ជាអ្នកតំណពូជនៃប្រជាជនដែលមានដើមកំណើតនៅទីនោះ ។ ក្រៅពីនោះ 10% នៃជនជាតិហាន ដែលមកពីតំបន់ផ្សេងៗនៃប្រទេសចិន និយាយគ្រាមភាសាចិនផ្សេងៗទៀត ។ ប្រមាណ 2% នៃប្រជាជនសរុប ជាអ្នកតំណពូជពីបុព្វបុរសរបស់គេ ដែលមកពីប្រទេសក្រៅ ភាគច្រើនមកពីអាស៊ីអាគ្នេយ៍ ។ ប្រជាជនជាច្រើន គោរពបូជាព្រលឹងដូនតា តាមលទ្ធិខុងជឺ ។ ភាសាចិននិងអង់គ្លេស ជាភាសាប្រើជាផ្លូវការនៅហុងកុង ។

## 2.3. ចលភាពប្រជាជន

ពីឆ្នាំ 1984 ដល់ឆ្នាំ 1997 ដោយសារភាពមិនច្បាស់លាស់នៃការផ្ទេរនិងការក្រែងរអែង ប្រជាពលរដ្ឋហុងកុង ដែលទទួលបានការអប់រំល្អ និងមានទ្រព្យសម្បត្តិជាច្រើនពាន់នាក់ បានផ្លាស់ប្តូរលំនៅទៅកាន់បណ្តាប្រទេស ដូចជាអូស្ត្រាលី កាណាដា និងសហរដ្ឋអាមេរិក ដែលនៅទីនោះ ពួកគេអាចទទួលបានការឱ្យស្នាក់នៅ ឬភាពជាពលរដ្ឋ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏មានមួយចំនួនធំបានវិលត្រឡប់មកកាន់ហុងកុងវិញ បន្ទាប់ពីបានធ្វើចំណាកស្រុកពីដំបូង ។



ហុងកុងនិងតំបន់ដីសណ្តតជ់

នៅឆ្នាំ 1973 រដ្ឋអំណាចហុងកុង បានចាប់ផ្តើមអនុវត្តកម្មវិធីសាងសង់លំនៅស្ថាននិងតាំងទីឧស្សាហកម្មជាថ្មីមួយដ៏ធំធេង ។ នេះគឺ ជាការសាកល្បងបន្ធូរភាពចង្អៀតណែនណាន់តាន់តាប់នៃទីក្រុងកៅលន់និងមណ្ឌលកណ្តាលនៃកោះហុងកុង ហើយនិងកាត់បន្ថយសំណូមពរដឹកជញ្ជូនដោយការរៀបចំសហគមន៍ឱ្យទៅនៅក្បែរមណ្ឌលការងារ ។ តាំងពីពេលនោះមក ប្រជាជនហុងកុងចូលចិត្តរស់នៅជិតកន្លែងធ្វើការ ។ វិធានការនេះបានជួយសម្រួលដល់ប្រជាជនហុងកុងមួយចំនួនធំ ដែលរស់នៅក្នុងទីតូចចង្អៀតនៃដែនដីអតីតអាណានិគមអង់គ្លេស ។



*មជ្ឈមណ្ឌលទីក្រុងហុងកុង*

# 3. លក្ខខណ្ឌសេដ្ឋកិច្ច

## 3.1. ជោគជ័យមួយជាគំរូ

ហុងកុង សម្រេចបានជោគជ័យក្នុងការកសាងអំណាចសេដ្ឋកិច្ចឧស្សាហកម្មនិងពាណិជ្ជកម្ម ។ ផលិតផលជាតិសរុប (GNP) ឡើងដល់ 100 ពាន់លានដុល្លារ ដើរមុខប្រទេសខ្លះ ដូចជាអាហ្សង់ទីន ក្រិក ឬព័រទុយហ្គាល់ ឈ្នះទាំងតំបន់ម៉ាទ្រិបទាំងមូលទៀតផង បើគិតពីធនធានផលិត ។

ពិតមែនហើយ ពាណិជ្ជកម្មក្រៅប្រទេសរីកចម្រើនយ៉ាងសម្បើម ដោយសារលំនាំចេញមួយចំនួនធំរបស់ប្រទេសចិនធ្លាក់ក្នុងកណ្តាប់ដៃសហគ្រាសខ្លួន ។ ទឹកដីដ៏តូចនេះ បានធ្វើឱ្យសម្រេចឡើងនូវពាណិជ្ជកម្មមួយសំខាន់ជាងរុស្ស៊ីទៅទៀត ។ ហុងកុង ក៏ជាមជ្ឈមណ្ឌលហិរញ្ញវត្ថុទីបីក្នុងពិភពលោក ដោយសារការរីកចម្រើនផ្នែកសារពើពន្ធ ។

ជាមួយនឹងភាពចំណុះទៅនឹងទីក្រុង ស៊ិនជិន (Shenzhen) និងតំបន់កង់តុងឬក្វាងចូវ (GuangZhou) ដ៏សកម្ម ដែលជាឃ្លាំងពលករនិងគំនិតផ្តួចផ្តើមមិនចេះរីងស្ងួត ហុងកុងជាទឹកដីដែលកំពុងទទួលបានការផ្លាស់ប្តូរឈានមុខគេ ហៅម្យ៉ាងទៀតថា ដីសណ្តគជ់ ចាប់ពីពេលដែលប្រទេសចិនបានបើកចំហទៅរកពិភពក្រៅ ពោលគឺ ជាតំបន់មួយសកម្មខ្លាំងក្លាបំផុតក្នុងលោក ។

## 3.2. លក្ខខណ្ឌអភិវឌ្ឍន៍ថ្មី

នយោបាយបើកទ្វារចំហរបស់ប្រទេសចិននៅដំណាច់ឆ្នាំ 1978 នាំមកនូវការប៉ះទង្គិចមួយដល់ក្រុងហុងកុង ដែលជាឃ្លាំងស្តុកទំនិញកាលពីដើម ។ ជាថ្មីម្តងទៀត មួយភាគធំនៃពាណិជ្ជកម្មរបស់ទឹកដីអាណានិគម បានប្រព្រឹត្តទៅជាមួយប្រទេសចិន ក្នុងលក្ខខណ្ឌផ្សេងៗពីឆ្នាំ 1950 ប៉ុន្តែទំនាក់ទំនងរបស់ចិនជាមួយពិភពមូលធននិយមតែងជួបការលំបាកជានិច្ច ។ ការបើក "តំបន់សេដ្ឋកិច្ចពិសេស (ZES)" ពីរគឺ ស៊ិនជិន ក៏ដូចជា ជូហៃ (Zhuhai) នៃខេត្តក្វាងទុង ដោយដើរតួនាទីដូចគ្នានឹងក្រុងម៉ាកាវ បានបម្រើជាបឋមឱ្យទីក្រុងហុងកុង ។ ការជោរជន់នៃសហគ្រាសបរទេស ដែលបានជ្រើសរើសយកហុងកុងជាឈ្នាន់ សម្រាប់ទំនាក់ទំនងជាមួយប្រទេសចិន នាំមកនូវសំទុះនៃការបើកការិយាល័យនិងធនាគារនៅលើទឹកដីអាណានិគមនេះតែម្តង ។ បន្ទាប់មក ស៊ិនជិន ក៏ក្លាយទៅជាសួតរបស់ហុងកុងនិងដោយសារកង្វះខាតទីដីផងនោះ ស៊ិនជិនមានមុខងារមួយទៀតគឺជាប្រភពផ្គត់ផ្គង់បន្ថែមនូវចំណីអាហារ ។

ជាចុងក្រោយ មានធាតុសំខាន់បីដែលពង្រឹងគ្នាទៅវិញទៅមក ដើម្បីបង្កើនថាមភាពទីក្រុង គឺការរកឃើញប្រេងកាតនៅតំបន់ជាយទ្វីប ការបើកទំនាក់ទំនងពាណិជ្ជកម្មរវាងតៃវ៉ាន់និងប្រទេសចិនដោយកំណត់យកហុងកុងជាចំណុចតភ្ជាប់រវាងប្រទេសទាំងពីរ និងការរីកចម្រើនរបស់ខេត្តក្វាងទុងដែលជាមូលដ្ឋាននៃឧស្សាហកម្មធុនស្រាលនិងសហគ្រាសពលករ ។

## ? សំណួរ

1. តើសណ្ឋានដីហុងកុងផ្តល់នូវសារៈសំខាន់សេដ្ឋកិច្ចអ្វីខ្លះ ?
2. តើអាកាសធាតុហុងកុងមានលក្ខណៈដូចម្តេចខ្លះ ?
3. តើអាកាសធាតុហុងកុងនិងអាកាសធាតុកម្ពុជាមានលក្ខណៈខុសប្លែកគ្នាត្រង់ណាខ្លះ ?
4. តើកំណើនខ្ពស់នៃប្រជាជនទីក្រុងហុងកុងបានមកពីអ្វី ?
5. ចូរនិយាយពីចលភាពនៃប្រជាជនហុងកុង ។
6. ចូរនិយាយអំពីតួនាទីសេដ្ឋកិច្ចនៃទីក្រុងហុងកុង ។
7. តើគំរូសេដ្ឋកិច្ចបែបហុងកុងមានលក្ខណៈដូចម្តេចខ្លះ ?
8. តើលក្ខខណ្ឌនៃការអភិវឌ្ឍថ្មីរបស់ហុងកុងមានអ្វីខ្លះ ?

# 4 ប្រទេសសិង្ហបុរី

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាបានពីលក្ខខណ្ឌធម្មជាតិ លក្ខខណ្ឌសង្គម និងសេដ្ឋកិច្ចប្រទេសសិង្ហបុរី ។

ជាមជ្ឈមណ្ឌលអាណានិគមអង់គ្លេសនៅម៉ាឡេស៊ី ក្នុងឆ្នាំ 1824 ជប៉ុន (1942-45)បង្កើតទៅជាទឹកដីអាណានិគមពិតប្រាកដរបស់អង់គ្លេសនៅឆ្នាំ 1946 ភ្ជាប់ទៅក្នុងសហព័ន្ធម៉ាឡេស៊ីនៅឆ្នាំ 1963 ។

សិង្ហបុរី បានក្លាយជារដ្ឋឯករាជ្យផ្តាច់ចេញពីម៉ាឡេស៊ីនៅថ្ងៃទី 09 ខែសីហា ឆ្នាំ 1965 ។ រដ្ឋដ៏តូចនេះដែលជាកោះនិងជាទីក្រុងមួយ បានវិតខំអភិវឌ្ឍសេដ្ឋកិច្ចតាមមាគ៌ាមូលធននិយម រហូតទទួលបានជ័យជំនះ ក្លាយជាប្រទេសឧស្សាហកម្មថ្មីនៃអាស៊ី ។

## 1. លក្ខខណ្ឌធម្មជាតិ

សិង្ហបុរី មានកោះទាំងអស់ចំនួន 63 ជាបុរីរដ្ឋ មានផ្ទៃដីសរុបពី 581.5km$^2$ នៅឆ្នាំ 1960 ដល់ 707.1km$^2$ សព្វថ្ងៃ ។ បម្រែបម្រួលផ្ទៃដីនេះ បានមកពីការវាយដណ្តើមដីពីសមុទ្រ ។ សិង្ហបុរី ស្ថិតនៅឃ្លាតពីឧបទ្វីបម៉ាឡេស៊ីដោយច្រកយោហូ និងឃ្លាតពីឥណ្ឌូណេស៊ីដោយច្រកសិង្ហបុរី ។ ភ្នំប៊ូឃីតទីម៉ា ជាកំពូលខ្ពស់របស់សិង្ហបុរី (163m) ។ កោះតេកុង យូប៊ីន និងសិនតូសាជាកោះធំជាងគេក្នុងបណ្តាកោះតូចៗទាំងឡាយរបស់សិង្ហបុរី ដែលមានកម្ពស់រហូត 15m ពីនីវ៉ូសមុទ្រ ។




*ផែនទីសិង្ហបុរី*

សិង្ហបុរី ស្ថិតក្រោមឥទ្ធិពលអាកាសធាតុត្រូពិចមូសុង ក្តៅហើយសើម ។ សីតុណ្ហភាពមធ្យមប្រចាំឆ្នាំប្រហែល 27°C និងមានភ្លៀងធ្លាក់ពេញមួយឆ្នាំ ប៉ុន្តែភ្លៀងធ្លាក់ខ្លាំងពីខែវិច្ឆិកាដល់ខែមករា ។ ចំណែកខែកក្កដាជាខែដែលមានភ្លៀងធ្លាក់តិចបំផុត ។ កម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំមាន 2 400mm ។

សិង្ហបុរី ជាប្រទេសមួយដែលមានសំណើមអាកាសខ្ពស់ គឺ 90% នៅពេលយប់ និងពេលព្រឹកព្រលឹម រីឯនៅពេលរសៀលមានពី 60% ទៅ 70% ។

ព្រៃស្បាតនិងវាលភក់មាននៅលើកោះដែរកាលពីដើម ។ តែសព្វថ្ងៃ គេបានរក្សាព្រៃស្បាតធម្មជាតិលើទីដីដ៏តូចមួយនៃតំបន់ភ្នំកណ្តាល ។ ចំណែកព្រៃរងទឹកភ្លៀង ត្រូវបានថែរក្សាទុកនៅទីបម្រុងធម្មជាតិប៊ូឃីតទីម៉ា ។ រីឯព្រៃកោងកាងតាមឆ្នេរ ត្រូវជំនួសវិញដោយប៉ុលខែឧស្សាហកម្ម ។

ប្រភេទសត្វព្រៃជាច្រើន ត្រូវរងគ្រោះថ្នាក់ដោយបាត់បង់ជម្រក ។ ខ្លារខិន ស្វាគ្រោស ឆ្មាព្រៃ ... ដែលរស់នៅក្នុងព្រៃរងទឹកភ្លៀង សព្វថ្ងៃស្ទើរតែផុតពូជ ។ សត្វដែលនៅសេសសល់ រួមមាន ស្វាឪ ជ្រូកព្រៃ សំពោច ... ។ ចំណែកសត្វស្លាបមានច្រើនប្រភេទនៅសិង្ហបុរី ។ ទីបម្រុងដីសើមសាន់ជេប៊ូឡូស នៅលើឆ្នេរភាគពាយ័ព្យកោះសិង្ហបុរី ជាទីជម្រកសំខាន់សម្រាប់បក្សីដើរទេស ។

សិង្ហបុរី មានផ្លូវទឹកខ្លីៗជាច្រើន និងអាងទឹកធម្មជាតិបីបួនប៉ុណ្ណោះ ដែលជាហេតុនាំឱ្យប្រទេសនេះខ្វះខាតទឹកប្រើប្រាស់ ។ ទឹកប្រហែលពាក់កណ្តាល ត្រូវនាំចូលពីម៉ាឡេស៊ី តាមបំពង់បង្ហូរភ្ជាប់សិង្ហបុរី និងយោហូបារូ ។ កំណើនដ៏ឆាប់រហ័សនៃសេដ្ឋកិច្ច ឧស្សាហកម្ម និងយានយន្តជាមូលហេតុដ៏ចម្បងនៃការបំពុលទឹក និងអាកាស ។

## 2. លក្ខខណ្ឌសង្គម

សិង្ហបុរី មាននាមជាផ្លូវការថា "សាធារណរដ្ឋសិង្ហបុរី" មានរដ្ឋធានីឈ្មោះសិង្ហបុរីដែរ ។ ក្រោយឯករាជ្យ ប្រទេសនេះដឹកនាំដោយ លោក លី គ្វាន់យូ (Lee Kuan Yew) ជានាយករដ្ឋមន្ត្រីនិងគណបក្សសកម្មភាពប្រជាជន PAP (The People's Action Party) ដែលទទួលបានសំឡេងគាំទ្រលើសលប់ នៅរាល់ការបោះឆ្នោត ។ សព្វថ្ងៃសិង្ហបុរី ជាសាធារណរដ្ឋសេរី ។ ប្រធានាធិបតីមានអាណត្តិ 6 ឆ្នាំជ្រើសរើសតាំងដោយរដ្ឋសភា ។ អំណាចនីតិប្រតិបត្តិ ជាសមត្ថកិច្ចរដ្ឋាភិបាលក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រីដែលធ្វើឱ្យប្រទេសមានសេដ្ឋកិច្ចខ្លាំងក្លា (ផលិតផលក្នុងស្រុកសម្រាប់មនុស្សម្នាក់ 30 928 ដុល្លារ)ហើយប្រជាជនមានសុខុមាលភាពជាទូទៅ (សង្ឃឹមរស់របស់បុរស 74.2ឆ្នាំស្ត្រី 78ឆ្នាំ) ។



*ទីក្រុងសិង្ហបុរី*

## 2.1. ប្រជាជនសិង្ហបុរី



*ប្រជាជនសិង្ហបុរី*

ជំរឿនឆ្នាំ 1990 ប្រជាជនសិង្ហបុរីមាន 2.7 លាននាក់ និងនៅឆ្នាំ 1998 មាន 3.05 លាននាក់ និងមានដង់ស៊ីតេ 4 720 នាក់ / $km^2$ ហើយនៅឆ្នាំ 2009 ប្រជាជនមាន 4 987 600 នាក់ និងមានដង់ស៊ីតេ 7 053 នាក់ / $km^2$ ។

នៅឆ្នាំ 2006 អត្រាជាតិប្រមាណមាន 1.01% អត្រានេះទាបណាស់ ដែលជាលទ្ធផលនៃនយោបាយត្រួតពិនិត្យកំណើត ហើយអត្រាមរណប្រមាណក៏ជាអត្រាមួយទាបបំផុតក្នុងលោកគឺ 0.43% ។ កំណើនប្រជាជនសរុបមាន 4.4% ស្របគ្នានឹងកំណើនអ្នកតាំងលំនៅស្ថាន 1.8% ។ អត្រាកំណើនខ្ពស់នេះបានមកពីចលនាចំណូលស្រុកសុខសាធ ប៉ុន្តែក៏មកពីកំណើនសង្ឃឹមរស់ផងដែរ ។ សិង្ហបុរី ក៏ជាប្រទេសដែលមានប្រជាជនរស់នៅណែនណាន់តាន់តាប់បំផុតទី 2 បន្ទាប់ពីប្រទេសម៉ូណាកូ ។ នៅឆ្នាំ 1957 ប្រជាជនសិង្ហបុរីមានប្រហែល 1.45 លាននាក់និងមានអត្រាជាតិប្រមាណខ្ពស់ ។ ដោយហេតុថា

ធនធានធម្មជាតិមានតិចតួចស្តួចស្តើងនិងទឹកដីតូចចង្អៀត រដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវគោលនយោបាយទប់កំណើតប្រជាជនចាប់ពីឆ្នាំ 1960 មកម្ល៉េះ ។ គេបានផ្សព្វផ្សាយព័ត៌មានយ៉ាងទូលំទូលាយពីវិធីពន្យារកំណើត ដូចជាបិទផ្សាយពាក្យស្លោក "សុភមង្គលគឺគ្រួសារមានកូនពីរនាក់" ផ្តល់មធ្យោបាយ រំលូត គ្រៀវ ដាក់កង ប្រើថ្នាំ ...និងអត្ថប្រយោជន៍ជាច្រើនដល់គ្រួសារកូនតិច ។ នៅក្រោយឆ្នាំ 1990 ប្រជាជនសិង្ហបុរី ក៏ក្លាយទៅជាមានទម្រង់ចាស់ ដែលជាហេតុនាំឱ្យមានការថយចុះចំនួនប្រជាជនសកម្ម និងកង្វះខាតពលករជំនាញ ។ រឿងដែលគួរឱ្យរំជួលចិត្តនោះគឺ នយោបាយបញ្ច្រាសទិសរបស់រដ្ឋាភិបាលសិង្ហបុរី ស្តីអំពី "តុរង្វាន់ដល់ទារក" នៅឆ្នាំ 2001 (ដែលអនុវត្តបានល្អនៅខែតុលា 2004) ដោយលើកទឹកចិត្តឱ្យគូស្រករមានកូនច្រើន ។

នៅឆ្នាំ 2006 អត្រាលទ្ធភាពបង្កកំណើតរបស់ស្ត្រីសិង្ហបុរីមាន 1.26 នាក់ប៉ុណ្ណោះ ទាបជាងគេបង្អស់ លំដាប់ទីបីក្នុងពិភពលោក ហើយអ្វីដែលល្អប្រសើរនោះគឺក្រោម 2.10 នាក់សម្រាប់បំពេញចំនួនប្រជាជន ។ ដើម្បីជំនះបញ្ហានេះ រដ្ឋាភិបាលបានលើកទឹកចិត្តឱ្យជនបរទេសចូលមករស់នៅសិង្ហបុរី ។ ការមកដល់នៃជនចំណូលស្រុកដ៏ច្រើនទាំងនោះ ជួយទប់តំហាយចុះនៃប្រជាជនសិង្ហបុរីបាន ។

### 2.2. ក្រុមជនជាតិ ភាសា និងសាសនា

ប្រជាជនសិង្ហបុរីចម្រុះដោយជនជាតិជាច្រើនដូចជា ជនជាតិចិនមាន 77.3% ជនជាតិម៉ាឡេស៊ីមាន 14.1% ជនជាតិឥណ្ឌាមាន 7.3% និងជនជាតិផ្សេងៗទៀត 1.3% ។ ភាសាប្រើជាផ្លូវការមានបួនគឺ ចិន អង់គ្លេស ម៉ាឡេស៊ី និងតាមិល ។ ភាសាចិន ជាភាសាទីមួយដែលនិយាយនៅតាមផ្ទះភាគច្រើន ។ ភាសាអង់គ្លេសជាភាសាសំខាន់ទីពីរ ប្រើនៅតាមស្ថាប័ននានានិងក្នុងកិច្ចការជំនួញ ។

សាសនាសំខាន់ៗនៅសិង្ហបុរីមាន ពុទ្ធសាសនិក (39.1%) តាវសាសនិក (21.9%) អ៊ីស្លាមសាសនិក (14.9%) គ្រិស្តសាសនិក (12.9%) ហិណ្ឌូសាសនិក (3.3%) សាសនាផ្សេងៗទៀត (0.6%) និងអ្នកអត់កាន់សាសនា (14.5%) ។

## 3. លក្ខណៈសេដ្ឋកិច្ច

### 3.1. ដំណាក់កាលនៃការអភិវឌ្ឍឧស្សាហកម្ម

នៅក្រោយសង្គ្រាមលោកលើកទីពីរ នាដំណាច់ទសវត្សរ៍ឆ្នាំ 1950 សិង្ហបុរីបានជួបប្រទះបញ្ហាមួយចំនួនធំដូចជា ភាពឥតការងារធ្វើ ភាពសម្បូរទីកន្ទក់នៅជុំវិញក្រុង កំណើនជម្លោះក្នុងសង្គម និងការបិទមូលដ្ឋាននាវាអង់គ្លេសនៅសិមបាវ៉ាង នាចុងទសវត្សរ៍ឆ្នាំ 1960 ដែលចិញ្ចឹមអ្នកធ្វើការដល់ទៅ 35 000 នាក់ ។ ការខិតខំប្រឹងប្រែងសង្កត់ធ្ងន់ទៅលើឧស្សាហូបនីយកម្មចាប់ពីពេលនោះមក ។ ក្រុម

វិនិយោគថ្មីមួយត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីទាក់ទាញមូលធនដ៏សម្បូរហូរហៀរពីបរទេសនិងដំណើរការឧស្សាហកម្មមួយសម្រាប់លំនាំចេញដែលប្រើកម្លាំងពលកម្មច្រើន ក្នុងគោលបំណងកាត់បន្ថយភាពឥតការងារធ្វើ ។ ទន្ទឹមនេះ ការងារសំខាន់ៗផ្នែកហេដ្ឋារចនាសម្ព័ន្ធក៏ចាប់ផ្ដើមធ្វើ ដូចជាការរៀបចំទីតាំងថ្មីនៃឧស្សាហកម្មនៅជូរ៉ុង (5 666ហ. ត)និងកំពង់ផែទឹកជ្រៅ ។ ក្រោមអំណាចនៃក្រុមហ៊ុនក្រុងជូរ៉ុង JTC ( Jurong Town Company ) ទីតាំងប្អូនដប់ទៀតនៃឧស្សាហកម្មត្រូវបានរៀបចំឡើងដំណាលគ្នានៅតំបន់ឆ្នេរ ។

នៅចុងទសវត្សរ៍ឆ្នាំ 1970 ការដំឡើងថ្លៃឈ្នួលឱ្យកម្មករដែលទាក់ទងនឹងការលើកកម្ពស់ជីវភាពប្រជាជនបង្កើតជាបញ្ហាដល់ការប្រកួតប្រជែងនៃឧស្សាហកម្មហត្ថពលករ (ឧស្សាហកម្មដំឡើងគ្រឿងអេឡិចត្រូនិក វាយនភ័ណ្ឌកាត់ដេរ សម្ភារៈប្រើប្រាស់ទូទៅ ...) ។ រដ្ឋាភិបាល បានសម្រេចធ្វើ "បដិវត្តន៍ឧស្សាហកម្ម" មួយ សំដៅជំរុញឧស្សាហកម្មបច្ចេកវិទ្យាខ្ពស់តាមគំរូតៃវ៉ាន់និងកូរ៉េ ។ ដោយធ្វើអន្តរាគមន៍ផ្ទាល់ក្នុងការចរចាស្ដីពីប្រាក់ខែ រដ្ឋាភិបាលបានសម្រេចឱ្យដំឡើងរហូតដល់ 40% ក្នុងរយៈពេលបីឆ្នាំ ក្នុងបំណងជំរុញឧស្សាហកម្មឱ្យទំនើបផ្នែកបរិក្ខារនិងតម្រង់ទិសវិនិយោគឆ្ពោះទៅរកឧស្សាហកម្ម ដែលមានតម្លៃបន្ថែមខ្ពស់ ។

ជាចុងក្រោយ ដូចគ្នានឹងនៅក្នុងប្រទេសឧស្សាហកម្មលូតលាស់ថ្មី (NPI) ដទៃទៀតដែរ ដោយសារសហគ្រាសបរទេសបានជួយជំរុញឧស្សាហកម្មសំណង់អគ្គិសនីនិងអេឡិចត្រូនិច សិង្ហបុរីនាំផលិតផលនេះចេញទៅសហរដ្ឋអាមេរិកបីដងច្រើនជាងទៅជប៉ុន ។ ដូចគ្នានឹងប្រទេស NPI បីទៀតដែរ បុរីរដ្ឋនេះ ពឹងផ្អែកជាចម្បងទៅលើសហរដ្ឋអាមេរិកសម្រាប់លំនាំចេញនិងលើជប៉ុនសម្រាប់លំនាំចូល ។ វិនិយោគរបស់អង់គ្លេសមានកម្រិតខ្ពស់ណាស់ គឺឈានមុខប្រជាជាតិទាំងពីរនេះ ។

## 3.2. បញ្ហានិងយថាទស្សន៍

ការលើកកម្ពស់ជីវភាពនិងការឈានចូលសម័យកាលនៃបម្រើបម្រាស់ដែលគេមើលឃើញច្បាស់តាមរយៈកម្រិតសិក្សាទូទៅខ្ពស់ បង្កើតការលំបាកដល់រដ្ឋាភិបាលតាំងពីដើមទសវត្សរ៍ឆ្នាំ 1980 ដូចជា

- បញ្ហាជាតិសាសន៍មួយធ្ងន់ធ្ងរបំផុតរវាងជនជាតិចិនភាគច្រើននិងជនជាតិម៉ាឡេស៊ីភាគតិចដែលយល់ថាគេមិនសូវឱ្យតម្លៃ ។
- បញ្ហាកំណើតទទួលបានការលើកទឹកចិត្តដោយរដ្ឋាភិបាលដែលព្រួយបារម្ភពីការធ្លាក់ចុះអត្រាជាតិប្រមាណក្នុងពេលថ្មីៗនេះ ជនជាតិចិនមានអត្រានេះទាបជាងជនជាតិម៉ាឡេស៊ីនិងឥណ្ឌា ។

- បញ្ហាអត្រាសន្សំប្រាក់ ដែលបានជួយផ្គត់ផ្គង់នយោបាយសាងសង់លំនៅស្ថានប្រកបដោយប្រសិទ្ធភាពរបស់រដ្ឋាភិបាលនិងជំនួយដល់មនុស្សចាស់ ប៉ុន្តែប្រជាជនវិញចង់បានសេវាអភិវឌ្ឍន៍ ការសិក្សាអប់រំសាធារណៈ ។

ចេញពីភាពអន់ថយមួយ នៅឆ្នាំ 1986 សេដ្ឋកិច្ចសិង្ហបុរីសព្វថ្ងៃ ហាក់ដូចជាមានភាពប្រសើរក្នុងបណ្ដានាគទាំងបួន ។ ពីឆ្នាំ 1966 ដល់ 1986 សេដ្ឋកិច្ចនេះទំនងជាមានអត្រាកំណើនខ្ពស់ជាងគេបំផុតក្នុងលោក ។ ប៉ុន្តែគិតក្នុងរយៈពេលវែង ប្រទេស NPI បីទៀតហាក់ដូចជាមានទីផ្សារពលករធំធេងនិងថោកជាង ក្នុងការទាក់ទាញវិនិយោគពីបរទេសដោយមិននិយាយពីប្រទេសចិន ម៉ាឡេស៊ី ឬឥណ្ឌូណេស៊ីទេ ។

តទៅអនាគត បុរីរដ្ឋនេះនឹងក្លាយទៅជាមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍមួយសម្រាប់ក្រុមហ៊ុនពហុជាតិនានា ដោយការផ្ដល់ហេដ្ឋារចនាសម្ព័ន្ធដ៏ល្អប្រសើរ(ដីធ្លី ធនាគារ សណ្ឋាគារ ...) ។ ចំណែកប្រទេសជិតខាង ដែលមានប្រជាជនច្រើននិងតម្លៃពលកម្មទាបជាងនឹងទទួលបាននូវសំណង់ សម្រាប់ផលិតកម្មផ្ទាល់តែម្ដង ។ ចាប់តាំងពីឥឡូវនេះទៅហើយ សហគ្រាសជប៉ុន (ម៉េបា សូនី) បានបង្កើតមូលដ្ឋានស្រាវជ្រាវនៅសិង្ហបុរី ដែលនឹងក្លាយទៅជា "ខួរក្បាល"បច្ចេកវិទ្យានៅអាស៊ីអាគ្នេយ៍ ។

## ? សំណួរ

1. តើប្រទេសសិង្ហបុរីដោះស្រាយបញ្ហាខ្វះខាតដីសម្រាប់អភិវឌ្ឍដោយវិធីណា ?
2. ហេតុអ្វីបានជាសិង្ហបុរីខ្វះខាតទឹកសម្រាប់ប្រើប្រាស់ ? តើគេដោះស្រាយដោយមធ្យោបាយណា ?
3. ចូរនិយាយអំពីបញ្ហាកំណើនប្រជាជនសិង្ហបុរី ។
4. ចូរនិយាយអំពីដំណាក់កាលអភិវឌ្ឍន៍ឧស្សាហកម្ម នៅចុងទសវត្សរ៍ឆ្នាំ 1970 ។
5. តើចាប់ពីដើមទសវត្សរ៍ឆ្នាំ 1980មក តើរដ្ឋាភិបាលសិង្ហបុរីជួបនឹងបញ្ហាអ្វីខ្លះ ?
6. តើកម្ពុជាអាចមានលទ្ធភាពអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចបានដូចសិង្ហបុរីដែរឬទេ ? ព្រោះអ្វី ? ចូរពន្យល់ ។

## ? សំណួរបញ្ចប់ជំពូកទី៣

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់មុខចម្លើយត្រូវតែមួយគត់**

1. កំពង់ផែលេខមួយនិងជាទីក្រុងទីពីររបស់កូរ៉េខាងត្បូងគឺ

☐ ក. ពូសាន ☐ ខ. អ៊ុលសាន

☐ គ. ប៉ូហាង ☐ ឃ. យេវចុង

2. ចំណុចខ្ពស់បំផុតរបស់ប្រទេសសិង្ហបុរីគឺ

☐ ក. ភ្នំហាឡា ☐ ខ. ភ្នំយូសាន

☐ គ. ភ្នំតែម៉សាន ☐ ឃ. ប៊ូឃីតទីម៉ា

**II. ចូរផ្ទៀងផ្ទាត់ផ្នែក A និង B រួចភ្ជាប់ចម្លើយត្រូវក្នុងផ្នែក C :**

| A | B | C (ចម្លើយ) |
|---|---|---|
| 1. 100 032 $Km^2$<br>2. 36 000 $Km^2$<br>3. 707.1 $Km^2$ | ក. សាធារណរដ្ឋសិង្ហបុរី<br>ខ. កោះតៃវ៉ាន់<br>គ. ទឹកដីហុងកុង<br>ឃ. សាធារណរដ្ឋកូរ៉េ | 1 →<br>2 →<br>3 → |

**III. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ :**

1. 1.26 នាក់ ជាអត្រាបង្កកំណើតរបស់ស្ត្រី.......................... នៅឆ្នាំ 2006 ។
2. ប្រទេសមួយក្នុងបណ្ដា "នាគទាំងបួន" ដែលបានប្ដូរនយោបាយពីប្រឆាំងកំណើតមកផ្ដល់ "គុណង្វាន់ដល់ទារក" វិញគឺ ...................... ។

**IV. សំណួរ**

1. តើរបបនយោបាយនិងសេដ្ឋកិច្ចរបស់ហុងកុងនិងតៃវ៉ាន់មានលក្ខណៈដូចម្ដេចខ្លះ ?
2. តើមាគ៌ាអភិវឌ្ឍន៍សេដ្ឋកិច្ចបែបកូរ៉េខាងត្បូងផ្អែកលើកត្តាអ្វីខ្លះ ?

# ជំពូកទី 4 កំណើនប្រជាជននិងផលវិបាក




○ ចំណុចនីមួយៗតាង 500 000 នាក់ ○ កំណុំរង ◯ កំណុំសំខាន់ៗ

*ផែនទីបង្ហាញពីកំណុំនៃដំណុះប្រជាជន (2004)*

ចាប់តាំងពីមានកំណាកំណើតនៅលើភពផែនដីមក មនុស្សលោកមានការវិវត្តឥតឈប់ឈរ ទាំងចំនួន ទាំងរបៀបរបបរស់នៅ ។ ការវិវត្តនៃចំនួននេះ គឺប្រាកដជាកំណើនប្រជាជន ហើយមានកំណើនវិជ្ជមាននិងកំណើនអវិជ្ជមាននៅឆ្នាំណាមួយ ដែលបណ្ដាលមកពីកំណើនធម្មជាតិ និងការផ្លាស់ទីលំនៅ ។ រីឯការវិវត្តរបៀបរស់នៅ វាជាផលវិបាកនៃកំណើននេះឯង ។ កំណើនប្រជាជនប្រព្រឹត្តទៅតាមចង្វាក់មិនដូចគ្នាទេ តែងប្រែប្រួលទៅតាមយុគសម័យផង និងទៅតាមរបៀបរបបសង្គមផង ។ នៅដើមសហស្សវត្សទីបីនេះ នៅលើផែនដីយើងមានមនុស្សរស់នៅចំនួន 6.5 ពាន់លាននាក់និងមានរបាយមិនស្មើគ្នាទេ ។ តាមការប៉ាន់ស្មានរបស់អ្នកវិទ្យាសាស្ត្រ ប្រជាជនពិភពលោកនឹងកើនដល់ 9 ពាន់លាននាក់នៅឆ្នាំ 2050 ។

# 1 កំណើនប្រជាជនពិភពលោក

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ពីកំណើនប្រជាជនពិភពលោក ប្រវត្តិកំណើន អន្តរភាពប្រជាសាស្ត្រ និងពិភពលោកមួយបែងចែកប្រជាសាស្ត្រ ។

ក្រោយពេលដែលមានកំណើនយឺត និងទៀងទាត់អស់ជាច្រើនពាន់ឆ្នាំមក ភពផែនដីមានបន្ទុះប្រជាសាស្ត្រចាប់ពី 2 សតវត្សកន្លងមកថ្មីៗនេះ ។ ហេតុអ្វីបានជាចំនួនមនុស្សលោកមានកំណើនសម្បើមម្ល៉េះ ក្នុងរយៈពេលប្រហែល 200 ឆ្នាំនេះ ? តើគ្រប់ប្រទេសទាំងអស់ សុទ្ធតែមានការវិវត្តស្មើចង្វាក់គ្នាដែរឬទេ ?

## 1. ប្រវត្តិកំណើនប្រជាជន

### 1.1. មុនឆ្នាំ 1650

តាំងពីដើមកំណើតមនុស្សជាតិ រហូតដល់ពាក់កណ្តាលសតវត្សទី 17 ប្រជាជនពិភពលោកមានកំណើនយឺតបំផុត ។ ក្នុងរយៈពេលដ៏វែងនេះ ប្រជាជនកើនពី 250 លាននាក់ ក្នុងឆ្នាំ 2000 មុនគ. ស. ដល់ 500 លាននាក់ នៅឆ្នាំ 1650 ។ អត្រាកំណើនមធ្យមមានប្រហែល 0.05% ។ មរណប្រមាណខ្ពស់បានកំណត់កំណើនមនុស្សជាតិគឺ កុមារចំនួន 1/3 បានស្លាប់នៅក្នុងអាយុក្រោមមួយឆ្នាំ ហើយសង្ឃឹមរស់ មានមិនលើសពី 30 ឆ្នាំឡើយ ទោះបីជាតិប្រមាណមានកម្រិតខ្ពស់ក៏ដោយ ។

ការរីកសាយនៃកសិកម្មដែលចាប់ផ្តើមកាលពីប្រាំមួយពាន់ឆ្នាំមុន គ. ស. ពន្យល់បានពីកំណើនលើកទីមួយនៃប្រជាជនពិភពលោក ។ កំណើននេះ មិនបានជាប់លាប់បន្តបន្ទាប់ទេ ប៉ុន្តែប្រព្រឹត្តទៅជួនលូតលាស់ទៅមុខនៅពេលសន្តិភាពនិងអភិវឌ្ឍន៍ ហើយជួនថយក្រោយនៅពេលអាកាសធាតុមិនល្អ ឬពេលសង្គ្រាម ទុរ្ភិក្ស និងរោគរាតត្បាត ។ *ឧទាហរណ៍* នៅអឺរ៉ុប ការរីកចម្រើនពីស. វ. ទី 11 ដល់ទី 13 បានមកពីអាកាសធាតុនិងកសិកម្មមានអំណោយផលល្អ ។ ក្រោយមក មានការធ្លាក់ចុះបន្តបន្ទាប់ ដោយការសម្លាប់រង្គាលពីជំងឺ ប៉េស្តខ្មៅ (ជំងឺពិសម្យ៉ាងឆ្លងតាមសត្វកណ្តុរ) ពីឆ្នាំ 1347 ដល់ 1351 ដែលបណ្តាលឱ្យមនុស្សស្លាប់អស់ 25 លាននាក់ កាត់បន្ថយមនុស្សអស់ចំនួនមួយភាគបួន ។

## 1.2. ពីឆ្នាំ 1650 ដល់ឆ្នាំ 1950

ក្នុងរយៈពេល 300ឆ្នាំនេះ ប្រជាជនពិភពលោកកើនពី 500លានទៅ 2 500លាននាក់ ។ កំណើនមធ្យមមាន 0.5% ស្មើរដប់ដង កាលពីមុនឆ្នាំ 1650 ។ កំណើននេះ បានមកពីតំហយចុះជាប់លាប់នៃអត្រាមរណប្រមាណ ។ ចាប់តាំងពីពាក់កណ្ដាលទីពីរនៃសតវត្សទី 18 ប្រទេសខ្លះ ដូចជាស៊ុយអែត បារាំង អង់គ្លេស មានកំណើនប្រជាជនយ៉ាងរហ័ស ។ បាតុភូតនេះ បានរីកសាយទៅក្នុងប្រទេសអឺរ៉ុបមួយចំនួនធំទៀត នៅសតវត្សទី 19និងផ្លាយទៅដល់ប្រទេសថ្មី (សហរដ្ឋអាមេរិកនិងកាណាដា) ។

ចាប់តាំងពីសតវត្សទី 18មក បដិវត្តន៍កសិកម្មអាចផ្ដល់នូវចំណីអាហារដ៏ល្អប្រសើរនិងបានបញ្ចប់គ្រោះទុរ្ភិក្សពីក្នុងប្រទេសទាំងនោះ ។ ការរីកចម្រើនផ្នែកវិជ្ជាពេទ្យ និងអនាម័យ បានធ្វើឱ្យមរណប្រមាណថយចុះនៅសតវត្សទី 19 ។ ការប្រើប្រាស់ទឹកស្អាត ប្រព័ន្ធលូបង្ហូរទឹកក្នុងក្រុង ការសិក្សាអប់រំពីភាពស្អាត និងការចាក់វ៉ាក់សាំង បានរីកសាយ ពិសេសការប្រយុទ្ធប្រឆាំងជំងឺអុត ដ៏កាចសាហាវ ជាអំរែកមរណៈរាប់សតវត្សកន្លងមក ។ នៅស្ទើរគ្រប់ទីកន្លែង អត្រាជាតិប្រមាណមានកម្រិតខ្ពស់ ប្រជាជនកើនជាមធ្យមក្នុងអត្រាពី 1 ទៅ 1.5% ។




*ក្រាបបង្ហាញចំនួនប្រជាជនពិភពលោក*

### 1.3. ចាប់ពីឆ្នាំ 1950 មក

នៅសតវត្សទី 20 កំណើនប្រជាជននៅតែខ្លាំងក្លាដោយសារតំហយចុះយ៉ាងរហ័សនៃមរណប្រមាណ នៅកន្លែងផ្សេងៗទៀតនៃពិភពលោក ។ ប្រជាជនពិភពលោក មានចំនួន 3 ពាន់លាននាក់នៅឆ្នាំ 1960 4.435 ពាន់លាន (1980) 5.264 ពាន់លាន (1990) និង 6.5 ពាន់លាន (2006) ។ កំណើនដ៏ខ្លាំងក្លានេះ មានតែនៅក្នុងប្រទេសកំពុងអភិវឌ្ឍនៃទ្វីបអាស៊ី អាហ្វ្រិក និងអាមេរិកឡាទីន ព្រោះប្រជាជនប្រទេសអភិវឌ្ឍលែងកើនឡើងទៀតហើយ ។

មរណប្រមាណនៅក្នុងប្រទេសលោកខាងត្បូង បានថយចុះយ៉ាងសម្បើម ដោយសារវឌ្ឍនភាពសេវាសុខាភិបាល កសិកម្ម និងជំនួយស្បៀង ។ ដូចនៅទ្វីបអឺរ៉ុបដែរ ជាតិប្រមាណមានកម្រិតខ្ពស់ ក្នុងរយៈពេលយូរ នាំឱ្យកំណើនធម្មជាតិមានដល់ទៅ 2.5% នៅបណ្តាឆ្នាំ 1960 2.05% (1990) 1.61% (2000) និង 1.34% (2006) ។ ប៉ុន្តែក៏មានគម្លាតគ្នាខ្លាំងណាស់ដែរ រវាងបណ្តាប្រទេសលោកខាងត្បូងទាំងនោះ ។

## 2. អន្តរភាពប្រជាសាស្ត្រ

អន្តរភាពប្រជាសាស្ត្រ គឺជាដំណើរឆ្លងកាត់ពីរបបប្រជាសាស្ត្រមួយ ដែលមានជាតិប្រមាណនិងមរណប្រមាណខ្ពស់ ទៅរបបប្រជាសាស្ត្រមួយទៀត ដែលមានជាតិប្រមាណនិងមរណប្រមាណទាប ។

### 2.1. របបប្រជាសាស្ត្រប្រពៃណី

នៅមុនអន្តរភាពប្រជាសាស្ត្រ អត្រាកំណើនធម្មជាតិមានកម្រិតទាបណាស់ ព្រោះជាតិប្រមាណនិងមរណប្រមាណខ្ពស់ដូចគ្នា ។ ជាតិប្រមាណខ្ពស់ ព្រោះនៅជំនាន់នោះ គេមិនបានយល់ដឹងសោះឡើយថា អ្វីទៅជាផែនការគ្រួសារនោះ ហើយគូស្រករ ក៏បង្កើតកូនដោយចៃដន្យ មិនមែនតាមក្តីប្រាថ្នាឡើយ ។ មរណប្រមាណខ្ពស់ ព្រោះអ្នកជំនាន់នោះរស់នៅតាមបែបធម្មជាតិ ក្រោមការញាំញីនៃជំងឺរាតត្បាត គ្មានថ្នាំសង្កូវត្រឹមត្រូវសម្រាប់ការពារព្យាបាល ពោលគឺវេជ្ជសាស្ត្រមានកម្រិតទាប ។

### 2.2. អន្តរភាពប្រជាសាស្ត្រវគ្គទី 1

គេសង្កេតឃើញមានកំណើនធម្មជាតិខ្ពស់ ព្រោះជាតិប្រមាណខ្ពស់ តែមរណប្រមាណស្រុតចុះ ។ ជាតិប្រមាណនៅតែខ្ពស់ ព្រោះលទ្ធភាពបង្កកំណើតមានកម្រិតខ្ពស់ (6 ទៅ 8 សម្រាប់ស្ត្រីម្នាក់) ។ មរណប្រមាណចាប់ផ្តើមថយចុះ ពិសេសមរណភាពកុមារ ព្រោះកិច្ចការពារផ្នែកវេជ្ជសាស្ត្រមានភាពប្រសើរ ស្រុបគ្នានិងអនាម័យផងដែរ ។

### 2.3. អន្តរភាពប្រជាសាស្ត្រវគ្គទី 2

ជាតិប្រមាណថយចុះ ស្របគ្នានឹងមរណប្រមាណនៅតែទាបដែលជាហេតុនាំឱ្យកំណើនធម្មជាតិនៃប្រជាជន ចាប់ផ្ដើមមានល្បឿនយឺត។ ជាតិប្រមាណស្រុតចុះយ៉ាងរហ័ស អាស្រ័យមូលហេតុច្រើនយ៉ាង តម្លៃជីវភាពកើនឡើង ការចូលរួមកាន់តែច្រើនក្នុងកិច្ចការសង្គមនិងការងារផលិតកម្មរបស់នារី ការពន្យារអាយុរៀបអាពាហ៍ពិពាហ៍ និងការអនុវត្តផែនការគ្រួសារ។ មរណប្រមាណទាប ព្រោះវេជ្ជសាស្ត្រកាន់តែជឿនលឿនខ្លាំង ចំណីអាហារកាន់តែប្រសើរឡើង។

### 2.4. របបប្រជាសាស្ត្រទំនើប

អន្តរភាពប្រជាសាស្ត្រត្រូវបានបញ្ចប់ នៅពេលដែលចំនួនប្រជាជនមានលំនឹង លទ្ធភាពបង្កកំណើតរបស់ស្ត្រីចុះទាប (2នាក់ ឬទាបជាងនេះ) មរណប្រមាណ លែងបន្តថយចុះទៀត តែជួនកាលអាចកើនឡើងផងដែរ ព្រោះសមាមាត្រមនុស្សចាស់កាន់តែធំ (ភាពចំណាស់នៃទម្រង់ប្រជាជន)។

## 3. ពិភពលោកមួយបែងចែកតាមប្រជាសាស្ត្រ

សព្វថ្ងៃ ស្ថានភាពប្រជាសាស្ត្រប្រទេសអភិវឌ្ឍនិងប្រទេសកំពុងអភិវឌ្ឍ មានលក្ខណៈផ្ទុយគ្នា។ ប្រទេសលោកខាងជើង បានចេញផុតពីអន្តរភាពប្រជាសាស្ត្រហើយ រីឯប្រទេសលោកខាងត្បូង ភាគច្រើនស្ថិតក្នុងវគ្គទី 2នៃអន្តរភាព ក្នុងពេលដែលប្រទេសខ្លះទៀតទើបតែបញ្ចប់វគ្គទី 1 ប៉ុណ្ណោះ។

នៅក្នុងប្រទេសអភិវឌ្ឍ លទ្ធភាពបង្កកំណើតរបស់ស្ត្រីមានកម្រិតទាប (តិចជាង 2 នាក់) ដោយសារគូស្រករមានការយល់ដឹងច្បាស់ពីលក្ខខណ្ឌជីវភាព និងស្ម័គ្រចិត្តយកកូនតិច។ នៅទ្វីបអឺរ៉ុបដ៏ចំណាស់នេះ ជំនាន់មនុស្សលែងកើតមានទៀតហើយនិងនៅប្រទេសខ្លះ ដូចជាអាល្លឺម៉ង់ ដាណឺម៉ាក ហុងគ្រី និងអ៊ីតាលី មរណប្រមាណខ្ពស់ជាងជាតិប្រមាណ ដែលជាមូលហេតុនៃកំណើនអវិជ្ជមាន។

ស្ថានភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍមានប្លែកៗគ្នា។ រដ្ឋមួយចំនួនដូចជា ចិន កូរ៉េខាងត្បូង តៃវ៉ាន់ សិង្ហបុរី ថៃ បានបញ្ចប់អន្តរភាពប្រជាសាស្ត្រខ្លួនហើយ ដោយសារនយោបាយផែនការគ្រួសារដ៏មានប្រសិទ្ធភាព។ ប្រទេសភាគច្រើនផ្សេងទៀត កំពុងតែមានការវិវត្តក្នុងទិសដៅនេះដែរ។

លទ្ធភាពបង្កកំណើតស្ថិតនៅខ្ពស់ដដែលនៅអាហ្វ្រិកស្បែកខ្មៅ ភាគច្រើននៅជនបទក្រីក្រ។ នៅតំបន់ក្បែរបូព៌ានិងមជ្ឈិមបូព៌ា ដែលទទួលបាននគរូបនីយកម្មនិងអភិវឌ្ឍន៍ខ្ពស់ ឥទ្ធិពលដ៏ខ្លាំងក្លានៃសាសនានិងស្ថានភាពមិនអនុគ្រោះចំពោះស្ត្រីក្នុងសង្គម បានរក្សាទុកផងដែរនូវលទ្ធភាពបង្កកំណើតខ្ពស់។ នៅក្នុងតំបន់ទាំងពីរ គំហយចុះជាក់លាក់មួយនៃលទ្ធភាពបង្កកំណើតត្រូវបានកត់ត្រាទុក តាំងពីដំណាច់ទសវត្សរ៍ឆ្នាំ 1980 ហើយប្រទេសទាំងនោះ ក៏បានឈានចូលទៅក្នុងវគ្គទី 2នៃអន្តរភាពប្រជាសាស្ត្រ។

## ៤. កំណើនប្រជាជននិងភាពក្រីក្រ

ដំណើរការវិវត្តឆ្ពោះទៅរកអន្តរភាពប្រជាសាស្ត្ររបស់ប្រទេសកំពុងអភិវឌ្ឍពុំគ្រាន់តែបណ្តាលឱ្យមានកំណើនប្រជាជនយ៉ាងឆាប់រហ័សប៉ុណ្ណោះទេ ថែមទាំងនាំមកនូវបម្រែបម្រួលទម្រង់ប្រជាជនតាមភេទនិងតាមអាយុ (ពីរ៉ាមីតអាយុប្រជាជន) និងទម្រង់គ្រួសារយ៉ាងខ្លាំងក្លាទៀតផង ។ បាតុភូតទាំងពីរនេះ ជះឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមានទៅលើភាពក្រីក្រ អាស្រ័យនឹងភាពឆាប់លឿនក្នុងអន្តរភាពប្រជាសាស្ត្រ ។

### ៤.១. ពេលដំបូងនៃអន្តរភាពប្រជាសាស្ត្រ

ក្នុងដំណាក់កាលនេះ ពីរ៉ាមីតអាយុប្រជាជនបានបង្ហាញឲ្យច្បាស់ណាស់ថា ប្រជាជនមានទម្រង់ក្មេង ពោលគឺចំនួនកុមារមានច្រើនជាងមនុស្សពេញវ័យ ហើយផលវិបាកគឺ

- ប្រាក់សន្សំ មានកម្រិតទាប (មេគ្រួសារត្រូវចំណាយលុយយ៉ាងច្រើន សម្រាប់ចិញ្ចឹមគ្រួសារដ៏ធំ និងមិនអាចសន្សំលុយកាក់បានឡើយ) ។
- សុខភាពនិងការសិក្សាអប់រំមានកម្រិតទាប (ខ្វះថវិកា សម្រាប់ព្យាបាលជំងឺនិងការរៀនសូត្ររបស់កូនចៅ) ។
- កំណើនសម្ពាធលើបម្រើបម្រាស់ធនធានធម្មជាតិ (*ឧទាហរណ៍* កំណើនតម្រូវការអុស ធ្យូង ឈើ សំណង់នានា ...នាំឱ្យបាត់បង់ព្រៃឈើជាដើម) ។
- កំណើនវិសមភាពភេទ (កំណើនការងារផ្ទះរបស់ស្ត្រីមេផ្ទះនិងកូនស្រី ដែលជាប់រវល់ជួយកិច្ចការផ្ទះ ខកខានមិនបានទៅសាលារៀន) ។

### ៤.២. សម័យកាលទី 2 នៃអន្តរភាពប្រជាសាស្ត្រ

នៅក្នុងដំណាក់កាលទី 2 នេះ គេឃើញដំណើរឆ្ពោះទៅរកលំនឹងប្រជាសាស្ត្រ ជាពិសេសរវាងកុមារនិងមនុស្សពេញវ័យ ទំហំគ្រួសារឆ្ពោះទៅរកភាពរួមតូច បន្ទុកគ្រួសារតិច ជីវភាពគ្រួសារអាចល្អប្រសើរឡើង សុខភាព និងការសិក្សាអប់រំ ត្រូវបានកែលម្អ ផលិតភាពការងារនិងផលទុនអាចត្រូវបានលើកកម្ពស់ ភាពក្រីក្រអាចត្រូវបានកាត់បន្ថយ ។

តាមពិត សម័យកាលនេះហើយដែលរដ្ឋអាចសម្រេចបាននូវការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ដូចជានៅបណ្តាប្រទេសមួយចំនួននៃអាស៊ីបូព៌ា អាស៊ីអាគ្នេយ៍ អាស៊ីទក្សិណ និងអាមេរិកឡាទីន ។ ចំណែកនៅអាហ្វ្រិកក្បែរសាហារ៉ា លទ្ធភាពបង្កកំណើតរបស់ស្ត្រីនៅមានកម្រិតខ្ពស់នៅឡើយ (5.2 នាក់សម្រាប់ស្ត្រីម្នាក់) ។ នៅក្នុងប្រទេសតែមួយ លទ្ធភាពបង្កកំណើតក៏ខុសគ្នាដែរ ទៅតាមក្រុមសង្គម ដូចជានៅប្រទេសប្រេស៊ីល មាន 1.6 នាក់សម្រាប់ក្រុមសង្គមអ្នកមាន និង 3.2 នាក់សម្រាប់ក្រុមសង្គមអ្នកក្រីក្រឆ្នាំ 1995 ។

## ៤.៣. ការមានកូនច្រើនជាគុណប្រយោជន៍ចំពោះគ្រួសារក្រីក្រ

គ្រួសារក្រីក្រយល់ថា ការមានកូនច្រើនផ្តល់ប្រយោជន៍ជាច្រើនយ៉ាង ៖

- កូនៗអាចជួយថែទាំឪពុកម្តាយ ពេលគាត់មានវ័យចាស់ ។
- កូនៗដែលមិនទាន់ទៅសាលា ចាប់បំពេញការងារ (អាយុ 5 ឆ្នាំ)និងរកលុយបានបន្តិចបន្តួចសម្រាប់ឪពុកម្តាយគេ ។
- កូនស្រី អាចជួយសម្រាលការងារផ្ទះរបស់អ្នកម្តាយ ដូចជាដាំស្ល បោកគក់ មើលប្អូនជាដើម ។

ចំពោះគ្រួសារទាំងនោះ ការមានកូនច្រើនអាចបន្តរស់បាន ប៉ុន្តែលទ្ធភាពអប់រំនិងសន្សំប្រាក់ដែលជាមធ្យោបាយសំខាន់ ក្នុងការទប់ស្កាត់ភាពក្រីក្រមានតិចតួចណាស់ ។

ការសិក្សាអប់រំ អាចជួយកាត់បន្ថយអត្រាមរណៈ ដូចជាការសិក្សាយល់ដឹងពីវិធីទប់ស្កាត់ជំងឺឆ្លងផ្សេងៗ ជាពិសេសជំងឺអេដស៍ ដែលនាំមកនូវផលវិបាកយ៉ាងច្រើន ដូចជា

- មានទុក្ខព្រួយជាប្រចាំ ដោយឃើញកូនស្លាប់មុនខ្លួន ។
- មានការលំបាកដោយបាត់បង់ការជួយឧបត្ថម្ភពីកូន ពេលខ្លួនជរា ។
- មានបន្ទុកការងារបន្ថែមលើកិច្ចការ ដែលកូនរបស់គេធ្លាប់បំពេញ ។
- មានបន្ទុកចិញ្ចឹមបីបាច់រក្សាចៅតូចៗ ដែលកំព្រា ។

ដូចនេះ នយោបាយប្រជាសាស្ត្រ មានទំនោរទៅរកការកាត់បន្ថយរយៈពេលអន្តរភាពប្រជាសាស្ត្រ សំដៅធ្វើឱ្យលក្ខខណ្ឌសុខភាពកូនៗកាន់តែប្រសើរឡើង (លទ្ធភាពបង្កកំណើតទាប អត្រាមរណៈកុមារតិច)និងទៅរកការកាត់បន្ថយវិសមភាពភេទផងដែរ ។

## ? សំណួរ

1. តើកំណើនទាបនៃប្រជាជនពិភពលោក នៅមុនឆ្នាំ 1650 បណ្តាលមកពីមូលហេតុអ្វីខ្លះ ?
2. តើប្រជាជនពិភពលោកមានកំណើនដូចម្តេច ចាប់តាំងពីឆ្នាំ 1650 ដល់ 1950 ? មូលហេតុអ្វី ?
3. តើកំណើនប្រជាជនពិភពលោកមានដំណើរវិវត្តន៍ដូចម្តេច ចាប់តាំងពីឆ្នាំ 1950 មក ?
4. ដូចម្តេចហៅថា អន្តរភាពប្រជាសាស្ត្រ ?
5. តើរបបប្រជាសាស្ត្រប្រពៃណីនិងរបបប្រជាសាស្ត្រទំនើប មានលក្ខណៈខុសគ្នាដូចម្តេចខ្លះ ?
6. តើវគ្គទាំងពីរនៃអន្តរភាពប្រជាសាស្ត្រមានលក្ខណៈដូច ឬខុសគ្នាយ៉ាងណាខ្លះ ?
7. តើអ្នកយល់ថា ការមានកូនច្រើនជាភ័ព្វសំណាងសម្រាប់គ្រួសារនីមួយៗដែរឬទេ ?

មេរៀនទី

# 2 ប្រជាជនពិភពលោកនៅដើមសហស្សវត្សទី៣

ចប់មេរៀននេះ សិស្សអាច

- ពណ៌នាបានពីប្រជាជនពិភពលោកនៅដើមសហស្សវត្សទី 3 : ចំនួនប្រជាជនតាមតំបន់ធំៗ ប្រទេសដែលមានប្រជាជនច្រើនជាងគេ ។

ប្រទេសលោកខាងជើង បានឈានចូលសម័យប្រជាសាស្ត្រទំនើបហើយ ។ ចំណែកប្រទេសលោកខាងត្បូង មួយចំនួនតូចទើបតែបានឆ្លងផុតអន្តរភាពប្រជាសាស្ត្រ មួយចំនួនធំស្ថិតក្នុងវគ្គទី 2 នៃអន្តរភាព ក្នុងពេលដែលមួយចំនួនទៀតទើបតែឆ្លងវគ្គទី 1 នៅឡើយ ។ តើពីពេលនេះទៅមុខ តើពិភពលោកយើងនឹងស្ថិតក្នុងស្ថានភាពប្រជាសាស្ត្រមួយបែបណា ?

## 1. ការប៉ាន់ស្មានចំនួនប្រជាជនតាមតំបន់ធំៗ

តើអ្នកប្រជាសាស្ត្រ ធ្វើការប៉ាន់ស្មានចំនួនប្រជាជនពិភពលោកដោយរបៀបណា ? ចំណោលប្រជាសាស្ត្រប្រព្រឹត្តទៅដោយផ្អែកលើរូបមន្តគណិតសាស្ត្រ និងប្រើប្រាស់អត្រាកំណើនណាមួយជាគោល ។ លើសពីនេះ គេអាចគណនារយៈពេលកើនទ្វេនៃចំនួនប្រជាជនក្នុងប្រទេសមួយ តំបន់មួយ ឬក្នុងពិភពលោកទាំងមូល ។

ប្រជាជនពិភពលោកកើនឡើងឥតឈប់ឈរ មិនអាចទប់ទល់បានឡើយ ។ ភពផែនដី មានមនុស្សរស់នៅចំនួន 5 លាននាក់កាលពី 6 000 ឬ 7 000 ឆ្នាំមុន 250 លាននៅដើមសម័យយើងនេះ 1 ពាន់លាននាក់នៅឆ្នាំ 1800 3 ពាន់លាននៅឆ្នាំ 1960 6.5 ពាន់លាននៅឆ្នាំ 2006 ។ ចំនួននេះនឹងឡើងដល់ជាង 8 ពាន់លាននៅឆ្នាំ 2025 ។

សំទុះថេរនៃអត្រាកំណើនប្រជាសាស្ត្រ បង្កើតឱ្យមានលំនាំកំណើនមួយគួរឱ្យកង្វល់ ។ តាមពិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍសព្វថ្ងៃ ជំនាន់មនុស្សកំពុងធ្វើតំណពូជស្ថិតក្នុងក្រុមអាយុមួយ ដែលមានចំនួនច្រើនជាងកាលពីជំនាន់ឪពុកម្តាយរបស់ពួកគេ ។ គេត្រូវរង់ចាំប៉ុន្មានឆ្នាំទៀតទៀត ពេលកូនៗ

របស់ពួកគេគ្រប់អាយុរៀបការ ទើបគេអាចសង្កេតឃើញតំហាយចុះជាក់លាក់មួយនៃកំណើន ។ នៅទីបញ្ចប់ ផ្នែកមួយនៃពិភពលោក (ជាពិសេសមួយភាគធំនៃទ្វីបអាហ្វ្រិកនិងមជ្ឈិមបូព៌ា) មិនដែលស្គាល់អ្វីជាការកម្រិតកំណើតនៅឡើយ ហើយគេត្រូវរង់ចាំជាបន្តទៅទៀត ដើម្បីធ្វើឱ្យមរណប្រមាណថយចុះនៅក្នុងប្រទេសមួយចំនួនធំនៃលោកខាងត្បូង ។

ភាពចំណាស់នៃប្រជាជន ជាផលវិបាកបានមកពីតំហាយចុះនៃលទ្ធភាពបង្កកំណើតរបស់ស្ត្រី ។ នៅក្នុងប្រទេសអភិវឌ្ឍ គេមានក្តីបារម្ភពីឥទ្ធិពលនៃភាពចំណាស់ប្រជាជនដ៏លើសលប់មួយ ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍ គេត្រូវរងបន្ទុកដ៏ធ្ងន់នៃទម្រង់ប្រជាជនក្មេង (ចំនួនកុមារ មានច្រើនជាងមនុស្សពេញវ័យ) ។ ប៉ុន្តែប្រទេសកំពុងអភិវឌ្ឍនិងស្គាល់ភាពចំណាស់នៃប្រជាជនបានឆាប់រហ័ស នៅពេលជាតិប្រមាណមានតំហាយចុះយ៉ាងខ្លាំងតែប៉ុណ្ណោះ ។

## 2. ប្រទេសដែលមានប្រជាជនច្រើនជាងគេ

ក្នុងរយៈពេលមិនយូរប៉ុន្មានខាងមុខនេះ សង្វាក់កំណើនខុសៗគ្នា ធ្វើឱ្យផលធៀបរវាងតំបន់ប្រជាជនធំៗមានការប្រែប្រួល ។ ក្នុងមួយឆ្នាំៗ ប្រជាជនពិភពលោកកើនបានចំនួន 85 លាននាក់ដែលក្នុងចំនួននេះ ទ្វីបអឺរ៉ុបស្រូបយកបានតែ 1.7% ហើយអាមេរិកខាងជើងបាន 2.2% ទល់នឹង 65% សម្រាប់ទ្វីបអាស៊ី ទ្វីបអាហ្វ្រិក 20% និងអាមេរិកឡាទីន 11% ។ នៅប៉ុន្មានទសវត្សរ៍ខាងមុខនេះប្រជាជននៃប្រទេសអភិវឌ្ឍនឹងថយចុះយ៉ាងរហ័ស ពិសេសនៅទ្វីបអឺរ៉ុប ។ ចំណែកទ្វីបអាហ្វ្រិកនឹងត្រូវរងនូវទម្ងន់ប្រជាសាស្ត្រ ដែលកើនឡើងយ៉ាងសម្បើម បន្ទាប់មកគឺអាមេរិកឡាទីន ។ រីឯទ្វីបអាស៊ីវិញ ចំនួនប្រជាជននឹងស្ថិតនៅថេរ ។

ដូចគ្នានេះដែរចំណាត់ថ្នាក់រដ្ឋតាមចំនួនប្រជាជននឹងត្រូវប្រែប្រួល ។ នៅឆ្នាំ 2025 ចំនួនប្រជាជនចិន និងឥណ្ឌាមួយផ្នែក ជាមួយសហរដ្ឋអាមេរិកមួយផ្នែកទៀតនឹងបង្ហាញឱ្យឃើញពីគម្លាតរវាងគ្នាយ៉ាងច្បាស់ ។ ប្រទេសនីហ្សេរីយ៉ានឹងមានប្រជាជនច្រើនជាងសហរដ្ឋអាមេរិក ។ ប្រទេសប្រេស៊ីលប៉ាគីស្ថាននិងបង់ក្លាដែសនឹងមានប្រជាជនប្រហាក់ប្រហែលសហរដ្ឋអាមេរិកសព្វថ្ងៃ ។ ប្រទេសបារាំងនឹងមានប្រជាជនត្រឹមតែពាក់កណ្តាលប្រជាជន អេត្យូពី និងតិចជាងប្រទេសអេហ្ស៊ីប សាអៀ តង់សានី កេនយ៉ា ដែលសព្វថ្ងៃនេះខ្លួនមានច្រើនជាង ។

| ល.រ | ឈ្មោះប្រទេស | 1950 | ល.រ | ឈ្មោះប្រទេស | 1994 | ល.រ | ឈ្មោះប្រទេស | 2005 |
|---|---|---|---|---|---|---|---|---|
| 1 | ចិន | 554 | 1 | ចិន | 1192 | 1 | ចិន | 1315 |
| 2 | ឥណ្ឌា | 350 | 2 | ឥណ្ឌា | 911 | 2 | ឥណ្ឌា | 1103 |
| 3 | សហភាពសូវៀត | 180 | 3 | សហរដ្ឋអាមេរិក | 260 | 3 | សហរដ្ឋអាមេរិក | 298 |
| 4 | សហរដ្ឋអាមេរិក | 152 | 4 | ឥណ្ឌូណេស៊ី | 200 | 4 | ឥណ្ឌូណេស៊ី | 222 |
| 5 | ជប៉ុន | 84 | 5 | ប្រេស៊ីល | 155 | 5 | ប្រេស៊ីល | 186 |
| 6 | ឥណ្ឌូណេស៊ី | 80 | 6 | រុស្ស៊ី | 150 | 6 | ប៉ាគីស្ថាន | 158 |
| 7 | ប្រេស៊ីល | 53 | 7 | ប៉ាគីស្ថាន | 126 | 7 | រុស្ស៊ី | 143 |
| 8 | អង់គ្លេស | 51 | 8 | ជប៉ុន | 125 | 8 | បង់ក្លាដែស | 142 |
| 9 | អាល្លឺម៉ង់ខាងលិច | 50 | 9 | បង់ក្លាដែស | 117 | 9 | នីហ្សេរីយ៉ា | 131 |
| 10 | អ៊ីតាលី | 47 | 10 | នីហ្សេរីយ៉ា | 98 | 10 | ជប៉ុន | 128 |
| 11 | បារាំង | 42 | 11 | ម៉ិកស៊ិក | 92 | 11 | ម៉ិកស៊ិក | 107 |
| 12 | បង់ក្លាដែស | 42 | 12 | អាល្លឺម៉ង់ | 81 | 12 | វៀតណាម | 87 |
| 13 | ប៉ាគីស្ថាន | 40 | 13 | វៀតណាម | 73 | 13 | ហ្វីលីពីន | 83 |
| 14 | នីហ្សេរីយ៉ា | 33 | 14 | ហ្វីលីពីន | 69 | 14 | អាល្លឺម៉ង់ | 82 |
| 15 | វៀតណាម | 28 | 15 | តួកគី | 62 | 15 | អេត្យូពី | 77 |
| 16 | អេស្ប៉ាញ | 28 | 16 | អ៊ីរ៉ង់ | 61 | 16 | អេហ្ស៊ីប | 74 |
| 17 | ម៉ិកស៊ិក | 27 | 17 | ថៃ | 60 | 17 | តួកគី | 73 |
| 18 | ប៉ូឡូញ | 25 | 18 | អេហ្ស៊ីប | 59 | 18 | អ៊ីរ៉ង់ | 69 |
| 19 | ហ្វីលីពីន | 21 | 19 | អ៊ីតាលី | 58 | 19 | ថៃ | 64 |
| 20 | តួកគី | 21 | 20 | អង់គ្លេស | 58 | 20 | បារាំង | 60 |
| 21 | ថៃ | 20 | 21 | បារាំង | 58 | 21 | រាជាណាចក្ររួម | 59 |
| 22 | កូរ៉េខាងត្បូង | 20 | 22 | អេត្យូពី | 55 | 22 | អ៊ីតាលី | 58 |
| 23 | អេហ្ស៊ីប | 20 | 23 | អ៊ុយក្រែន | 51 | 23 | កុងហ្គោ(ឃីនសាសា) | 57 |
| 24 | អាល្លឺម៉ង់ខាងកើត | 18 | 24 | កូរ៉េខាងត្បូង | 45 | 24 | មីយ៉ាន់ម៉ា | 50 |
| 25 | មីយ៉ាន់ម៉ា | 18 | 25 | មីយ៉ាន់ម៉ា | 45 | 25 | កូរ៉េខាងត្បូង | 47 |

*ប្រទេស 25 ដែលមានប្រជាជនច្រើនជាងគេលើពិភពលោក(ជាលាននាក់)*

## 3. ការវិវត្តប្រជាសាស្ត្រ

នៅឆ្នាំ2050 ប្រជាជនពិភពលោកនឹងមានប្រហែល9ពាន់លាននាក់ ខុសគ្នាពីចំនួន15ពាន់នាក់ ដែលគេបានផ្សព្វផ្សាយកាលពី50ឆ្នាំមុន ។

តំហយល្បឿននៃកំណើនប្រជាជន ជាប់ទាក់ទងជាសំខាន់ទៅនឹងកម្រិតទាបនៃលទ្ធភាពបង្ក កំណើត ។ សន្ទស្សន៍មធ្យមនៃលទ្ធភាពបង្កកំណើតក្នុងពិភពលោកនឹងត្រូវស្ថិតនៅក្រោមបន្ទាត់នៃតំណ ជំនាន់មនុស្ស (1.8នាក់ទល់នឹង2.1នាក់សម្រាប់ស្ត្រីម្នាក់) ។ ជានិច្ចកាល ប្រទេសជាច្រើននៅអាហ្វ្រិក និងមជ្ឈិមបូព៌ាមានសន្ទស្សន៍មធ្យមលើសពី4នាក់ ។ អាស្រ័យហេតុនេះ ទ្វីបអាហ្វ្រិកនឹងមានប្រជាជន កើនឡើងជិតពីរដង គឺដល់ទៅ1.5ពាន់លាននាក់ ពីឥឡូវនេះទៅទល់ឆ្នាំ2050 ។ មែនហើយ នយោបាយ"កូនទោល"បានធ្វើឱ្យអត្រាជាតិប្រមាណរបស់ចិនចុះមកនៅត្រឹម 1.3% អាចប្រៀបបានទៅ និងប្រទេសបារាំង(1.2%)តែភាគច្រើននៃប្រជាជនចិននៅតែក្មេង(ទម្រង់ក្មេងនៃប្រជាជន) ។

## 4. ប្រាំបួនពាន់លាននាក់នៅឆ្នាំ 2050

ភពផែនដីនឹងមានប្រជាជនរស់នៅចំនួនប្រហែល9ពាន់លាននាក់នៅឆ្នាំ2050 ទល់នឹង6.5ពាន់ លាន ក្នុងពេលបច្ចុប្បន្ន ។

ជានិច្ចជាកាលនិន្នាការទូទៅ គឺកាត់បន្ថយល្បឿននៃកំណើនប្រជាសាស្ត្រ ធៀបទៅនឹងកំណើន កាលពី20ទៅ50ឆ្នាំមុននេះ ដែលជួយគាំទ្រឱ្យមានស្ថិរភាពប្រជាសាស្ត្រពិភពលោកយ៉ាងយឺតៗមួយ ។

នៅក្នុងប្រទេសឧស្សាហកម្ម លើកលែងតែសហរដ្ឋអាមេរិកចេញ ការមកដល់នៃអន្តោប្រវេសន៍ បណ្តាលឱ្យមានកំណើនប្រជាសាស្ត្រមួយ តែមិនបង្កើតឱ្យមានជំនាន់មនុស្សថ្មីសោះឡើយ ។ ក្នុង លក្ខខណ្ឌទាំងនេះ ប្រជាជនប្រទេសលោកខាងជើង ដែលសព្វថ្ងៃមានចំនួន1.2ពាន់លាននាក់ និងមិន ត្រូវកើនឡើងទៀតទេ រហូតដល់ឆ្នាំ2050 ។ អង្គការសហប្រជាជាតិ(ONU) ប៉ាន់ស្មានថា នឹងមាន តំហយប្រជាសាស្ត្រនៅប្រទេសអាល្លឺម៉ង់ អ៊ីតាលី រុស្ស៊ី និងនៅប្រទេសដទៃទៀត ដែលបែកចេញពី សហភាពសូវៀត ។ ផ្ទុយទៅវិញ ប្រជាជនប្រទេសក្រីក្រនឹងកើនឡើងពីឥឡូវទៅឆ្នាំ2050 ពី 5.3ពាន់ លានទៅ 7.8ពាន់លាន ។ នេះជាសំខុះប្រជាសាស្ត្រដែលពន្យល់ដោយ អង្គការសហប្រជាជាតិ ។

## ? សំណួរ

1. ចូរឱ្យនិយមន័យនៃពាក្យ ភាពចំណាស់នៃប្រជាជន លទ្ធភាពបង្កកំណើត អត្រាកំណើនធម្មជាតិ ។
2. តើប្រទេសអភិវឌ្ឍនិងកំពុងអភិវឌ្ឍមានបញ្ហាប្រជាសាស្ត្រដូចគ្នាដែរឬទេ ? ចូរពន្យល់ ។
3. តើសង្វាក់កំណើនប្រជាជនខុសៗគ្នា នាំមកនូវផលវិបាកអ្វីខ្លះ?
4. តាមរូបមន្តរយៈពេលកើនទ្វេ : $D = \frac{70}{A}$ ចូរគណនា រយៈពេលកើនទ្វេនៃប្រជាជនកម្ពុជា កាលណាអត្រាកំណើននៃប្រជាជនកម្ពុជា $A = 2.4\%$ ។

មេរៀនទី

# 3 របាយប្រជាជនពិភពលោក

ចប់មេរៀននេះ សិស្សអាច

- រៀបរាប់ពីរបាយប្រជាជនពិភពលោក : បណ្តុំប្រជាជនសំខាន់ៗ មជ្ឈមណ្ឌលមានដង់ស៊ីតេខ្ពស់ និងមានប្រជាជនមធ្យម ។

ភពផែនដីមានមនុស្សរស់នៅមិនស្មើគ្នាទេ តំបន់ខ្លះមានមនុស្សរស់នៅកុះករ តំបន់ខ្លះជាវាលរហោឋាន តំបន់ខ្លះមានមនុស្សរស់នៅជាមធ្យម និងតំបន់ខ្លះមានមនុស្សរស់នៅតិចតួច ។ សូម្បីតែនៅក្នុងប្រទេសមួយ ក៏មានរបាយប្រជាជនមិនស្មើគ្នាដែរ ។ តើបាតុភូតទាំងនេះ កើតមាននៅទីណាខ្លះ? ហើយអាស្រ័យនឹងកត្តាអ្វីខ្លះ ?

## 1. បណ្តុំប្រជាជនសំខាន់ៗ

បណ្តុំប្រជាជនសំខាន់ៗមានបីស្ថិតនៅទ្វីបអឺរ៉ុប តាមវាលទំនាប និងដីសណ្តមិនជាឆ្ងាយប៉ុន្មានពីឆ្នេរ មានប្រជាជនសរុបជាង 1/2 នៃប្រជាជនពិភពលោក ដែលជាទីទាក់ទាញបំផុត ព្រោះទីទាំងនោះមាននាទីជាអ្នកចិញ្ចឹមជីបាច់ នាំមកនូវអាកាសធាតុដ៏បរិសុទ្ធនិងមនោរម្យ ព្រមទាំងផ្តល់លទ្ធភាពពាណិជ្ជកម្មទៀតផង ។

### 1.1. តំបន់ឆ្នេរខាងកើតនៃទ្វីបអាស៊ី

តំបន់នេះលាតសន្ធឹងពីទំនាបចិនភាគខាងជើងរហូតដល់វៀតណាម រួមទាំងហ្វីលីពីននិងឥណ្ឌូណេស៊ីផង ប្រមូលផ្តុំមនុស្សជាង 1.7 ពាន់លាននាក់ លើផ្ទៃដីប្រមាណ 5.7 លាន $km^2$ ។

នៅតាមជនបទ មានដង់ស៊ីតេខ្ពស់បំផុតជាង 500 នាក់ / $km^2$ ត្រង់ទំនាបចិនភាគខាងជើងនិងជាង 1 000 នៅតាមដងស្ទឹងគជ (ទន្លេស៊ីជាំង) ។

នៅតាមបណ្តុំក្រុងធំៗមានមនុស្សច្រើនលាននាក់ដូចជាតូក្យូ (30 លាននាក់) សៀងហៃ (15 លាននាក់) ប៉ីជីន ឬ ប៉េកាំង (12 លាននាក់) សេអ៊ូល (12 លាន) អូសាកា (10 លាន) ធៀនជិន

(10លាន) ... ។ មេកាឡូប៉ូលជប៉ុន លាតសន្ធឹងតាមបណ្តោយឆ្នេរភាគខាងត្បូងកោះហុងស៊ូ ពីតូក្យូ ដល់ភូគូអូកា (កោះគ្យូស្យូ) ប្រមូលផ្តុំមនុស្សប្រមាណជាង 100លាននាក់ ។ ជប៉ុន កូរ៉េខាងត្បូង និង តៃវ៉ាន់ មានប្រជាជនក្រុងច្រើន ចំណែកចិន និងវៀតណាម មានប្រជាជនជនបទច្រើននៅឡើយ ។

## 1.2. ឧបទ្វីបឥណ្ឌា

តំបន់នេះជារួមមានប្រទេសឥណ្ឌា (1 103លាននាក់) បង់ក្លាដែស (141.8លាននាក់) ប៉ាគីស្ថាន (157.9លាន) ស្រីលង្កា (20.7លាន) ... ប្រមូលផ្តុំមនុស្សប្រមាណជា 1.4ពាន់លាននាក់(ឆ្នាំ 2005)លើផ្ទៃដីប្រហែល 4.4លាន$km^2$ ។ នៅទីនោះក៏ដូចជាតំបន់ខាងលើដែរ ទំនាបជាកន្លែងប្រមូលផ្តុំប្រជាជនច្រើនជាងគេ (ទំនាប ឥណ្ឌុស-គង្គា) ។ ដីសណ្តរួមរវាងទន្លេគង្គា និងទន្លេព្រហ្មបុត្រ ជាកន្លែងដែលមានប្រជាជនច្រើនជាងគេបំផុតនៃឧបទ្វីបឥណ្ឌា ។ ប៉ុន្តែទីនោះក៏ជាកន្លែងប្រកបដោយគ្រោះថ្នាក់ជាងគេដែរ ពីព្រោះមានព្យុះស៊ីក្លូន និងទឹកជំនន់ជាញឹកញាប់ ។ ទីក្រុងមួយចំនួន បន្តរីកចម្រើនយ៉ាងរហ័ស ដូចជាមុមបៃ កាល់កត្តា ញូដេលី ម៉ាដ្រាស នៅប្រទេសឥណ្ឌា ដាកានៅបង់ក្លាដែស និងការ៉ាជីនៅប៉ាគីស្ថាន ។ នៅតាមជនបទ ដង់ស៊ីតេប្រជាជនខ្ពស់ជាងនៅប្រទេសចិន គឺជាង 800នាក់/$km^2$ ។ ចំណែកក្រុងវិញ មានត្រឹមតែ 1/5នៃប្រជាជនសរុបប៉ុណ្ណោះ ។ នៅឆ្នាំ 2025 ប្រជាជនឥណ្ឌានឹងកើនលើសប្រជាជនចិន ។

## 1.3. ទ្វីបអឺរ៉ុប

តំបន់នេះ មានដំណុះប្រជាជននិងមានដង់ស៊ីតេ មិនសូវសំខាន់ដូចតំបន់ទាំងពីរខាងលើទេ តែមានទីក្រុងច្រើនប្រមូលផ្តុំមនុស្ស 650លាននាក់លើផ្ទៃដីប្រហែល 2លាន$km^2$ ។ ដង់ស៊ីតេប្រជាជនមានលើស 300នាក់/$km^2$ ដោយកម្រ ។ នៅតំបន់ជនបទ ដង់ស៊ីតេមានមិនលើស 100នាក់/$km^2$ ។ ទីក្រុងធំៗ មានដូចជាម៉ូស្គូ ប៉ារីស ឡុង តំបន់រួ ប៉ុន្តែទីក្រុងតូចៗនិងមធ្យមក៏មានច្រើនដែរ ។ ដង់ស៊ីតេប្រជាជនមានកម្រិតខ្ពស់បំផុតនៅតាមទ្រនុងខ្សែបន្ទាត់កណ្តាលនៃទ្វីបអឺរ៉ុប គឺជាមេកាឡូប៉ូលធំបំផុតក្នុងលោក លាតសន្ធឹងពីតំបន់មីតឡិន (ប៉ែកអាគ្នេយ៍ប្រទេសអង់គ្លេស) ដល់ទំនាបប៉ូ (ប៉ែកខាងជើងប្រទេសអ៊ីតាលី) កាត់តាមប្រទេសប៊ែលហ្ស៊ិច ពេអ៊ីបា អាល្លឺម៉ង់ប៉ែកខាងលិច និងស្វ៊ីស ប្រមូលផ្តុំប្រជាជន 125លាននាក់ ។ តំបន់ខាងលិចនិងខាងកើត ខ្សែបន្ទាត់នេះមានដង់ស៊ីតេមធ្យម ។ ជាទូទៅបណ្តុំប្រជាជនទ្វីបអឺរ៉ុប មានកម្រិតជីវភាពនិងនគរូបនីយកម្មខ្ពស់ ។

## 2. មជ្ឈមណ្ឌលដែលមានដង់ស៊ីតេខ្ពស់ តែមានទំហំតូច

គេឃើញមានមជ្ឈមណ្ឌលតូចៗជាច្រើនកន្លែង តែមានដង់ស៊ីតេប្រជាជនខ្ពស់ ។

### 2.1. នៅទ្វីបអាស៊ី

យោងតាមទិន្នន័យឆ្នាំ 2005 កោះតៃវ៉ាន់ មានមនុស្សរស់នៅចំនួន 23 លាននាក់ គិតជាដង់ស៊ីតេមធ្យមមាន 627 នាក់/ $km^2$ ភាគច្រើនជាប្រជាជនក្រុង (75%) ។ ប្រទេសសិង្ហបុរី មានប្រជាជន 4.3 លាននាក់ គិតជាដង់ស៊ីតេមាន 7 166.6 នាក់/ $km^2$ មានសុទ្ធតែប្រជាជនក្រុងទាំងអស់ (100%) ។ ប្រទេសហ្វីលីពីន ជាកម្រងកោះភ្នំមួយទៀត មានប្រជាជនទាំងអស់ 80 លាននាក់ គិតជាដង់ស៊ីតេមធ្យមមាន 277 នាក់/ $km^2$ មានប្រជាជនក្រុង 61.8% ។

### 2.2. នៅទ្វីបអាហ្វ្រិក

បណ្តុំមនុស្សច្រើនជាងគេ ស្ថិតនៅតាមជ្រលងនិងដីសណ្តទន្លេនីលនៃប្រទេសអេហ្ស៊ីប (1 500 នាក់/ $km^2$ ) ។ ការងារនគរូបនីយកម្មមិនទាន់ខ្លាំងក្លា ប៉ុន្តែមានការឈានឡើង ហើយមានបណ្តុំក្រុងមួយបានកកើតឡើងនៅគែ (រដ្ឋធានីអេហ្ស៊ីប) ។

ប្រទេសនីហ្សេរីយ៉ា មានមជ្ឈមណ្ឌលបីដែលមានដង់ស៊ីតេប្រជាជនខ្ពស់គឺ ហាអ៊ូសានៅខាងជើង យោរូបានៅខាងនិរតី និងអ៊ិចបូនៅខាងអាគ្នេយ៍ ។ មជ្ឈមណ្ឌលនិរតីបានទទួលនគរូបនីយកម្ម ព្រោះមានទីប្រជុំក្រុងមួយដ៏ធំសម្បើម គឺឡាកូស ។

អាហ្វ្រិកនៃតំបន់បឹងធំ មានមណ្ឌលតូចៗមួយចំនួនដែលមានដង់ស៊ីតេខ្ពស់ ដូចជារ្វ៉ាន់ដា ប៊ូរុនឌី អ៊ូកង់ដា និងកេនយ៉ា ។

## 3. លំហមានប្រជាជនមធ្យម

### 3.1. អាមេរិកខាងជើង




កំណត់សំគាល់ : ◉ ទីក្រុងច្រើនជាង 2 លាននាក់ • ទីក្រុងពី 0.5 ទៅ 2 លាននាក់

*មេកាឡូប៉ូល អឺរ៉ុប អាមេរិក និងជប៉ុន*

សំណុំនេះ មានសហរដ្ឋអាមេរិក និងកាណាដាដែលមានប្រជាជន 330.48 លាននាក់ (ឆ្នាំ 2005) រស់នៅលើផ្ទៃដីដ៏ធំទូលាយនាតំបន់បឹងធំនិងភាគខាងកើតសហរដ្ឋអាមេរិក ។ នគរូបនីយកម្ម មានកម្រិតខ្ពស់ណាស់ ទីក្រុងដែលមានប្រជាជនលើសពី 1 លាននាក់ មានចំនួន 130 និងមេកាប៉ូលសំខាន់ពីរ ។ មេកាប៉ូលអាត្លង់ទិក លាតសន្ធឹងពីបស្តុនដល់វ៉ាស៊ីនតោន មានប្រជាជនជិត 100 លាននាក់ ។

## 3.2. អាមេរិកឡាទីន

អាមេរិកឡាទីន ជាអតីតទឹកដីអាណានិគមរបស់ប្រទេសអេស្ប៉ាញនិងព័រទុយហ្គាល់ រួមមានប្រទេសម៉ិកស៊ិក អាមេរិកកណ្តាល និងអាមេរិកខាងត្បូង ។ ប្រទេសម៉ិកស៊ិកនិងអាមេរិកកណ្តាលមានដង់ស៊ីតេប្រជាជនញឹក (160 នាក់/ $km^2$ ) ។ នៅអាមេរិកខាងត្បូង តាមបណ្តោយឆ្នេរអាត្លង់ទិក គេឃើញមានទីក្រុងធំៗ ដូចជាសាវប៉ូឡូ រីយ៉ូដឺសានេរ៉ូ និងប៊ុយអេណូស៊ែ ។ ព្រៃអាម៉ាសូន (ឋាននរកបៃតង) ជាទឹកដីដ៏ធំទូលាយ គ្របដណ្តប់ទៅដោយព្រៃស្តុក ខ្សត់មនុស្សរស់នៅ ។

## 3.3. ទ្វីបអាហ្វ្រិក

ក្រៅពីប្រទេសអេហ្ស៊ីប នីហ្សេរីយ៉ា និងប្រទេសតំបន់បឹងធំចេញ ទ្វីបអាហ្វ្រិកនៅមានដង់ស៊ីតេប្រជាជនទាបនៅឡើយ ដូចជាម៉ាដាកាស្កា (31.7 នាក់/ $km^2$ ) ម៉ូសំប៊ិច (24.7 នាក់/ $km^2$ ) អង់កូឡា (12.8 នាក់/ $km^2$ ) កាបុង (5.2 នាក់/ $km^2$ ) បុតស្វាណានិងម៉ូរីតានី (3 នាក់/ $km^2$ ) និងណាមីប៊ី (2.5 នាក់/ $km^2$ ) នៅឆ្នាំ 2005 ។ គេឃើញមានដង់ស៊ីតេខ្ពស់ជាងនេះ នៅទំនាបម៉ាក្រិប ប្រទេសម៉ារ៉ុក នៅកាប៊ីលី ប្រទេសអាល់ហ្សេរី មណ្ឌលបណ្តុំរ៉ែ មណ្ឌលឧស្សាហកម្ម និងក្រុងវិតវ៉ាទេស្រ៉ិន នៅអាហ្វ្រិកខាងត្បូង ។

## ? សំណួរ

1. តើបណ្តុំប្រជាជនធំៗ ក្នុងពិភពលោកមាននៅទីណាខ្លះ ?
2. ចូរនិយាយអំពីបណ្តុំប្រជាជន តំបន់ឆ្នេរខាងកើតនៃទ្វីបអាស៊ី ។
3. ចូរកំណត់ន័យនៃពាក្យ បណ្តុំប្រជាជន មេកាឡូប៉ូល ។
4. តើ "ទ្រនុងកណ្តាលនៃទ្វីបអឺរ៉ុប" ជាអ្វី ? ចូរពន្យល់ ។
5. ចូរប្រៀបធៀប បណ្តុំប្រជាជនអាស៊ីបូព៌ានិងបណ្តុំប្រជាជនអាស៊ីទក្សិណ ។
6. ចូរនិយាយអំពីបណ្តុំប្រជាជនសំខាន់ៗនៃទ្វីបអាហ្វ្រិក ។
7. តើតំបន់បឹងធំៗក្នុងពិភពលោក មាននៅទីណាខ្លះ ? ចូររាប់ឈ្មោះបឹងទាំងនោះ ។

## ? សំណួរបញ្ចប់ជំពូកទី៤

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់មុខចម្លើយត្រូវតែមួយគត់

1. កាលពីឆ្នាំ 1347 ដល់ 1351 មនុស្សលោកស្លាប់អស់ 25 លាននាក់ដោយសារ

☐ ក. សង្គ្រាម ☐ ខ. ជំងឺអាសន្នរោគ

☐ គ. ជំងឺប៉េស្តខ្មៅ ☐ ឃ. ជំងឺអុត

2. ចំនួនកូនជាមធ្យមដែលស្ត្រីម្នាក់អាចបង្កើតបាននៅដំណាក់បន្តពូជហៅថា

☐ ក. អត្រាជាតិប្រមាណ ☐ ខ. អត្រាកំណើនវិជ្ជមាន

☐ គ. អត្រាលទ្ធភាពបង្កកំណើត ☐ ឃ. អត្រាកំណើនអវិជ្ជមាន

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. វិធានការទប់កំណើនប្រជាជន ដែលលើកឡើងនិងដាក់ឱ្យអនុវត្តនៅប្រទេសចិនមានឈ្មោះថា .................................................. ។

2. ដំណើរឆ្លងកាត់ពីរបបប្រជាសាស្ត្រប្រពៃណី ទៅរបបប្រជាសាស្ត្រទំនើបហៅថា ................ ។

3. ភាពចំណាស់នៃប្រជាជន ជាលទ្ធផលបានមកពីតំហយចុះនៃ ............................ របស់ស្ត្រី ។

4. បណ្តុំប្រជាជននៃទ្វីបអឺរ៉ុប មានដង់ស៊ីតេខ្ពស់បំផុតទៅតាម ................................... ។

III. សំណួរ

1. តើកំណើនទាបនៃប្រជាជនពិភពលោកនៅមុនឆ្នាំ 1650 បណ្តាលមកពីមូលហេតុអ្វីខ្លះ ?

2. តើប្រទេសលោកខាងជើងនិងប្រទេសលោកខាងត្បូង មានបញ្ហាប្រជាសាស្ត្រដូចគ្នាដែរឬទេ ? ចូរពន្យល់ ។

3. តើគេអាចធ្វើចំណោលប្រជាសាស្ត្រដោយរបៀបណា ? ដើម្បីអ្វី ?

4. អ្នកប្រជាសាស្ត្រអះអាងថា "នៅឆ្នាំ 2050 ខាងមុខ ប្រទេសឥណ្ឌានឹងមានប្រជាជនច្រើនជាងចិន"

ក. តើការគន់គូរទុកជាមុននេះ ផ្អែកលើមូលដ្ឋានអ្វី ? មានប្រយោជន៍អ្វី ?

ខ. តើប្រទេសឥណ្ឌា អាចដោះស្រាយបញ្ហាចិញ្ចឹមប្រជាជនដ៏ច្រើនលើសលប់នេះ បានដែរឬទេ ? ព្រោះអ្វី ? ចូរពន្យល់ ។

# ជំពូកទី 5 នគរូបនីយកម្មនិងបញ្ហា




*ការរៀបចំក្រុងនៅស៊ាងហៃ ប្រទេសចិន*

នគរូបនីយកម្ម គឺជាការងាររៀបចំឬពង្រីកក្រុង និងជាការប្រមូលផ្តុំប្រជាជនរស់នៅក្នុងក្រុងផងដែរ ។ អត្រានគរូបនីយកម្ម បង្ហាញភាគរយនៃប្រជាជនដែលរស់នៅក្នុងក្រុងរបស់ប្រទេសមួយ ឬតំបន់មួយ ។ នគរូបនីយកម្ម អាចជួយសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ច ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍ (P.V.D) តែងកើតមានបញ្ហាទីក្រុងថ្មីៗ ឬអតីតទីក្រុងអាណានិគម ដែលមិនបានរៀបចំទទួលយកការហូរចូលយ៉ាងច្រើននៃប្រជាជន ពិសេសប្រជាជនជនបទក្រីក្រ ។ កំណើនប្រជាជននៅទីក្រុងខ្ពស់ជាងនៅស្រុកស្រែ ដោយសារអត្រាមរណប្រមាណមានតំហយចុះ ។ ចំណោលស្រុកស្រែ មកកាន់ទីក្រុង រួមចំណែកបានពាក់កណ្តាលក្នុងការធ្វើឱ្យមានកំណើនប្រជាជនក្រុង ។ កំណើនប្រជាជននិងសកម្មភាពនានានៅក្នុងទីក្រុងតែងចោទជាបញ្ហាដែលរដ្ឋអំណាចក្រុងត្រូវតែប្រឈមមុខដោះស្រាយ ។

មេរៀនទី

# 1 បន្ទុះប្រជាជនក្រុងនៅប្រទេសកំពុងអភិវឌ្ឍ

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ពីបន្ទុះប្រជាជនក្រុង នៅប្រទេសកំពុងអភិវឌ្ឍ : បន្ទុះទីក្រុងនិងផលវិបាក ។

នៅប្រទេសកំពុងអភិវឌ្ឍ (P.V.D) កំណើនប្រជាជនក្រុងបានមកពីកំណើនធម្មជាតិនិងចលនាចំណោលស្រុកស្រែ ។ ប្រទេសអភិវឌ្ឍ មានអត្រាកំណើនប្រជាជនក្រុងទាបជាងប្រទេសកំពុងអភិវឌ្ឍ ។ សព្វថ្ងៃ មនុស្សលោកចំនួនជិតពាក់កណ្ដាលរស់នៅទីក្រុង ហើយចំនួននេះនឹងបន្តកើនឡើងទៀត ។ កំណើនក្រុងមានបន្ទុះខ្លាំងណាស់ នៅប្រទេសលោកខាងត្បូង តែយឺតបំផុតនៅប្រទេសលោកខាងជើង ។ បញ្ហាសេដ្ឋកិច្ចសង្គមនិងចិត្តសាស្ត្រ ជាកត្តាជំរុញឱ្យប្រជាជនចូលទៅរស់នៅទីក្រុងកាន់តែច្រើនឡើងៗ ។

## 1. បន្ទុះទីក្រុងខ្លាំងក្លាណាស់នៅប្រទេសកំពុងអភិវឌ្ឍ

### 1.1. ចង្វាក់នគរូបនីយកម្មខុសគ្នាខ្លាំង

តាមពិត ប្រទេសលោកខាងជើងបានបញ្ចប់អន្តរភាពទីក្រុងរួចរាល់ហើយ ។ អត្រានគរូបនីយកម្ម មានកម្រិតខ្ពស់ ទីក្រុងមានចំនួនច្រើន ប៉ុន្តែការលូតលាស់ក្រុងខ្សោយ (មានជាង 3% សម្រាប់ទីក្រុងញូយ៉កនិងទាបជាង 5% សម្រាប់ទីក្រុងម៉ូស្គូ នៅចន្លោះឆ្នាំ 1990 និង 2000) ។ ទោះបីកំណើនធម្មជាតិនៅទីក្រុង មានកម្រិតខ្ពស់ជាងនៅជនបទក៏ដោយ ក៏នៅក្រោយសម័យដ៏វែងមួយនៃចំណោលស្រុកស្រែ អ្នកទីក្រុងនៃប្រទេសអភិវឌ្ឍសព្វថ្ងៃនេះ បានទទួលភាពអនុគ្រោះពីលំហបរិមណ្ឌលក្រុង ដែលអាចឱ្យពួកគេគេចចេញពីមណ្ឌលកណ្ដាលក្រុង ពីទីប្រជុំជនក្រុង និងពីបញ្ហាចោទទាំងឡាយ ។

### 1.2. ការលូតលាស់យ៉ាងសំខាន់នៃទីក្រុង

ការរីកលូតលាស់នេះ កើតមាននៅប្រទេសលោកខាងត្បូង (ជាង 18% សម្រាប់ទីក្រុងម៉ិកស៊ិកូ និងជាង 64% សម្រាប់ទីក្រុងឃីនសាសា នៅចន្លោះឆ្នាំ 1990 និង 2000) ។ ពិតមែនហើយ ដែលថាអត្រានគរូបនីយកម្មនៅទីនោះ មានកម្រិតទាបបំផុត ទីក្រុងមានចំនួនតិចតួច (ទ្វីបអាហ្វ្រិក) អ្នក

ប្រជាសាស្ត្រនៅតែចាត់ទុកការវិវត្ត ដែលកើតមានថា ជាបន្ទុះទីក្រុង ។ តាមអ្នកប្រជាសាស្ត្រទាំងនោះ អត្រាកំណើនប្រជាជនក្រុង មានកម្រិតខ្ពស់ណាស់នៅគ្រប់ទីកន្លែងនិងកំពុងថយចុះ បើធៀបទៅនឹងបណ្តាឆ្នាំ 60-70 ។ ប៉ុន្តែ ជាមួយនឹងចង្វាក់កំណើន 3% ក្នុងមួយឆ្នាំ ដែលខ្ពស់ជាងនៅស្រុកស្រែបើដង នាំឱ្យចំនួនប្រជាជនក្រុងនៃប្រទេស P.V.D កើនទ្វេដងក្នុងរយៈពេល 22ឆ្នាំ ។ នៅឆ្នាំ 2010 ប្រទេសចិននឹងមានប្រជាជនក្រុងចំនួន 694លាននាក់ ច្រើនជាងប្រជាជនក្រុងសហរដ្ឋអាមេរិក រួមទាំងសហភាពអឺរ៉ុបផង ។

| | អត្រានគរូបនីយកម្ម (%) | | ចំនួនទីក្រុង ដែល>5លាននាក់ | |
|---|---|---|---|---|
| | 1950 | 2010 | 1950 | 2010 |
| អាហ្វ្រិក | 14.9 | 42.4 | 0 | 5 |
| អាមេរិកឡាទីនការ៉ាអ៊ិប | 41.9 | 79.4 | 1 | 7 |
| អាស៊ី | 16.6 | 48.7 | 2 | 34 |
| អាមេរិកខាងជើង | 63.9 | 82.9 | 1 | 4 |
| អឺរ៉ុប | 51.2 | 74.2 | 4 | 5 |
| អូសេអានី | 60.6 | 73.7 | 0 | 0 |
| ពិភពលោក | 29.1 | 51.3 | 8 | 55 |

*ទិន្នន័យស្តីពីនគរូបនីយកម្មនិងទីក្រុងក្នុងតំបន់ធំៗនៃពិភពលោក*

| ទីក្រុង | ចំនួនប្រជាជន | ទីក្រុង | ចំនួនប្រជាជន |
|---|---|---|---|
| តូក្យូ | 35 | ចាកាតា | 12.3 |
| ម៉ិកស៊ិកូ | 18.7 | ឡូសអង់សឺឡែស | 12 |
| ញូយ៉ក | 18.3 | ដាកា | 11.6 |
| សាវប៉ូឡូ | 17.9 | អូសាកា-ខូបេ | 11.2 |
| មុមបៃ | 17.4 | រីយ៉ូដឺសាណេរ៉ូ | 11.2 |
| ដេលី | 14.1 | ការ៉ាជី | 11.1 |
| កាល់កុត្តា | 13.8 | កៃរ | 10.8 |
| ប៊ុយអេណូស៊ែ | 13 | ម៉ូស្គូ | 10.5 |
| ស៊ាងហៃ | 12.8 | ម៉ានីល | 10.4 |

*ទីប្រជុំជនធំៗក្នុងពិភពលោក (លាននាក់)*

| | 1940 | 1950 | 1980 | 1995 | ប៉ាន់ស្មាន 2025 |
|---|---|---|---|---|---|
| ប្រទេសអភិវឌ្ឍ : | 202 | 388 | 768 | 865 | 1 140 |
| អឺរ៉ុប | 133 | 193 | 325 | 390 | 410 |
| អាមេរិកខាងជើង | 41 | 12 | 159 | 219 | 285 |
| ប្រទេសកំពុងអភិវឌ្ឍ (PVD) : | 120 | 262 | 933 | 1 585 | 3 860 |
| អាហ្វ្រិក | 9 | 22 | 116 | 223 | 820 |
| អាមេរិកឡាទីន | 18 | 66 | 232 | 336 | 710 |
| អាស៊ី | 93 | 174 | 585 | 1 026 | 2 330 |
| សរុប : | 322 | 650 | 1 701 | 2 450 | 5 000 |

*ការវិវត្តនៃប្រជាជនក្រុងក្នុងពិភពលោក (លាននាក់)*

## 1.3. ចំណោលស្រុកស្រែ

ចលនាចំណោលស្រុកស្រែ បានជួយពង្រឹងកម្លាំងដល់កំណើនធម្មជាតិផ្ទាល់នៅទីក្រុង ។ ប្រជាជនជនបទ ចាកចោលស្រុកស្រែ ដោយសារសម្ពាធប្រជាសាស្ត្រ និងឧស្សាហូបនីយកម្មទៅលើវិស័យកសិកម្ម និងទាក់ទាញដោយក្តីសង្ឃឹមថានឹងរកបានការងារធ្វើនៅទីក្រុង ហើយនឹងមានជីវភាពប្រសើរជាង ។ ស្ទើរតែពាក់កណ្តាលនៃប្រជាជនក្រុងសាវប៉ូឡូ មានកំណើតកើតនៅទីឆ្ងាយៗ ។ ទោះបីនៅទីក្រុងមានបញ្ហាច្រើនក្តីក៏ការទទួលបានគ្រឿងបរិក្ខារនិងសេវាមូលដ្ឋាន (ទឹក អគ្គិសនី សុខាភិបាល អប់រំ ...) មានលក្ខណៈល្អប្រសើរជាងនៅស្រុកស្រែដែរ ។



*ប្រភព : អ.ស.ប 2005*

*ការវិវត្តនៃអត្រានគរូបនីយកម្មក្នុងពិភពលោក*



*ប្រភព : អ.ស.ប លំនៅ 2003*

*របាយអ្នករស់នៅក្នុងសំណង់អនាធិបតេយ្យតាមតំបន់ភូមិសាស្ត្រ*

## 2. ផលវិបាកដែលពិបាកជម្នះ

**របៀបរបបរស់នៅក្នុងទីក្រុង** : អន្តរភាពទីក្រុង បាននាំមកនូវកំណែប្រែរបៀបរបបរស់នៅរបស់ប្រជាជនដែលជាប់ពាក់ព័ន្ធ ។ ទីជម្រកដែលមានទំហំតូចៗតម្រូវឱ្យអ្នកទីក្រុងកំណត់ចំនួនកំណើត និងកាត់បន្ថយផងដែរនូវចំនួនអ្នករស់នៅជាមួយ ។ ដូច្នេះសម្ព័ន្ធភាពសហគមន៍ដែលធ្លាប់មានកាលពីនៅស្រុកស្រែ មានទំនោរទៅរកភាពចូររលុង ។ ប៉ុន្តែគេឃើញក្រុមជនជាតិផ្សេងៗប្រមូលផ្តុំគ្នារស់នៅក្នុងសង្កាត់ដូចៗគ្នា ដូចជានៅប្រាសាវីល ប្រទេសកុងហ្គោ ។

**បញ្ហាក្រុង** : បន្ទុះទីក្រុង ចោទជាបញ្ហាដ៏ធ្ងន់ធ្ងរចំពោះការគ្រប់គ្រង

- ការលាតសន្ធឹងនៃទីក្រុង អាចជម្នះបានដោយលំបាក (ផ្ទៃដីនិងប្រជាជនម៉ិកស៊ិកូ កើនឡើង 40ដង ក្នុងអំឡុងសតវត្សទី 20) ។
- កង្វះហេដ្ឋារចនាសម្ព័ន្ធ ពិសេសបណ្តាញចែកចាយមានមិនគ្រប់គ្រាន់ (កន្លែងចាក់សំរាម ដំណឹកជញ្ជូន សេវាសុខាភិបាល សង្គម និងអប់រំ ...) ។ ភាគច្រើននៃប្រជាជនក្រុង នៅប្រទេសលោកខាងត្បូង គ្មានប្រព័ន្ធបង្ហូរទឹកកខ្វក់តាមផ្ទះទេ ហើយចំនួនពាក់កណ្តាលមិនបានភ្ជាប់បណ្តាញទឹកស្អាតប្រើប្រាស់ឡើយ ។
- កង្វះទីជម្រក នាំឱ្យកើតមានសង្កាត់លំនៅស្ថានឯកឯង ហៅថា សំណង់អនាធិបតេយ្យ ដែលរីកដុះដាលជាមធ្យមពីរដងលឿនជាងសំណុំទីប្រជុំជនក្រុង ។
- កង្វះការងារ នាំឱ្យមានការរីកចម្រើនផ្នែកទម្រង់ការងារមិនច្បាស់លាស់ (ជាងពាក់កណ្តាលនៃប្រជាជនសកម្មនៅទីក្រុងដាកា) ។ អាស្រ័យហេតុដូច្នេះ សំណង់អនាធិបតេយ្យ ច្រើនតែជាកន្លែងដែលមានសកម្មភាពមិនស្របច្បាប់និងបណ្តាលឱ្យមានឧក្រិដ្ឋភាពខ្ពស់ ។

## ? សំណួរ

1. ចូរឱ្យនិយមន័យនៃពាក្យ : នគរូបនីយកម្ម អត្រានគរូបនីយកម្ម អន្តរភាពទីក្រុង និងសំណង់អនាធិបតេយ្យ ។
2. តើសង្វាក់នគរូបនីយកម្ម នៅប្រទេសលោកខាងត្បូងនិងលោកខាងជើងខុសគ្នាដូចម្តេច ?
3. ចូរស្រង់ឈ្មោះទីក្រុងទាំងអស់ ដែលមានក្នុងមេរៀន ។ តើជាទីក្រុងរបស់ប្រទេសណាខ្លះ ?
4. នៅទ្វីបអាហ្វ្រិក អត្រានគរូបនីយកម្មនិងចំនួនទីក្រុងមានយ៉ាងដូចម្តេច
5. ហេតុអ្វីបានជាអ្នកប្រជាសាស្ត្រចាត់ទុកថា ជាបាតុភូតបន្ទុះទីក្រុង ?
6. តើបន្ទុះទីក្រុងនាំមកនូវបញ្ហាអ្វីខ្លះ ?
7. តើទីក្រុងកម្ពុជាយើងសព្វថ្ងៃ មានការរីកចម្រើនដែរឬទេ ? ហើយកំពុងជួបបញ្ហាអ្វីខ្លះ ?

មេរៀនទី

# 2 ទីក្រុងក្នុងប្រទេសកំពុងអភិវឌ្ឍ

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីទីក្រុងក្នុងប្រទេសកំពុងអភិវឌ្ឍ ៖ ទីក្រុងដែលមានភាពផ្ទុយគ្នា ទីក្រុងមានល្បឿនពីរ ទីក្រុងរីកហួសខ្នាត និងចំណោលស្រុកស្រែ ។

លើសពីភាពខុសគ្នាផ្នែកសង្គម-វប្បធម៌ រវាងទីក្រុងលោកខាងត្បូង និងលោកខាងជើង ក៏មានលក្ខណៈផ្ទុយគ្នាសំខាន់ៗផ្នែករចនាសម្ព័ន្ធទីក្រុងថែមទៀតដែរ ។ ភាពផ្ទុយគ្នានេះ បានបង្ហាញឱ្យឃើញច្បាស់ពីលក្ខណៈសម្គាល់សំខាន់ៗនៃទីក្រុងរបស់ប្រទេសកំពុងអភិវឌ្ឍ ។

## 1. ទីក្រុងដែលមានភាពផ្ទុយគ្នាខ្លាំង

ទីក្រុងនៅប្រទេសកំពុងអភិវឌ្ឍមានលក្ខណៈពីរផ្ទុយគ្នា ។

### 1.1. មណ្ឌលកណ្ដាលក្រុង



*មណ្ឌលកណ្ដាលនៃក្រុងលីម៉ា (ប៉េរូ)*

ផ្នែកនេះ មានលក្ខណៈស្រដៀងគ្នាទៅនឹងទីក្រុងលោកខាងលិច ។ គេឃើញមានសង្កាត់ជំនួញដែលជាទីស្នាក់ការនៃមុខងារក្រុងជាន់ខ្ពស់ (រដ្ឋបាល ធនាគារ ...) ។ សង្កាត់នេះ មានសារៈសំខាន់តិច ឬច្រើនអាស្រ័យនិងកម្រិតសមាហរណកម្មរបស់ប្រទេសនីមួយៗ ទៅក្នុងសេដ្ឋកិច្ចពិភពលោក ។ សង្កាត់នេះស្ថិតនៅលើវិថីល្បីៗ ជាទីប្រមូលផ្តុំអគារពាណិជ្ជកម្ម សណ្ឋាគារធំៗ និងបន្តដោយតំបន់លំនៅស្ថានប្រណិតៗ ។

### 1.2. សង្កាត់អ្នកក្រ



*សង្កាត់អ្នកក្រនៃទីក្រុងលីម៉ា (ប៉េរូ)*

សង្កាត់ប្រភេទនេះស្ថិតនៅក្បែរសង្កាត់ទំនើបខាងលើដែលប្រមូលផ្តុំប្រជាជនក្រុងដល់ទៅ 3/4 ។ សង្កាត់អ្នកក្រមានពីរប្រភេទ ៖

- សង្កាត់ប្រវត្តិសាស្ត្រនៅជិតមណ្ឌលកណ្តាល មានសំណង់ចាស់ៗបាក់បែក មានឈ្មោះផ្សេងៗគ្នាដូចជាស្លាំ (Slums) នៅកាល់កុត្តា វេស៊ីនដេត (Vecindades) នៅម៉ិកស៊ិកូ មេឌីណា (Medinas) នៅទីក្រុងអារ៉ាប់ ។ សង្កាត់ទាំងនោះ មានអ្នកជំនួញតូចតាចនិងក្រុមផលិតករតាមរោងជាង ។
- លំនៅថ្មីៗនៃសំណង់អនាធិបតេយ្យនៅកណ្តាលក្រុង ក៏ដូចជានៅតាមបរិវេណក្រុងនិងមានឈ្មោះហៅខុសៗគ្នាដែរ ។ នៅកន្លែងខ្លះនៃអាមេរិកឡាទីន គេហៅអ្នករស់នៅក្នុងសំណង់អនាធិបតេយ្យថា "ប៉ារ៉ាកៃឌីស្មូ" (Paracaidismos) មានន័យថា អ្នកលោតឆ័ត្រយោង ។ នៅទីក្រុងលីម៉ា (Lima) សង្កាត់អ្នកក្រ រីកធំរហូតដល់ទៅ 15 ដងគិតពីឆ្នាំ 1950 មក ។

## 2. ទីក្រុងដែលមានល្បឿនពីរ

**វិសមភាពចំពោះសេវា** : បន្ថែមពីលើភាពផ្ទុយគ្នាផ្នែកលំហរវាងសង្កាត់អ្នកមាននិងសង្កាត់អ្នកក្រ នៅមានវិសមភាពក្នុងការទទួលបានសេវានិងបរិក្ខារក្រុងទៀត គឺថា រហូតមកដល់ពេលនេះ រាល់ការសាកល្បងរៀបចំ សុទ្ធតែប៉ះទង្គិចទៅនឹង "ជំនោរប្រជាសាស្ត្រ" ដែលបានរុញច្រានលំហក្រុងទៅកាន់តែឆ្ងាយនិងបង្កើនតម្រូវការអ្នកទីក្រុងដល់ទៅដប់ដង ។

**វិសមភាពចំពោះការបំពាក់គ្រឿងបរិក្ខារ :** សង្កាត់ទាំងឡាយ ត្រូវបានបំពាក់គ្រឿងបរិក្ខារយ៉ាងសម្បូរបែប ព្រមទាំងមានការភ្ជាប់បណ្តាញដំណឹកជញ្ជូនឬបន្ទុខផង រីឯសង្កាត់ជុំវិញ គេមិនឃើញមានអ្វីៗទាំងនោះទេ ។ ដូច្នេះហើយ បានជានៅទីក្រុង រីយ៉ូដឺសាណេរ៉ូ ឬម៉ិកស៊ិកូ មេត្រូបម្រើឱ្យដំណឹកជញ្ជូនតែក្នុងសង្កាត់កណ្តាលនៃទីក្រុងប៉ុណ្ណោះ ។

ការបំពុលអាកាស : រយៈពេលធ្វើដំណើរកាន់តែវែង ដោយលំហក្រុងកាន់តែរីកធំទៅៗ ដូចនេះ មនុស្សម្នាត្រូវជិះរថយន្តក្រុងឬរថយន្តផ្ទាល់ខ្លួនកាន់តែច្រើន ចំណែកការបំពុលអាកាសកាន់តែកើនលើសកម្រិតភាពអាសន្ន ។

ការផ្គត់ផ្គង់ទឹក : បញ្ហានេះ អាចបកស្រាយតាមរយៈការប្រកួតប្រជែងដ៏ជូរចត់ ដើម្បីបំពេញតម្រូវការទឹកដល់ឧស្សាហកម្ម ទេសចរណ៍និងពួកអ្នកមាន ។ ម្យ៉ាងវិញទៀត គឺការផ្គត់ផ្គង់ទឹកដល់សង្កាត់ដែលមានប្រជាជនច្រើនលើសចំណុះ ។

# 3. ទីក្រុងរីកធំហួសខ្នាត

## 3.1. ថាមភាពប្រជាសាស្ត្រ

ទីក្រុងនៅប្រទេសលោកខាងត្បូង រីកលូតលាស់ខ្លាំងក្លានិងឆាប់រហ័ស ចាប់តាំងពីពាក់កណ្តាលសតវត្សទី 20មកម្ល៉េះ ។ បន្ទុះទីក្រុង បានបង្ហាញឱ្យឃើញតាមរយៈការកកើតបណ្តុំក្រុង ដូចផ្ការីក ហៅថា មេកាប៉ូល ។

តើការរីកលូតលាស់នេះ បានមកពីអ្វី ? បើនិយាយថា បានមកពីថាមភាពប្រជាសាស្ត្រផ្ទាល់ក្នុងប្រទេសលោកខាងត្បូង គេក៏មិនត្រូវបំភ្លេចមុខងារក្រុងផងដែរទេ ដែលតែងផ្តល់នូវលក្ខខណ្ឌជីវភាពប្រសើរជាងនៅទីជនបទ ព្រមទាំងលទ្ធភាពធ្វើសមាហរណកម្មផ្នែកសង្គមយ៉ាងរហ័សបំផុតផង ។ បន្ទេរប្រជាជនជនបទឆ្ពោះមកកាន់ទីក្រុង អាចមើលឃើញតាមរយៈការរីកធំនៃលំហក្រុង ។

## 3.2. បច្ចេកទេសទំនើប

បាតុភូតនេះ អាចពន្យល់បានផងដែរតាមកត្តាបច្ចេកវិទ្យា ។ បច្ចេកទេសទំនើប នាំចូលមកពីប្រទេសឧស្សាហកម្ម បង្កើតឱ្យមានសំណង់បណ្តាញដំណឹកជញ្ជូន បណ្តាញផ្គត់ផ្គង់ទឹក និងអគ្គិសនីដែលចាំបាច់ដល់ដំណើរការក្នុងមហាបុរីទាំងនោះ ។ ប៉ុន្តែផ្ទុយពីការលូតលាស់ដែលកើតមាននៅប្រទេសអភិវឌ្ឍកាលពីសតវត្សទី 19 កំណើននគរូបនីយកម្មបច្ចុប្បន្ននៅប្រទេសកំពុងអភិវឌ្ឍមិនមែនមានន័យថា ប្រទេសទាំងនោះទទួលបានការអភិវឌ្ឍខ្លាំងក្លានោះទេ ។

# 4. ចំណោលស្រុកស្រែនិងមូលហេតុ

## 4.1. ចំណោលស្រុកស្រែនិងកំណើនធម្មជាតិនៅទីក្រុង

កំណើនប្រជាជនក្រុង ជួនកាលខ្ពស់ជាងនៅស្រុកស្រែ ព្រោះអត្រាមរណប្រមាណនៅទីក្រុងមានកម្រិតទាបជាងនៅជនបទ ហើយសព្វថ្ងៃ អត្រាជាតិប្រមាណក៏មានទំនោរទៅរកការថយចុះដែរ ។ កត្តាធម្មជាតិតែមួយមិនអាចពន្យល់បានពីសំទុះកំណើនបានឡើយ (3.5% ក្នុងមួយឆ្នាំ នៅក្នុងទីប្រជុំជនធំៗ) ។ ចំណោលស្រុកស្រែ បានរួមចំណែកពាក់កណ្តាលក្នុងការធ្វើឱ្យមានកំណើនប្រជាជនក្រុងជាមធ្យមប្រចាំឆ្នាំ ។

## 4.2. មូលហេតុនៃចំណោលស្រុកស្រែ

ចលនាចំណោលស្រុកស្រែមកកាន់ទីក្រុង បណ្តាលមកពីបញ្ហាសេដ្ឋកិច្ច សង្គម និងចិត្តសាស្ត្រព្រមគ្នា ។

- ទម្រង់សេដ្ឋកិច្ចទំនើប មានការរីកចម្រើន ។ ចំណែកនៅទីជនបទ ការរស់នៅកាន់តែលំបាក ដោយសារសម្ពាធប្រជាសាស្ត្រ ដីខ្សោះជីជាតិយ៉ាងរហ័ស ប្រាក់កម្រៃប្រចាំថ្ងៃមានកម្រិតទាបពេក ។
- នៅទីក្រុង ការរកប្រាក់មានភាពងាយស្រួលជាងនៅជនបទ ព្រោះសម្បូរការងារនិងសកម្មភាពតូចតាចនៃសេវាកម្ម ។
- ការទទួលព័ត៌មានតាមបណ្តាញផ្សព្វផ្សាយព័ត៌មាន ស្តីអំពីមូលហេតុនៃកង្វះខាតជីវភាព នាំឱ្យអ្នកជនបទរិតតែមិនសប្បាយចិត្តខ្លាំងឡើង ។

ទាំងអស់នេះ ជាកត្តាជំរុញនិងទាក់ទាញប្រជាជនជនបទ ពិសេសយុវជន ឱ្យចាកចោលស្រុកកំណើតមកកាន់ទីក្រុង ក្នុងក្តីសង្ឃឹមថានឹងអាចរកប្រាក់កម្រៃចិញ្ចឹមជីវិត រកសេរីភាពផ្ទាល់ខ្លួន និងរបៀបរស់នៅតាមបែបសម័យផងដែរ ។

## សំណួរ

1. លក្ខណៈសម្គាល់ពិសេសៗនៃទីក្រុងនៅប្រទេសលោកខាងជើងនិងលោកខាងត្បូងមានដូចម្តេច ?
2. តើបន្ទុះប្រជាជនក្រុងនៅប្រទេសលោកខាងត្បូងកើតឡើងដោយសារអ្វីខ្លះ ?
3. ចលនាចំណោលស្រុកស្រែ មានទំនាក់ទំនងទៅនឹងកត្តាសេដ្ឋកិច្ច សង្គម និងចិត្តសាស្ត្រ។ ចូរបង្ហាញឱ្យច្បាស់លាស់ទៅតាមកត្តានីមួយៗ ។
4. ចូរពន្យល់ពាក្យ : ថាមភាពប្រជាសាស្ត្រ ជំនោរប្រជាសាស្ត្រ សម្ពាធប្រជាសាស្ត្រ ។
5. នៅកម្ពុជាយើងមានកំណើនប្រជាជនក្រុងដូចម្តេចដែរ ? តើកំណើននេះ បណ្តាលមកពីមូលហេតុអ្វីខ្លះ ? ចូរពន្យល់ ។

មេរៀនទី

# 3 ការប្រជែងផ្នែកនគរូបនីយកម្ម

ចប់មេរៀននេះ សិស្សអាច

❑ ពណ៌នាពីការប្រជែងផ្នែកនគរូបនីយកម្ម : ផលប្រយោជន៍និងបញ្ហានគរូបនីយកម្ម ។

នគរូបនីយកម្ម ជាដំណើរការមួយចៀសមិនផុតដែលផ្សារភ្ជាប់ជាមួយការអភិវឌ្ឍសេដ្ឋកិច្ច ។ ទីក្រុងទាំងឡាយ ជាទីប្រជុំបដ៏សំខាន់នៃផលិតកម្ម ការងារ និងការបង្កើតថ្មី ជាកន្លែងផ្សព្វផ្សាយសកម្មភាពផលិតកម្ម ផ្តល់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មចាំបាច់ សម្រាប់ទីផ្សារនិងលំនាំចេញ ។ ទីក្រុងក៏ជាកន្លែងប្រើប្រាស់និងកែច្នៃផលិតផលកសិកម្មផងដែរ ដើម្បីជំរុញកសិកម្មឱ្យទទួលបានការរីកចម្រើនជាបន្តបន្ទាប់ ។ ប៉ុន្តែកាលណាអត្រាកំណើនប្រជាជនស្មើ ឬខ្ពស់ជាងអត្រាកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍជួបការលំបាកឬត្រូវរាំងស្ទះ ។ តើនគរូបនីយកម្មផ្តល់ផលប្រយោជន៍និងបញ្ហាអ្វីខ្លះ ?

## 1. ផលប្រយោជន៍នៃនគរូបនីយកម្ម

### 1.1. នគរូបនីយកម្មនិងការអភិវឌ្ឍសេដ្ឋកិច្ច

សកម្មភាពទាំងពីរនេះ តែងមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធប្រកបដោយភាពស្មុគស្មាញនិងមានលក្ខណៈពង្រឹងគ្នាទៅវិញទៅមក ។

ការសង្កេតជាទូទៅនៅលើពិភពលោក ក្នុងប្រទេសមួយ បើប្រជាជនម្នាក់រកបានប្រាក់ជាមធ្យម 480$ ក្នុងមួយឆ្នាំ ប្រជាជនក្រុងរបស់ប្រទេសនោះនឹងមានប្រមាណ 37% នៃប្រជាជនសរុប បើរកបាន 1 930$ អ្នកទីក្រុងមានប្រមាណ 52% បើរកបាន 3 240$ អ្នកទីក្រុងឡើងដល់ 62% បើរកបាន 17 080$ អ្នកទីក្រុងមាន 78% ។

ម្យ៉ាងវិញទៀត ផលិតភាពការងារកសិកម្មខ្ពស់ ជាកត្តាជំរុញពលករជនបទឱ្យរត់មកកាន់ទីក្រុង ដើម្បីស្វែងរកការងារ ដែលបង្កើតបានជាកម្លាំងពលកម្មយ៉ាងច្រើន ជាហេតុនាំឱ្យផលិតកម្មនិងសេវាកម្មក្នុងទីក្រុងរីកធំឡើង ។ ទាំងនេះ ជាកម្លាំងរួមចំណែកធ្វើឱ្យសេដ្ឋកិច្ចនិងទីក្រុងរីកចម្រើន ។ ដូចគ្នានិងប្រទេសឧស្សាហកម្មលូតលាស់ដែរ នគរូបនីយកម្មនៅប្រទេស P.V.D ជាលក្ខខណ្ឌសម្រាប់បង្កើតពង្រឹងនិងពង្រីកគ្រឹះសេដ្ឋកិច្ច ដែលជាប្រភពផ្តល់ការងារ ប្រាក់ចំណូល និងកំណើនប្រជាជនក្រុង ។

## 1.2. តួនាទីនៃបណ្ដាញក្រុង

ប្រទេសលោកខាងត្បូង (ពិសេសទ្វីបអាហ្វ្រិក) មានមេត្រូប៉ូល (មាតុធានី)តិចតួចណាស់ ។ លើកលែងតែ ប៉ូលខ្លះៗចេញ ដូចជាស៊ាងហៃ ឬសាវប៉ូឡូ ឥទ្ធិពលមេត្រូប៉ូលលោកខាងត្បូង ត្រូវបានកំណត់ត្រឹមថ្នាក់ជាតិប៉ុណ្ណោះ ។ ទម្ងន់ប្រជាសាស្ត្រ មានមិនគ្រប់គ្រាន់សម្រាប់កសាងអានុភាពនិងធានារ៉ាប់រងនូវកម្រិតថ្នាក់អន្តរជាតិរបស់ទីក្រុងមួយបានឡើយ ។ ទីក្រុងឡាកូស មានប្រជាជនច្រើនជាងទីក្រុងប៉ារីស ឬទីក្រុងឡុង តែមិនអាចទទួលបានឋានៈជាមេត្រូប៉ូលអន្តរជាតិឡើយ ដោយឡាកូសនៅខ្វះស្ថាប័នហិរញ្ញវត្ថុ សេដ្ឋកិច្ច និងវប្បធម៌ថ្នាក់អន្តរជាតិ ។

តើបណ្ដាញមជ្ឈមណ្ឌលក្រុងតូចៗ ក្នុងក្របខ័ណ្ឌជាតិអាចបំពេញតួនាទីអ្វីខ្លះ ? ជារួម អាចជួយដល់ទំនើបកម្ម កសិកម្ម និងកំណើនផលិតកម្ម ។ មជ្ឈមណ្ឌលក្រុង មានមុខងារខាងហិរញ្ញវត្ថុ តែថ្លៃការចែកចាយ និងផ្ដល់ការងារសម្រាប់កសិករ ។ បណ្ដាញបញ្ចូលគ្នា ឬបែកគ្នាតាមលក្ខណៈរូបរបស់ទីក្រុងទាំងតូចទាំងធំ បង្កើតជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ដែលនៅទីនោះសម្ភារៈប្រើប្រាស់ទំនើបៗអាចរកទិញបាន ហើយលទ្ធភាពជ្រៀតចូលនៃផលិតផលកសិកម្ម គឺជាការលើកទឹកចិត្តចំពោះកសិករ ។ លំនៅស្ថានក្នុងទីក្រុង បានទាក់ទាញប្រជាជនជនបទមករស់នៅកាន់តែច្រើន ដែលអាចកាត់បន្ថយសម្ពាធលើដីស្រែចម្ការបានមួយចំណែក ។

## 1.3. ឥទ្ធិពលវិជ្ជមាននៃទីក្រុង

នៅក្នុងប្រទេសជាច្រើននៃទ្វីបអាហ្វ្រិក អាស៊ីខាងត្បូង និងអាមេរិកកណ្ដាលប្រាក់ចំណូលនៃគ្រួសារជនបទ ពឹងផ្អែកលើសមាជិកគ្រួសារធ្វើការក្រៅម៉ោង ឬពេញម៉ោងក្នុងទីក្រុង ។ ពួកគេបានបញ្ជូនប្រាក់ចំណូលមួយចំណែកទៅឱ្យគ្រួសារនៅឯជនបទ ។ លើសពីនេះទៅទៀត គេអាចរំពឹងទុកថានគរូបនីយកម្មបានផ្ដល់ផលប្រយោជន៍ជាច្រើនដល់សង្គមដូចជា បំផុសឱ្យមានការកាត់បន្ថយអត្រាជាតិប្រមាណ ផ្ដល់ការងារផ្សេងៗនិងថ្មីៗពិសេសសម្រាប់ស្ត្រី បង្កើនកម្លាំងពលកម្ម និងលើកកម្ពស់វប្បធម៌និងសង្គមក្នុងក្រុង (ប្រជាជនអភិវឌ្ឍចំណេះដឹងនិងជំនាញកាន់តែប្រសើរឡើង) ។

# 2. បញ្ហានគរូបនីយកម្ម

## 2.1. កំណើនភាពក្រីក្រក្នុងក្រុង

យោងតាមឯកសារធនាគារពិភពលោក (ឆ្នាំ 1994) ប្រជាជនក្រុងប្រហែល 340 លាននាក់ ត្រូវជា 1/4 នៃប្រជាជនក្រុងសរុបក្នុងប្រទេស P.V.D កំពុងរស់នៅក្នុងភាពក្រីក្រទាំងស្រុង ។ ចំនួននេះ នឹងចេះតែកើនយ៉ាងរហ័ស ក្នុងចំណោមប្រជាជនក្រុង ។ ប្រសិនបើយើងគិតពីចំនួនមនុស្សរស់នៅក្នុងភាពក្រីក្រ ជាងពាក់កណ្ដាលនៃអ្នកទាំងនោះរស់នៅប្រមូលផ្ដុំក្នុងក្រុងនៅឆ្នាំ 2000 មាន 90% នៅអាមេរិកឡាទីន 40% ទ្វីបអាហ្វ្រិកនិង 45% ទ្វីបអាស៊ី (UNDP 1997) ។ ចំណែកទ្វីបអាស៊ីដូចជាកាល់កុត្តា(60%) ការ៉ាជី(45%) និងម៉ានីល(35%)ជាដើម ។

ភាពក្រីក្រក្នុងទីក្រុង បាននាំមកនូវបញ្ហាដ៏ធ្ងន់ធ្ងរដល់រដ្ឋាភិបាលនានា នៅដំណាច់សតវត្សទី 20 និងដើមសតវត្សទី 21 ។ ទោះបីប្រាក់ចំណូលរបស់អ្នកទីក្រុងកើនខ្ពស់ លទ្ធភាពទទួលបានសេវាកាន់តែប្រសើរក៏ដោយ ក៏អ្នកទីក្រុងក្រីក្រអាចមានការលំបាកច្រើនជាងអ្នកក្រីក្រនៅជនបទដែរ ។ អ្នកទាំងនោះ រស់នៅកន្លែងសំណង់អនាធិបតេយ្យ ខ្វះសព្វ ខ្វះគ្រប់ ដូចជាអនាម័យ បណ្ដាញទឹកស្អាត បណ្ដាញអគ្គិសនី ច្បាប់ទម្លាប់ និងសុខសុវត្ថិភាព ។

កង្វះអាហារនិងជំងឺ ជាបញ្ហាដ៏ធ្ងន់ធ្ងរនៅតំបន់ក្បែរក្រុង ។ នៅប្រទេសកូឡុំប៊ី កាតេម៉ាឡា និងម៉ារ៉ុក របបអាហារប្រចាំថ្ងៃរបស់អ្នកជនបទមានចំនួនកាឡូរីច្រើនជាងអ្នកក្រីក្រក្នុងក្រុង ។ អ្នកជំងឺរបេង នៅទីក្រុងអាប៊ីតសង់ (ប្រទេសកូតឌីវ័រ) មានកម្រិត 6ដងខ្ពស់ជាងអ្នកជនបទ ។ ទារកទើបកើតជាង 20% ក្នុងទីក្រុងព័រអូប្រាំងនៃប្រទេសហៃទី ស្លាប់មុនអាយុ 1ឆ្នាំ ច្រើនជាងបីដងអត្រានៅជនបទ ។ នៅប្រទេសកម្ពុជា កុមារក្រីក្រនៅជនបទ មានអត្រាខ្វះអាហារខ្ពស់ រីឯកុមារទីក្រុងក្រីក្របំផុតវិញ មានតែ 20%ប៉ុណ្ណោះ ។

## 2.2. ការប្រមូលផ្ដុំសកម្មភាពសេដ្ឋកិច្ច

នៅក្នុងប្រទេសលោកខាងត្បូង ភាគច្រើនសកម្មភាពផលិតកម្មទំនើបៗប្រមូលផ្ដុំក្នុងក្រុងធំៗដែលបង្កើតឱ្យមានវិសមភាពអភិវឌ្ឍន៍សេដ្ឋកិច្ចរវាងតំបន់នានានៃប្រទេស ។ ទីក្រុងបាងកក (ថៃ)មានសកម្មភាពផលិតកម្មចំនួន 74% ទីក្រុងឡាកូស (នីហ្សេរីយ៉ា) មានពលករជំនាញខ្ពស់ 40% ទីក្រុងសាវប៉ូឡូ(ប្រេស៊ីល) ផ្ដល់តម្លៃបន្ថែមឧស្សាហកម្មជាង 40% (UNDP 1997) ។ នៅកម្ពុជា ប៉ូលឧស្សាហកម្មលាតសន្ធឹងលើទីក្រុងភ្នំពេញនិងតំបន់ជាយៗក្រុងនៃខេត្តកណ្ដាលនិងកំពង់ស្ពឺ ។ វិសមភាពទាំងនេះ នាំមកនូវផលប៉ះពាល់ដល់តុល្យភាពអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ ។

## 2.3. ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈមិនគ្រប់គ្រាន់

ប្រជាជនក្រុងកាន់តែកើន ការពង្រីកទីក្រុងជាការចាំបាច់ ហើយតម្រូវការផ្នែកបរិក្ខារក្រុងក៏កាន់តែច្រើន ។ តាមការគន់គូររបស់អង្គការសហប្រជាជាតិ បើទីក្រុងទាំងឡាយដែលមានប្រជាជនលើសពីមួយលាននាក់ ចេះតែបន្តរីកលូតលាស់តាមសង្វាក់បច្ចុប្បន្ន នោះមធ្យោបាយដឹកជញ្ជូននិងគមនាគមន៍ សេវាសុខាភិបាល និងភាពងាយស្រួលទាំងឡាយនឹងឈានទៅដល់ចំណុចមួយដ៏លំបាកនៅឆ្នាំ 2000 (UNDP 1997) ។

នៅប្រទេសលោកខាងត្បូង បណ្ដាញលូទឹកសំអុយក្នុងទីក្រុងដ៏ច្រើន តែងកកស្ទះ ថែរក្សាមិនល្អ ឬក៏គ្មានផងទេ ។ ទីក្រុងចំនួនមួយភាគបីមិនបានធ្វើប្រព្រឹត្តកម្មទឹក ដែលប្រើប្រាស់រួចហើយ ។ បន្ថែម

ពីលើនេះ បញ្ហាសំរាមដែលប្រមូលមិនបានទាន់ពេលនិងយកទៅកែច្នៃបានតែពាក់កណ្ដាលប៉ុណ្ណោះ ធ្វើឱ្យមានការបំពុល ដី ទឹក និងអាកាស (ពេលផុតវា)កាន់តែធ្ងន់ធ្ងរឡើង ។ ទីក្រុងទាំងឡាយនៅកម្ពុជាយើងសព្វថ្ងៃ ក៏មានបញ្ហាទាំងនេះដែរ ជាពិសេសបណ្ដាញលូបង្ហូរទឹកសំអុយ មិនទាន់មានគម្រប ជះក្លិនអសោច ជាហេតុនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ និងសោភណភាពក្រុង ។

តាមឯកសាររបស់អង្គការសុខភាពពិភពលោក មនុស្សចំនួន 24% ខ្វះទឹកស្អាតប្រើប្រាស់ ហើយ 25% ពុំមានបណ្ដាញបញ្ចេញទឹកចាស់ប្រើប្រាស់រួច ។

## 2.4. ផលប៉ះពាល់គុណភាពបរិស្ថានក្រុង

ទីក្រុងធំៗបានប្រើប្រាស់ធនធានយ៉ាងច្រើន(ថាមពល ផលិតផលអាហារ រូបធាតុដើម ...) ដែលគេត្រូវដឹកជញ្ជូនចូល ។ ផ្ទុយទៅវិញ ផលិតផលដែលទីក្រុងបង្កើតបានក៏ត្រូវនាំចេញក្រៅដែរ ។ ជាវិបាក បណ្ដាញផ្គត់ផ្គង់និងបន្សុទ្ធទឹក ត្រូវតែអភិវឌ្ឍន៍ក្នុងពេលជាមួយគ្នានឹងការរីកលូតលាស់ទីក្រុង ។ ការត្រួតពិនិត្យគុណភាពបរិស្ថាន និងការរៀបចំចាត់ចែងសមស្រប ជាប្រការចាំបាច់ដែលត្រូវធ្វើ ដើម្បីធានាបាននូវទំនាក់ទំនងល្អរវាងនគរូបនីយកម្មនិងបរិស្ថាន ។

ប្រភពមួយដ៏សំខាន់នៃកង្វក់ក្រុង និងឱនភាពគុណភាពបរិស្ថានគឺ កំណើននៃបម្រើបម្រាស់ឥន្ធនៈផូស៊ីល ។ ចំហេះឥន្ធនៈផូស៊ីល បានបញ្ចេញឧស្ម័នពុលដ៏ច្រើនទៅក្នុងបរិយាកាស ដូចជា $CO_2$ $SO_2$ និង $NO_x$ ជាដើម ដែលនាំឱ្យប៉ះពាល់ដល់សុខភាពមនុស្ស ។ នៅទីក្រុងរបស់ប្រទេសលោកខាងត្បូង ការបំពុលអាកាសនៅតែបន្តកើនឡើងយ៉ាងរហ័ស (ម៉ិកស៊ិកូ ប៉ិជីន ក្រុងតែរ ...) ។

នគរូបនីយកម្មនៅប្រទេសលោកខាងត្បូងមានន័យពីរគឺ អភិវឌ្ឍន៍សេដ្ឋកិច្ចនិងកំណើនភាពក្រីក្រ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏វាមិនបានផ្ដល់វិបត្តិ ឬសោកនាដកម្មអ្វីឡើយ ។ នគរូបនីយកម្មដ៏ឆាប់រហ័ស ផ្ដល់ឱកាសសម្រាប់ការបង្កើតកម្មវិធីច្នៃប្រឌិតថ្មីៗ សំដៅអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច ។

## ? សំណួរ

1. តើនគរូបនីយកម្ម នាំមកនូវផលប្រយោជន៍និងផលវិបាកអ្វីខ្លះ ?
2. ហេតុអ្វីបានជាផលិតភាពការងារកសិកម្មខ្ពស់ ជាកត្តាជំរុញពលករជនបទ ឱ្យធ្វើចំណោលស្រុកស្រែមកកាន់ទីក្រុងទៅវិញ ?
3. តើចំណោលស្រុកស្រែមកកាន់ទីក្រុងនៅកម្ពុជាយើង បណ្ដាលមកពីមូលហេតុអ្វីខ្លះ ?
4. តើនគរូបនីយកម្មនៅកម្ពុជាយើងសព្វថ្ងៃ ជួបប្រទះនិងបញ្ហាអ្វីខ្លះ ?

## ? សំណួរបញ្ចប់ជំពូកទី៥

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់មុខចម្លើយត្រូវតែមួយគត់**

1. យិនសាសា (Kinshasa) ជារដ្ឋធានីរបស់

☐ ក. ប្រទេសកូតឌីវ័រ ☐ ខ. ប្រទេសនីហ្សេរីយ៉ា

☐ គ. ប្រទេសអាល់ហ្សេរី ☐ ឃ. សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ

2. ទីក្រុងដ៏ធំរបស់ប្រទេសមួយដែលមានឥទ្ធិពលទៅលើលំហមួយ មិនថាធំ ឬតូចទេ ហៅថា

☐ ក. មេត្រូប៉ូល ☐ ខ. មេកាប៉ូល

☐ គ. មេកាឡូប៉ូល ☐ ឃ. អូលីកូប៉ូល

**II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ**

1. សព្វថ្ងៃ ពិភពលោកមានប្រជាជនក្រុងចំនួន ........................................... ។
2. បន្ទុះទីក្រុងនាំមកនូវបញ្ហាជាច្រើនដែលអាច ........................... ដោយលំបាក ។
3. ចំណោលស្រុកស្រែ ជាបាតុភូតដែលបណ្ដាលមកពីបញ្ហាសេដ្ឋកិច្ច ............ និង ............. ។

**III. សំណួរ**

1. តើសង្វាក់នគរូបនីយកម្មនៅលោកខាងជើង និងលោកខាងត្បូង ខុសគ្នាដូចម្ដេច ?
2. ចូរបង្ហាញឱ្យបានច្បាស់លាស់អំពីបញ្ហាសេដ្ឋកិច្ច សង្គម និងចិត្តសាស្ត្រ ដែលនាំឱ្យមានបាតុភូតចំណោលស្រុកស្រែមកកាន់ទីក្រុង ។
3. តើនគរូបនីយកម្មនៅកម្ពុជាយើងសព្វថ្ងៃ ជួបប្រទះនឹងបញ្ហាអ្វីខ្លះ ?
4. តើទីក្រុងភ្នំពេញមានតួនាទីសំខាន់ៗអ្វីខ្លះ ? តើគេអាចចាត់ទុកទីក្រុងភ្នំពេញជាមាតុធានី (មេត្រូប៉ូល) បានដែរឬទេ ? ចូរពន្យល់ ។